ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៣២ លេខ ១ ខែមករា

ព. ស. ២៥០៣ គ. ស. ១៩៦០

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ


| *ផ្នែកសាសនា* | បញ្ជីរឿង | ទំព័រ |
| --- | --- | --- |


- ព្រះសមណគោតមសម្មាសម្ពុទ្ធ លោករដ្ឋលេខាធិការ ស្វ-ណែម រៀបរៀង . . ១
- ព្រះពុទ្ធសាសនា ជាគកិសនាន៍នាំទៅកាន់សេចក្ដីសុខ លោក វ៉ាយ-ប៊ុក រៀបរៀង ១០
- មធុរសវាហិណី សម្ដេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង ព្រះញាណកោសល ញាណ-ឈឿន ពិនិត្យ . . . . ២២
- មហោសថជាតក លោក អ៊ឹម-ភម ចម្លងពីសាស្ត្រាស្លឹករឹត ព្រះពុទ្ធវង្ស កឹម-តួរ ពិនិត្យ . . . . . . . ៤១

*ផ្នែកអក្សរសាស្ត្រ*

- រឿងមរណមាតា (តមក) លោក ឌី-សុវណ្ណ ចម្លងពីសាស្ត្រាស្លឹករឹត . . ៥១
- រឿងព្រេងអេហ្ស៊ីប ចែងអំពីការវិនិច្ឆ័យនៃភាពឈ្លាស ភិក្ខុ ម៉ែន-រៀម ប្រែពីភាសាអង់គ្លេស. . . . . . . ៥៩
- សុភាសិតជាតិកូរ៉េ និងខ្ចូតសឿ លោក វ៉ាយ-ប៊ុក ប្រែពីភាសាបារាំង . . ៦៥
- រឿងសាមកុក (តមក) ឧកញ៉ា គួ-កន ប្រែ . . . . . ៧២
- ពាក្យវប្បធម៌ លោក សម-ថាំង សមាជិកគណៈកម្មការវប្បធម៌ រៀបរៀង . ៩១

*ផ្នែកកំណត់ទីនិងប្រវត្តិការណ៍*

- គតុសំរាប់ព្រះមហាសន្និបាតនៃមន្ត្រីសង្ឃលើកទី ១៦ លោកឋង-វង រៀបរៀង.. ៩៨
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . ១១៩



ខួបឆ្នាំ មាន ១២ សៀវភៅ ដំឡៃជាវ ២៣០រ០០

**KAMBUJASURIYA**

Revue mensuelle de culture religieuse et littéraire
Publiée par l'Institut Bouddhique de Phnom-Penh

# sommaire

## Partie religieuse :

— Le Buddha Gotama par M. SO-NEM. . . . . . . 1

— Le Bouddhisme est la religion qui conduit à la paix par M. RAY-BUC . . . . . . . . . . . 10

— Madhurasavahini traduit par Samdec Prah Dhammalikhita Louis-Em, revu et corrigé par Vén-NHEAN-CHHOEUN . . . . . . . . . . . . . 22

— Prah Mahcsothajataka relevé du manuscrit sur feuilles de la tanier par M. IM-PHON et revu par Vén-KEM-TO 41

## Partie littéraire :

—Légende de Marana Mâtâ(suite) relevée du manuscrit sur feuilles de latanier par M.BY-SOVANN . . . . . . 51

— Contes et légendes égyptiens «Judgment of Karakoush» traduit de l'anglais par Vén-MEN-RIEM . . . . . 59

— Recueil de proverbes et maximes Peuls et Toucouleurs traduit du français par M. RAY-BUC. . . . . . . 65

— Histoire de Sam-Kok(suite)traduite par l'Oknha NOU-KAN. 72

— Activités de la Commission culturelle par M. SAM-THANG 91

## Notes et Chroniques :

— Seizième réunion annuelle, des dignitaires religieux pour l'année par M. THANG-VONG. . . . . . . . 98

— Dictionnaire Sanscrit-khmer (suite) par Vén-PANG-KHAT 118

Prix d'abonnement annuel (comprenant 12 numéros): 230$00 .

ផ្នែកសាសនា

# ព្រះសមណគោតមសម្មាសម្ពុទ្ធ

លោក សូ-ណៃម រដ្ឋលេខាធិការក្រសួងធម្មការ រៀបរៀង

---

ព្រះសមណគោតមសម្មាសម្ពុទ្ធ ទ្រង់ប្រសូតក្នុង៥៦០ឆ្នាំ ទ្រង់ព្រះផ្នួសក្នុង ៥៣១ ឆ្នាំមុនគ្រិស្តសករាជ ។

ពីតមែនតែបងប្អូនជនរួមជាតិ បានកាន់ខ្ជាប់នូវព្រះពុទ្ធសាសនា ជាយូរអង្វែងមកហើយ លើកលែងតែបងប្អូនខ្មែរខ្លះ ដែលកាន់សាសនាកាតូលិកនិងសាសនាឥស្លាម ។ តែពេលនេះ សូមលើកជីវប្រវត្តិព្រះសមណគោតមបរមគ្រូដោយត្រួស ៗ ជាថ្មីទៀត ដើម្បីជាទីរំលឹក ជាទីគោរពនិងជាទីពិចារណាតទៅ ។

ដូចបុព្វជនទាំងឡាយ ដែលកាលកន្លងទៅឆ្ងាយពុំអាចឲ្យការបងហាំនៃមនុស្សយើងដឹកល់ទុកបានដំច្បាស់លាស់ នូវអនុស្សាវរីយ៍ណាមួយ អនុស្សាវរីយ៍ដែលកាលកន្លងទៅនោះ តែងពង្រីកថែមថយយ៉ាងទូលំទូលាយ អនុស្សាវរីយ៍ចំពោះព្រះបរមគ្រូក៏ដូច្នោះដែរ ។ បើគេពិនិត្យពុទ្ធប្បវត្តិតាមគម្ពីរនានា គេនឹងអាចសង្កេតឃើញថា ពុទ្ធប្បវត្តិជាប្រវត្តិប្រកបដោយអច្ឆរិយហេតុគ្រប់អន្ទើចាប់តាំងពីគព្ភាភិនិក្ខមនៈ រហូតព្រះបរិនិព្វានៗ

ដូច្នេះហើយ បញ្ហាប្រវត្តិសាស្ត្រ ក៏បានកើតមានឡើងហោចថា

ព្រះពុទ្ធបានគង់ព្រះជន្មមានពិតមែនឬ ? ឬក៏គ្រាន់តែជានិមិត្តបុគ្គលទេ ? (personnage légendaire meztbu) ។

ចំពោះរឿងនេះ អ្នកប្រវត្តិសាស្ត្រជំនាញខាងអារ្យធម៌ឥណ្ឌា មានយោបល់ប្លែកៗគ្នា តែទោះជាយ៉ាងណាក៏ដោយ សព្វថ្ងៃពុំមានអ្នកណាអាចទុកព្រះពុទ្ធជានិមិត្តបុគ្គលបានឡើយ ។ ព្រះបរមពោធិសត្វពិតជាមនុស្សមួយរូប ពុំមែនជាអាទិទេព ឬជាតំណាងនៃអាថ៌កំបាំងមើលមិនឃើញឯណាឡើយ ដោយហេតុបុរាណវត្ថុវិជ្ជា (archéalèogie) បានបង្អួលនូវភស្តុតាងដ៏ច្បាស់លាស់ណាស់ ភស្តុតាងដែលបានស្ថិតនៅមកតាំងពីសតវត្សទី៣ មុនគ្រិស្តសករាជម្ល៉េះ ។

ដូច្នេះហើយ អ្នកប្រាជ្ញខាងប្រវត្តិសាស្ត្រយល់ថា គេពុំអាចដកអច្ឆរិយហេតុពីព្រះពុទ្ធ ឬព្រះពុទ្ធពីអច្ឆរិយហេតុ ដោយពុំប៉ះពាល់ធ្វើឲ្យខូចដល់ព្រះពុទ្ធសាសនា ព្រោះជីវភាពព្រះពុទ្ធនេះពិតជាឧទាហរណ៍ ជាវិចិត្រកម្មដ៏ល្អបំផុតជាពិសេសក្រៃលែង សំរាប់ព្រះធម៌ ការប្រៀនប្រដៅរបស់ព្រះពុទ្ធ ព្រោះជីវភាពនេះ ជាជីវភាពគំរូសំរាប់ជនទាំងទូទៅដែលស្វែងរកសុភមង្គល ឬព្រះនិព្វាន ។

ព្រះបរមពោធិសត្វ ជាព្រះរាជបុត្រនៃព្រះបាទសុទ្ធោទនៈ និងព្រះមហាមាយាទេវី ត្រកូលគោតម (គោ ព្រះអាទិត្យ តម ប្រសើរ)=ពូជវង្សនៃព្រះអាទិត្យដ៏ប្រសើរ, ជាស្តេចសាក្យនៅនគរកបិលពស្តុ ។ ព្រះអង្គ

ប្រសូតនៅលុម្ពិនីវ័នឧទ្យាន ជាចន្លោះនគរកបិលពស្តុ និងទេវទហៈក្នុង នេបាលរដ្ឋសព្វថ្ងៃ ។

ពុទ្ធទិពានបានដំណាលថា ព្រះបរមពោធិសត្វប្រសូតមក ក៏ឈរលើផែនដី ហើយឈានព៉ជំហានទៅទិសខាងកើត ។ លុះផ្តោះព្រះនេត្រគ្រប់ទិសទាំង ១០ ហើយ ក៏បន្លឺវាចាថា :

អគ្គោហមស្មិ លោកស្ស
សេដ្ឋោហមស្មិ លោកស្ស
ជេដ្ឋោហមស្មិ លោកស្ស
អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោ ។

ដែលមានន័យថា : ខ្លួនអញជាកំពូលនៃលោក ជាបុគ្គលប្រសើរជាងគេក្នុងលោក ជាច្បងជាងគេទាំងអស់ក្នុងលោក ហើយកំណើតនេះជាកំណើតក្រោយបំផុតរបស់អញ អំណឹះតទៅមុខ អញគ្មានកើតទៀតឡើយ ។

## និមិត្ត ៤ និងការទ្រង់ចេញទៅបួស

កាលប្រសូតបាន ៥ ថ្ងៃហើយ ព្រាហ្មណ៍ ៨ នាក់បានតាំងពិធីរើសព្រះនាមថ្វាយ ហើយបានថ្វាយព្រះនាមថា សិទ្ធារ្ថ (បាលិ សិទ្ធត្ថ) មានន័យថា អ្នកដែលមានប្រយោជន៍ ឬមានបំណងសម្រេចហើយ អ្នក

សម្រេចប្រយោជន៍តាមបំណង ៗ

ក្រោយដែលបានពិនិត្យលក្ខណៈនៃរូបព្រះសិទ្ធត្ថ, ព្រាហ្មណ៍ ៧ នាក់លើកម្រាមដៃ ២ ហើយទាយថា « បើនៅគង់នគរ ព្រះរាជកុមារនេះនឹងបានជាស្តេចចក្រពត្រាធិរាជ, បើចេញពីនគរនឹងបានត្រាស់ជាព្រះពុទ្ធមួយព្រះអង្គ » ។

ឯព្រាហ្មណ៍ទី ៨ ឈ្មោះកោណ្ឌញ្ញព្រាហ្មណ៍ លើកម្រាមដៃតែមួយទាយថា « ព្រះរាជកុមារនេះ ប្រាកដជាបានត្រាស់ជាព្រះពុទ្ធមួយព្រះអង្គ » ។ ព្រាហ្មណ៍ទាំងឡាយក៏បានបញ្ជាក់ថា ព្រះរាជកុមារនឹងចេញចាកនគរទៅបួស នៅវេលាដែលបានឃើញនិមិត្ត ៤ យ៉ាង: ឃើញមនុស្សជរា ១ ព្យាធិ ១ មរណៈ ១ និងភិក្ខុ ១ ។

ព្រះបាទសិរីសុទ្ធោទនព្រះវរបិតា ក៏ចាត់ការម៉ឺងម៉ាត់ប្រយ័ត្នកុំឲ្យព្រះអយ្យបុត្រឃើញនិមិត្តទាំងនេះ ទុកឲ្យឋិតនៅតែក្នុងទីសប្បាយ ទីរីករាយ សម្បូណ៌ទៅដោយភោគទ្រព្យ និងគ្រឿងដំរេកគ្រប់យ៉ាង ព្រមទាំងស្រីស្នំ ៤ ម៉ឺន ជាបរិវារ កុំឲ្យអារម្មណ៍ទាក់ទាញចិត្តគិតដល់សេចក្តីអន់អាក់ព្រះទ័យ សេចក្តីព្រួយជាទុក្ខបែបណាបន្តិចសោះឡើយ ។

ដល់ព្រះជន្ម ១៦ ឆ្នាំ ទ្រង់អភិសេកព្រះនាងយសោធរា ឬហៅម្យ៉ាងទៀតថា ពិម្ពា ព្រះអគ្គជាយា ប្រកបដោយរូបឆោមលោមពណ៌ជាចម្បងនៃអស់ស្នំផង ៗ ទ្រង់សោយសុខសម្បត្តិដរាបដល់ព្រះជន្ម២៩ឆ្នាំ

ទើបមានព្រះរាជឱរសមួយអង្គព្រះនាមព្រះរាហុលកុមារ ។ តែទោះជាយ៉ាងណាក៏ដោយ ព្រះបរមពោធិសត្វពុំអាចចៀសឡើងផុតពីសង្គមមនុស្ស នឹងពីដំណើរដែលជាច្បាប់របស់ធម្មជាតិនៃមនុស្ស ។

លុះបានប្រទះនិមិត្តទាំង ៤ ប្រការគឺ មនុស្សចាស់ មនុស្សឈឺ មនុស្សស្លាប់ នឹងបព្វជិតហើយ ព្រះសិទ្ធត្ថទ្រង់ជាប់អារម្មណ៍ តាំងព្រះទ័យនឹងចេញបព្វជ្ជាតាមយករាស ដោយឈ្វេងយល់ថា មានតែបព្វជ្ជាទេ ដែលអាចបើកឱកាសស្វែងរកឧបាយដោះស្រាយ បញ្ហាចាស់ ឈឺ ស្លាប់ ដែលគ្របសង្កត់សព្វសត្វក្នុងសកលលោកបាន ។

តាមផ្លូវចិត្តសាស្ត្រ សេចក្តីប្រាថ្នារបស់ព្រះពោធិសត្វ អាចទុកជាការធម្មតាបាន ដោយសំអាងទៅលើហេតុផល ។ ការស្គាល់តែសេចក្តីសប្បាយ ពុំដែលស្គាល់សោះនូវទុក្ខ ស្គាល់តែសេចក្តីត្រេកត្រអាល ពុំស្គាល់សោះនូវព្រួយ ស្គាល់តែរូបល្អស្អាតបំព្រង ពុំស្គាល់សោះនូវរូបអាក្រក់ក្រៀវក្រអំអសុក ហើយថ្ងៃមួយស្រាប់តែទៅឃើញ ទៅប្រទះដំណើរដែលផ្ទុយជាច្រាសឡើងពីការដែលធ្លាប់ដឹង ធ្លាប់ឮ ធ្លាប់ស្នានភ្នាម គឺជាហេតុដែលអាចធ្វើឲ្យប្រែគំនិតសតិអារម្មណ៍ដូច្នេះបានពិតប្រាកដ ។

ផ្ទុយទៅវិញ បើព្រះបាទសិរីសុទ្ធោទន៍ជាព្រះបិតាពុំចាត់វិធានការដូចតាមនិទាននេះទេ ពុំបានបង្ខាំងព្រះរាជបុត្រទេ នោះប្រហែលជាព្រះសិទ្ធត្ថពុំបានសម្រេចព្រះទ័យទៅបួសឡើយ ព្រោះអារម្មណ៍ព្រះអង្គទាំងឡាយ

មិនស្រប:នឹងការបង្ហាប់ខ្ចាប់ ច្បាប់ដែលចិត្តសាស្ត្រ បានពោលថា « ទម្លាប់បង្កើតទូកាក្រោកផ្លុល » ។

សេចក្តីត្រង់នេះ ជាខមួយបង្ហាញឱ្យឃើញថា ព្រះពុទ្ធសាសនា ស្របទៅតាមហេតុនិយមដែលជាគោលនៃវិទ្យាសាស្ត្រ ។

ក្នុងអធ្រាត្រនៃថ្ងៃដែលព្រះអង្គចាកចោលព្រះនគរ គម្ពីរទាំងឡាយ បាននិទានថា ទ្រង់មានព្រះហឫទ័យ ចង់ឃើញព្រះរាជបុត្រមុនទើបចេញ ។ តែលុះចូលក្នុងព្រះក្រឡាបន្ទំព្រះអគ្គមហេសី ហើយបានឃើញព្រះរាជ-ទេពីដាក់ព្រះហស្តលើព្រះរាជកុមារ ក៏ទ្រង់ពុំហ៊ានចាប់ត្រកងព្រះរាជបុត្រវិញ ។

ដំណើរនេះជាហេតុចង្អុលឱ្យឃើញថា កាមតណ្ហា សេចក្តីស្រឡាញ់ស្អប់ ដែលជាចំណងនៃសត្វលោកទូទៅ ក៏ជាវត្ថុដែលបានចាប់ចងព្រះពោធិសត្វដែរ ។ នរណាឡើយនឹងអាចកាត់សេចក្តីលោភ សេចក្តីស្រឡាញ់ ទ្រព្យ រាជសម្បត្តិ កូន ប្រពន្ធ ញាតិ មិត្ត បានដោយងាយបែបនេះ ។

ហើយដំណើរដដែលនេះ ក៏ជាហេតុចង្អុលឱ្យឃើញថា ព្រះអង្គពុំមែនទៅបួសដោយសេចក្តីខ្លាច ពុំហ៊ានតស៊ូនឹងជីវភាពរបស់ខ្លួន នេះម្យ៉ាង នឹងឱ្យឃើញថា ព្រះអង្គពុំមែនជាអត្តវតបុគ្គល (personne égoïste) រត់ចោលកូនប្រពន្ធ សង្គមជាតិ ដើម្បីស្វែងរកសេចក្តីសុខ

ស្រួលតែម្នាក់ឯងនោះម្យ៉ាងទៀត ។

ផ្ទុយទៅវិញ ព្រះសិទ្ធត្ថជាព្រះវិញ្ញូជន ដែលពោរពេញទៅដោយបរទត្ថភាព (altruisme) ទ្រង់ចេញបព្វជ្ជា ដើម្បីស្វែងរកអនុត្តរសម្មាសម្ពោធិញ្ញាណ ពោលគឺលោកុត្តរធម៌ (ធម៌ដែលអាចឲ្យផុតពីការកើត ចាស់ ឈឺ ស្លាប់) នេះឯង ដើម្បីត្រាច់រកសារធម៌ សំរាប់ជួយស្រោចស្រង់មនុស្សលោកឲ្យផុតពីសេចក្ដីវិនាស កុំឲ្យលង់ក្នុងវដ្ដសង្សារ ។

ក្នុងរឿងបូជនីយកិច្ចនេះ យើងពុំអាចរកបាននូវព្រឹត្តិការណ៍ដ៏អស្ចារ្យមួយដែលប្រវត្តិសាស្ត្រសាកលលោក និងប្រវត្តិសាស្ត្រខ្មែរបានទុកជាព្រឹត្តិការណ៍កម្រនឹងជួបប្រទះក្នុងលោកសន្និវាសយើង ត្រង់ដែលព្រះបាទសម្ដេចព្រះនរោត្តម-សីហនុវរ្ម័ន ទ្រង់លះបង់រាជសម្បត្តិ មកជាសម្ដេចព្រះឧបយុវរាជ ។

សម្ដេចព្រះឧបយុវរាជ ដែលទ្រង់លាលែងពីដំណែងព្រះមហាក្សត្រ គឺពុំមែនសម្រេចទៅដោយមានព្រះហឫទ័យក្ដួលចង់ប្រាថ្នា នូវប្រយោជន៍ផ្ទាល់ព្រះអង្គទេ ។ ព្រះអង្គទ្រង់មានព្រះមេត្តាករុណាដល់ជាតិមាតុប្រទេស ចង់ឲ្យប្រជាពលរដ្ឋខ្មែរដែលទទួលនូវសេចក្ដីអាប់ឱន អន់ថយកិត្តិយសជាយូរឆ្នាំហើយ បានស្គាល់នូវសេចក្ដីសុខ សេចក្ដីចំរើន សមរម្យជាអារ្យជនក្នុងលោកនឹងគេ និងចង់ឲ្យចៀសផុតពីសេចក្ដីវិនាស

គ្រប់យ៉ាង មានសេចក្ដីវិនាសដែលកើតមកពីការខ្វះសាមគ្គីជាដើម ។

រីឯព្រះសង្ឃដែលជាមិស្សនៃព្រះពុទ្ធ ព្រះសង្ឃដែលជាដំណាងនៃព្រះបរមគ្រូ ដែលជាអ្នកទ្រទ្រង់ធម៌ ក៏ដូច្នេះដែរ ។

ការបួសគឺពិតជាការប្រព្រឹត្តទៅតាមគន្លងព្រះពុទ្ធោវាទ គោលគឺការលះបង់នូវកាមកិលេសតណ្ហា ការប៉ុនប៉ងឲ្យឃ្លាតចាកឆ្ងាយពីសេចក្ដីលោភ ដែលជាមូលហេតុនៃគន្លងទុក្ខគ្រប់ប្រការ ។

ការបួស គឺពិតជាធ្វើទៅដោយយល់ច្បាស់នូវបេសកកម្មនៃបព្វជ្ជា ។ កន្លងទៅមុន កុលបុត្រខ្មែរទាំងឡាយសឹងប្ដេជ្ញាសូមការចបព្វជ្ជាគ្រប់ៗរូប ពុំសូវមានចន្លោះរូបណាឡើយ ។ ដំណើរនេះ បានបិតមកជាប្រពៃណីខ្មែរអស់កាលដ៏យូរ ដោយបុព្វបុរសយើងទាំងឡាយបានទទួលយល់ដឹងច្បាស់ណាស់ថា « មាតាបិតាមានគុណូបការៈលើកូនធ្ងន់ពន់ប្រមាណ ហើយមធ្យោបាយដែលអាចទុកជាកតញ្ញូកតវេទិសមល្មម មានតែមធ្យោបាយមួយបែប គឺបព្វជ្ជា » ។

បព្វជ្ជាក៏ជាមធ្យោបាយម្យ៉ាងទៀត ដើម្បីស្វែងរកវិជ្ជា ដើម្បីអប់រំកាយវាចាចិត្តក្រោមការដឹកនាំនៃព្រះឧបជ្ឈាយ៍អាចារ្យ ។

អាស្រ័យហេតុទាំងនេះ សាមណេរនិងភិក្ខុជាច្រើន កាលបើបានសូត្ររៀនសមល្មមហើយ ព្រមដោយសេចក្ដីកោតក្រែង ការស្អុះស្អាប់រត់តាមពាន់ ក៏វិលត្រឡប់មកជាគ្រហស្ថវិញ ប្រកបដំរកាពជា

ពលរដ្ឋយ៉ាងថ្លៃថ្នូរពេញសមត្ថភាព ។

ពុទ្ធបរិស័ទឯទៀត ដោយសទ្ធាជ្រះថ្លាយ៉ាងមុតមាំចំពោះព្រះធម៌នៃព្រះពុទ្ធ ក៏ឋិតនៅជាភិក្ខុរហូតទល់នឹងអស់ព្រះជន្មាយុតែម្តង កសាងដោយម៉ឺងម៉ាត់នូវទាន សីល ភាវនា និងសីល សមាធិ បញ្ញា ។

ព្រះអង្គជាអរិយបុគ្គល (បុគ្គលប្រាជ្ញថ្លាតិច) ជាព្រះឧបជ្ឈាយ៍អាចារ្យស្មោះស្ម័គ្រជាទីពឹងផ្អែក ជាទីស្រឡាញ់ទីជាទីគោរពនៃឧបាសកឧបាសិកា កុលបុត្រ កុលធីតាខ្មែរទូទៅ ។

ក្នុងបច្ចុប្បន្នកាលនេះ ប្រពៃណីដូចបានរៀបរាប់មក ក៏គង់វង់នៅដូចដើម មានការប្រែប្រួលតែត្រង់ព្រះភិក្ខុសង្ឃទាំងឡាយ ក្រោមការដឹកនាំនៃសម្តេចព្រះសង្ឃនាយកទាំងពីរព្រះអង្គ បានគោរពដោយហ្មត់ចត់លើសដើម និងដោយសទ្ធាស្មោះពីដួងព្រះទ័យ ចំពោះព្រះពុទ្ធោវាទមានព្រះវិន័យជាដើម និងបានយល់ជាក់នូវបេសកកម្មដ៏ថ្លៃថ្លាចំពោះជាតិ ព្រះពុទ្ធសាសនានិងព្រះមហាក្សត្រ ។ ពុទ្ធិកសិក្សាក៏បានរៀបចំសមតាមសម័យ អាចធ្វើឱ្យព្រះពុទ្ធបេសកសមណៈទាំងឡាយ មានសមត្ថភាពបរិបូណ៌ក្នុងការផ្សាយព្រះធម៌ដ៏ឧត្តម ក្នុងការផ្តល់នូវការអប់រំ ដល់អ្នកប្រាជ្ញាសុខចំរើនទាំងឡាយ ។

# ព្រះពុទ្ធសាសនាជាសាសនានាំទៅកាន់សេចក្ដីសុខ

លោក ភិយ-ប៊ុក រៀបរៀង

---

*ព្រះពុទ្ធសាសនា ជាសាសនានាំសេចក្ដីសុខមកឲ្យ :*

១- ចំពោះខ្លួន;

២- ចំពោះគ្រួសារ,

៣- ចំពោះជាតិ,

៤- ចំពោះសកលលោក ។

## អធិប្បាយ

### ១- ព្រះពុទ្ធសាសនានាំសេចក្ដីសុខមកឲ្យចំពោះខ្លួន :

*អ្នកកាន់ព្រះពុទ្ធសាសនា ឬអ្នកដែលស័ក្ដិព្រះពុទ្ធសាសនា ដែលបានប្រតិបត្តិតាមព្រះពុទ្ធោវាទ មានធ្វើទាន រក្សាសីលជាដើម តែងបានសេចក្ដីសុខចំពោះខ្លួន ។*

*ទាន គឺការធ្វើអំណោយ ចំពោះស្មូមយាចក ចំពោះអ្នកក្រីក្រលំបាកគោកយ៉ាក ចំពោះសមាគម ចំពោះក្រុម ចំពោះព្រះសង្ឃជាដើម ឈ្មោះថា ជាការសម្រាលនូវសេចក្ដីទុក្ខលំបាក ចំពោះសត្វលោក ។ ការដែលធ្វើបន្ធូរទុក្ខរបស់អ្នកដទៃឲ្យធូរថយចុះ ឈ្មោះថា ឲ្យសុខដល់អ្នកដទៃ ។ អ្នកណាឲ្យសុខដល់អ្នកដទៃ អ្នកនោះនឹងបាន*

សុខរំពោះខ្លួនវិញ, សមដូចពុទ្ធភាសិតក្នុងអង្គុត្តរនិកាយ បញ្ចកនិបាត ទានវគ្គថា :

សុខស្ស ទាតា មេធាវី សុខំ សោ អធិគច្ឆតិ

ប្រែថា: អ្នកមានប្រាជ្ញា ជាអ្នកឲ្យនូវសេចក្ដីសុខ (ដល់អ្នកឯទៀត ហើយ) រមែងបាននូវសេចក្ដីសុខ (នោះមកខ្លួនវិញ) ។

មិនតែប៉ុណ្ណោះ អ្នកធ្វើទាន រមែងចំរើនដោយបុណ្យជាយ៉ាងក្រៃពេក ព្រមទាំងអាយុ វណ្ណៈ យស កេរ្ដិ៍ឈ្មោះ សុខ និងកម្លាំងដ៏លើស ។ អ្នកធ្វើទាន រមែងជាទីស្រឡាញ់ ជាទីគាប់ចិត្តនៃជនទាំងឡាយដ៏ច្រើន ។

ព្រោះហេតុដូច្នេះ, អ្នកធ្វើទាន តែងមានចិត្តភក្ដី កិត្តិនាមល្បីខ្ចរខ្ចាយទៅគ្រប់ទិសទាំង៨, ដូចសម្ដេចព្រះឧបយុវរាជ ទ្រង់បានស្ថាបនានូវក្រុមសង្គហជាតិ ដើម្បីទ្រង់ធ្វើព្រះអំណោយ ចំពោះអ្នករងគ្រោះថ្នាក់ដោយអគ្គិភ័យ ចោរភ័យ ឧទកភ័យ និងចំពោះសេចក្ដីទុក្ខគ្រប់យ៉ាង របស់ជនតូចតាចជាដើម ។ល។ ទ្រង់បានបំពេញព្រះរាជបេសកកម្មព្រមទាំងធ្វើជាតិឲ្យបានឯករាជ្យ ដោយសម្បូណ៌ ឧបត្ថម្ភព្រះពុទ្ធសាសនាឲ្យរុងរឿងចំរើន បានជាព្រះកិត្តិនាមរបស់ព្រះអង្គលេចឮខ្ទរទៅដល់ពលរដ្ឋខ្មែរគ្រប់រូបក្នុងព្រះរាជអាណាចក្រទាំងមូល ព្រមទាំងនានាប្រទេសពេញសកលលោក ។ ដោយហេតុនេះហើយ បានជាពលរដ្ឋខ្មែរ មានសេចក្ដីស្នេហាស្រឡាញ់ព្រះអង្គ ថ្វាយព្រះនាមព្រះអង្គថា ព្រះបិតាឯករាជ្យ

ជាតិ ៗ បើទ្រង់ស្ដេចយាងទៅកន្លែងណា ប្រជារាស្ត្រខ្មែរទាំងប្រុសស្រី ក្មេង ចាស់ អ្នកមាន-អ្នកក្រ តែងតែចាំទទួលគោរពចំពោះព្រះអង្គ មានខ្លះអុជទៀនធូប ធ្វើសក្ការបូជាព្រះអង្គ, ទុកព្រះអង្គជាព្រះមហាវីរបុរសនៃប្រជាជាតិខ្មែរទាំងមូល ៗ នេះមិនមែនមកពីអ្វី គឺមកពីទ្រង់មានព្រះមហាករុណាទិគុណ ទ្រង់ធ្វើព្រះអំណោយផលចំពោះមុខ គឺថាអ្នកណាមានទុក្ខព្រះអង្គទ្រង់ជួយសម្រាលទុក្ខទៅ, អ្នកណាមានភ័យ ទ្រង់ព្រះពិចារណាលៃលកធ្វើភ័យនោះឲ្យបាត់ទៅ ដូចជាទ្រង់កសាងគេហដ្ឋានប្រទានដល់អ្នកក្រីក្រ ឬសាងសាលារៀន ឬទ្រង់ចូលព្រះរាជកុសលសាងវត្តអារាម ក្ដី ព្រះវិហារជាដើម; ទាំងអស់នេះ ធ្វើឲ្យព្រះអង្គមានព្រះអាយុ ព្រះវណ្ណៈ ព្រះយស ព្រះកេរ្តិ៍ឈ្មោះ សុខទឹងកម្លាំងដ៏លើសលុប, សមដូចពុទ្ធភាសិតក្នុងខុទ្ទកនិកាយ ឥតិវុត្តក: សុត្តន្តបិដកថា:

អគ្គស្មឹ ទានំ ទទតំ អគ្គំ បុញ្ញំ បវឌ្ឍតិ
អគ្គំ អាយុ ច វណ្ណោ ច យសោ កិត្តិ សុខំ ពលំ ៗ

ប្រែថា បុណ្យដ៏ប្រសើរលើស រមែងចំរើនដល់ពួកជនអ្នកឲ្យទានក្នុងវត្ថុ (អ្នកទទួល) ដ៏ប្រសើរលើស, អាយុ វណ្ណៈ យស កេរ្តិ៍ឈ្មោះ សុខនឹងកម្លាំងដ៏ប្រសើរលើសក៏ចំរើនដែរ ៗ

ព្រោះ ហេតុដូច្នេះ ទានដែលបុគ្គលធ្វើដោយល្អចំពោះជនដទៃតែងនាំសុខមកឲ្យចំពោះខ្លួន ៗ

ចំណែកសីលនោះ ក៏ឲ្យសុខចំពោះខ្លួនដែរ ព្រោះថា អ្នកមានសីល ៥ គឺ ការមិនសម្លាប់សត្វ ១, ការមិនលួចទ្រព្យសម្បត្តិរបស់អ្នកដទៃ ១, ការមិនប្រព្រឹត្តកន្លងក្នុងកាម ១, ការមិនភូតភរកុហក ១, ការមិនសេពសុរានិងមេរ័យ ១ ៗ សីលទាំង ៥ នេះ ជាករណីយកិច្ចរបស់ឧបាសក ឧបាសិកាទាំងឡាយ ៗ បើពុទ្ធមាមកជនបានប្រព្រឹត្តប្រតិបត្តិតាមព្រះពុទ្ធោវាទនេះពេញលក្ខណៈហើយ ក៏អាចនឹងចៀសវាងនូវកំហុសក្នុងលោកិយ មានការក្តីក្តាំ ការឈ្លោះទាស់ទែងគ្នា ការទទួលទណ្ឌកម្ម មានការជាប់គុកច្រវាក់ខ្នោះឃ្នាងជាដើម ៗ ការធ្វើខ្លួនឲ្យផុតពីទណ្ឌកម្មខាងផ្លូវលោកនេះឯង ហៅថាបានសុខចំពោះខ្លួន ៗ

សីលនេះជាទីពឹងផ្អែករបស់កុលបុត្រទាំងឡាយក្នុងព្រះពុទ្ធសាសនា ជាទឹកដ៏បរិសុទ្ធស្អាត សម្រាប់ជម្រះនូវមន្ទិលរបស់សត្វទាំងឡាយ ក្នុងលោកនេះ ជាគន្ធជាតដ៏ត្រជាក់ក្រៃលែង អាចរម្ងាប់នូវសេចក្តីក្រហល់ក្រហាយរបស់សត្វទាំងឡាយបាន ជាក្លិនដែលអាចបក់ទៅបាន ទាំងបណ្តោយខ្យល់ ទាំងច្រាសខ្យល់ ជាជណ្តើរកែវសម្រាប់ឡើងទៅកាន់ឋានសួគ៌ ឋានព្រហ្ម ជាមាគ៌ាដ៏វិសេសវិសាល សម្រាប់ទៅកាន់លោកុត្តរភូមិគឺព្រះនិព្វាន ៗ សីលជាមូលដ្ឋាននៃគុណទាំងឡាយ មានអានិសង្សអាចឲ្យសុខចំពោះខ្លួនមែនពិត ៗ

ត្រង់បទនេះ មានសំអាង ដូចពុទ្ធភាសិតគាថាមួយបទក្នុង

សុត្តន្តបិដក ខុទ្ទកនិកាយ ថេរគាថា ថា :

សីលំ សេតុ មហេសក្ខោ សីលំ គន្ធោ អនុត្តរោ

សីលំ វិលេបនំ សេដ្ឋំ យេន វាតិ ទិសោ ទិសំ ។

ប្រែថា សីលជាស្ពានដ៏មានសក្តិ សីលជាក្លិនដែលមិនមានក្លិនដទៃប្រសើរជាង សីលជាគ្រឿងលាបលនយ៉ាងប្រសើរខ្ចរខ្ចាយទៅគ្រប់ទិស ។

ដោយហេតុនេះហើយ បានជាថាទាននឹងសីល បើអ្នកណាបានបំពេញហើយ រមែងនាំសុខមកឱ្យចំពោះខ្លួនមែនពិត ។

ក្រៅពីនេះនោះមានធម៌ឯទៀត គឺ កតញ្ញូតាធម៌សេចក្តីដឹងចំពោះគុណអ្នកដ៏មានគុណ មានមាតាបិតាគ្រូឧបជ្ឈាយ៍អាចារ្យ នឹងសច្ចធម៌ សប្បុរសធម៌ ។ល។ ក៏នាំសុខមកឱ្យចំពោះខ្លួនដែរ ។ ព្រោះហេតុនេះបានជាថាព្រះពុទ្ធសាសនាជាសាសនានាំសុខមកឱ្យចំពោះខ្លួន ។

## ២- ព្រះពុទ្ធសាសនា នាំសេចក្តីសុខមកឱ្យចំពោះគ្រួសារ :

គ្រួសារគឺមាតាបិតា បុត្រធីតា កូនប្រសាប្រុស កូនប្រសាស្រី ជីដូន ជីតា ក្មួយ មា មីង ជាដើម ។ អ្នកទាំងអស់គ្នីគ្រួសារត្រូវមានករណីយកិច្ច ដែលត្រូវបំពេញទៅវិញទៅមក គឺស្វាមីចំពោះភរិយា មាតាបិតាចំពោះបុត្រធីតាជាដើម ។ ដូចព្រះពុទ្ធោវាទ

ក្នុងសិង្គាលោវាទសូត្រ ដែលព្រះមានព្រះភាគទ្រង់ត្រាស់សំដែងចំពោះសិង្គាលមាណពថា :

ករណីយកិច្ចដែលមាតាបិតា ត្រូវទំនុកបំរុងបុត្រធីតា មានស្ថាន ៥ គឺ

ក) ហាមមិនឲ្យបុត្រធីតាប្រព្រឹត្តអំពើទុច្ចរិត;

ខ) ទូន្មានបុត្រធីតាឲ្យតាំងនៅក្នុងកុសលធម៌;

គ) ទូន្មានបុត្រធីតាឲ្យសិក្សាសិល្បៈវិជ្ជា;

ឃ) រកភរិយាឲ្យបុត្រ ឬស្វាមីឲ្យធីតា តាមសមគួរ;

ង) ចែកទ្រព្យសម្បត្តិដល់បុត្រធីតា តាមសមគួរ ។

បើមាតាបិតា បានប្រព្រឹត្តករណីយកិច្ចទាំង៥ស្ថាន ចំពោះបុត្រធីតា តាមព្រះពុទ្ធឱវាទខាងលើនេះ ឈ្មោះថា មាតាបិតានាំសេចក្តីសុខមកឲ្យចំពោះបុត្រធីតា ហើយគ្រួសារនេះ នឹងបានសេចក្តីសុខជាកិយ្យោភាពតទៅ ។

លំដាប់តមក ព្រះអនាវរណញ្ញាណទ្រង់ទូន្មានសិង្គាលមាណពថា :

មាតាបិតាទុកជាបុរត្ថិមទិស ( ទិសបូព៌ ) គឺ បុត្រធីតាគប្បីទំនុកបំរុងដោយស្ថាន ៥ គឺ

ក ) លោកបានចិញ្ចឹមខ្លួនមកហើយ ត្រូវខ្លួនចិញ្ចឹមលោកវិញ ;

ខ ) ជួយធ្វើកិច្ចការរបស់លោក :

គ) ទំនុកបំរុងវង្សត្រកូលមិនឲ្យសាបសូន្យ ;

ឃ) ប្រតិបត្តិខ្លួនឲ្យសមគួរជាអ្នកទទួលមតិក ;

ង) កាលបើលោកធ្វើមរណកាល ត្រូវធ្វើបុណ្យឧទ្ទិសផលជូនលោក ។

ភរិយាទុកជាបច្ឆិមទិស (ទិសបស្ចិម) គឺ ស្វាមីគប្បីទំនុកបំរុងដោយស្ថាន ៥ គឺ

ក) រាប់អានលើកមុខជាភរិយា;

ខ) មិនមើលងាយ;

គ) មិនប្រព្រឹត្តកន្លងចិត្ត គឺមិនក្បត់ចិត្តភរិយា;

ឃ) ប្រគល់ភារៈជាធំក្នុងផ្ទះឲ្យ;

ង) ឲ្យគ្រឿងតែងខ្លួន ។

ភរិយាគប្បីប្រតិបត្តិស្វាមីដោយស្ថាន ៥ គឺ

ក) ចាត់ការងារដោយល្អ;

ខ) សង្គ្រោះញាតិខាងស្វាមីដោយល្អ;

គ) មិនប្រព្រឹត្តកន្លងចិត្តស្វាមី គឺមិនក្បត់ចិត្តប្តី,

ឃ) រក្សាទ្រព្យដែលស្វាមីរកបានមក,

ង) មិនខ្ជិលច្រអូសក្នុងកិច្ចការទាំងពួង ។

ទាសកម្មករទុកជាហេដ្ឋិមទិស (ទិសខាងក្រោម) គឺ ចៅហ្វាយនាយ

គប្បីទំនុកបំរុងដោយស្ថាន ៥ គឺ

ក) ចាត់ការងារឲ្យធ្វើតាមសមគួរដល់កម្លាំង;

ខ) ឲ្យភោជនាហារនិងរង្វាន់;

គ) ព្យាបាលក្នុងវេលាមានជម្ងឺ;

ឃ) ចែកភោជនាហារដ៏មានឱជារសប្លែក ៗ ឲ្យបរិភោគ,

ង) បើកឲ្យសប្បាយក្នុងកាលគួរ ៗ

ទាសកម្មករគប្បីប្រតិបត្តិចៅហ្វាយនាយដោយស្ថាន ៥ គឺ

ក) ក្រោកឡើងធ្វើការងារមុនចៅហ្វាយនាយ;

ខ) លែងធ្វើការងារក្រោយចៅហ្វាយនាយ;

គ) កាន់យកតែរបស់ដែលចៅហ្វាយនាយឲ្យ;

ឃ) ធ្វើការងារដោយយកចិត្តទុកដាក់,

ង) នាំគុណសម្បត្តិរបស់ចៅហ្វាយនាយៈទៅសរសើរក្នុងទីដទៃ ៗ

ព្រះពុទ្ធោវាទចំពោះសិង្គាលមាណពនេះ បើគ្រួសារនីមួយ ៗ យកទៅប្រព្រឹត្តប្រតិបត្តិតាម មុខជានឹងបានសេចក្ដីសុខ ចំរើន ជាពិតប្រាកដ, ព្រោះថា ព្រះពុទ្ធោវាទនេះ ព្រះអង្គទ្រង់ចែងទៅតាមអធ្យាស្រ័យលក្ខណៈចិត្ត ចរិត និស្ស័យ គុណសម្បត្តិ គុណវិបត្តិ មនោសញ្ចេតនា ៗលៗ នៃមនុស្សទាំងលើ បានជាថា ករណីយកិច្ចដែលមនុស្សទាំងឡាយត្រូវបំពេញនោះនឹងមានផល មានប្រយោជន៍ពិត ៗ ដោយ

ហេតុនេះហើយ បានជាថា ព្រះពុទ្ធសាសនាជាសាសនានាំសុខ មកឱ្យចំពោះគ្រួសារ ។

## ៣- ព្រះពុទ្ធសាសនានាំសេចក្ដីសុខមកឱ្យចំពោះជាតិ:

នៅប្រទេសកម្ពុជាយើង មានព្រះភិក្ខុសង្ឃជាធម្មកថិក តែងនិមន្តទៅគ្រប់និគមជនបទ ដើម្បីនឹងសំដែងធម៌ទេសនាចំពោះមហាជនខ្មែរ ពន្យល់បំភ្លឺពុទ្ធសាសនិកជន ឱ្យប្រព្រឹត្តប្រតិបត្តិតាមព្រះពុទ្ធោវាទ, ឱ្យមានសាមគ្គីភាព ដូច្នេះឈ្មោះថាលោកនាំសុភមង្គល និងសេចក្ដីសុខមកឱ្យពលរដ្ឋខ្មែរ ។ ម្យ៉ាងទៀត គោលបំណងនៃពុទ្ធសាសនា គឺ វិសិដ្ឋភាពជាមនុស្សជាតិ១, ការលើកនឹងសំអាតទឹកចិត្ត ១, ការស្វែងរកសុភមង្គលនិងសេចក្ដីស្ងប់១, ការប្រយុទ្ធនឹងរោគាពាធនិងទុគ្គតភាព១, ការកិលទៅជិតព្រះនិព្វានបើមិនទាន់បានដល់១ ។ បើជនជាតិខ្មែរប្រតិបត្តិទៅតាមគោលបំណងនៃព្រះពុទ្ធសាសនានេះ, ព្រះពុទ្ធ-សាសនា នឹងបានឡើងទៅកាន់វឌ្ឍនភាព ជាតិខ្មែរនឹងបានជួបប្រទះនូវសុភមង្គល និងសម្បូណ៌ភាពពុំខាន, ។ មិនតែប៉ុណ្ណោះ អ្នកដែលប្រតិបត្តិតាមព្រះពុទ្ធោវាទ នឹងបានជួបប្រទះនូវលោក យស សេចក្ដីសរសើរគ្រប់យ៉ាងមិនខាន សមដូចពុទ្ធភាសិតក្នុងខុទ្ទកនិកាយធម្មបទថា :

ឧដ្ឋានវតោ សតីមតោ សុចិកម្មស្ស និសម្មការិនោ

សញ្ញតស្ស ច ធម្មជីវិនោ អប្បមត្តស្ស យសោភិវឌ្ឍតិ ។

ប្រែថា យសតែងចំរើនដល់អ្នកមានព្យាយាមរឿសរៃ១, អ្នកមានស្មារតី១, អ្នកមានការងារស្អាត១ អ្នកមានប្រក្រតីពិចារណារួចទើបធ្វើ១ អ្នកប្រុងប្រយ័ត្ន១ អ្នកមានប្រក្រតីរស់នៅដោយធម៌១ អ្នកមិនប្រមាទ១ ។

ពុទ្ធសាសនាមានពុទ្ធភាសិតជាអនេកប្បការ តែខ្ញុំគ្រាន់តែយកគាថាមួយបទមកចុះក្នុងទីនេះ ដើម្បីបង្ហាញបងប្អូនរួមជាតិថា ការប្រព្រឹត្តប្រតិបត្តិទៅតាមពុទ្ធភាសិតនេះ អាចបនាបុគ្គលទីមួយ ៗ ឲ្យមានគុណធម៌ សីលធម៌ដ៏ឧត្តុង្គឧត្តម បើបុគ្គលចំរើនហើយ ជាតិក៏ចំរើនដែរ ។

ដើម្បីនឹងឲ្យជនជាតិខ្មែរចេះវិជ្ជាខាងព្រះពុទ្ធសាសនា មានតែព្រះសង្ឃនេះឯង ជាមគ្គុទ្ទេសក៍អ្នកណែនាំពន្យល់បំភ្លឺពួកពុទ្ធបរិស័ទទាំងឡាយឲ្យដើរតាមពីក្រោយ ៗ ពិតមែនតែព្រះសង្ឃទាំងឡាយនេះមិនមែនជាព្រះខីណាស្រព បិតនៅជាសម្មតិសង្ឃនៅឡើយ ក៏គង់ការទេសនារបស់លោក ជាទេសនាល្អមធ្យតដោយយកពុទ្ធភាសិតជាមូលដ្ឋាន ។ ឧបាសកឧបាសិកាណា បានស្ដាប់ធម៌ទេសនានេះហើយ ត្រង់សេចក្ដីណាដែលងឿងឆ្ងល់ បានសាកសួរពន្យល់សព្វគ្រប់ហើយ យកពុទ្ធភាសិតដែលស្ដាប់បានយល់ច្បាស់លាស់នោះ មកអនុវត្តចំពោះជីវភាពសព្វៗថ្ងៃ ធ្វើជាមូលដ្ឋាននៃការប្រព្រឹត្តប្រតិបត្តិ, ឧបាសក ឧបាសិកានោះ ឈ្មោះថា

បានរួចខ្លួនឲ្យផុតពីអបាយភូមិទាំង៤ និងផុតពីអកុសលទាំងឡាយ បានតាំងអាត្មានៅក្នុងសង្គមដោយប្រពៃ ដូចបានយកថ្មមួយដុំ មកសាងគេហដ្ឋានជាតិ គឺប្រទេសកម្ពុជាឲ្យបានមុតមាំឡើង ។ ព្រោះហេតុដូច្នេះបានជាថាព្រះពុទ្ធសាសនានាំសុខមកឲ្យចំពោះជាតិ ។

## ៤- ព្រះពុទ្ធសាសនានាំសេចក្ដីសុខមកឲ្យចំពោះសកលលោកៈ

សម្ដេចព្រះឧបយុវរាជ ទ្រង់មានព្រះបន្ទូលទវ្គ ក្នុងព្រះរាជសុន្ទរកថា ដែលទ្រង់ថ្លែងក្នុងឱកាសបើកការសិក្សាពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ និងសម្ពោធគ្រឹះស្ថានព្រះសីហនុ កាលពីថ្ងៃទី១០មិថុនា១៩៥៩ ថា:

" ទោះបីនៅក្នុងសម័យបរមាណូយើងនេះក៏ដោយ ព្រះពុទ្ធសាសនាក៏នៅតែមានឋិរភាពនឹងជាក់ស្ដែងដដែល ៗ ពិភពលោកសព្វថ្ងៃដែលឋិតនៅក្នុងការព្រួយបារម្ភដោយអនាគតមិនភ្លឺស្វាង បើប្រសិនជាយកធម៌ព្រះពុទ្ធមកពិចារណា អាចនឹងដោះស្រាយអស់ទាំងបញ្ហាគ្រប់យ៉ាងរបស់ខ្លួនបាន ទុកជាបញ្ហានោះស្មុគ្រស្មាញយ៉ាងណាក៏ដោយ ។ នេះហើយដែលជាសេចក្ដីជឿស៊ប់នៃប្រជាជាតិ ដែលមានចំនួនកាន់តែច្រើនឡើងក្នុងលោក សូម្បីតែអ្នកកាន់សាសនាដទៃ ក៏ចាប់ផ្ដើមសិក្សាលទ្ធិព្រះពុទ្ធសាសនាដែរ ។ ស្ទើរតែគ្រប់ប្រទេសក្នុងពិភពលោក មានអ្នករាប់អាននឹងសមាគម អ្នកពិនិត្យស្រាវជ្រាវខាងធម៌នៃព្រះពុទ្ធអង្គ " ។

មែនពិត ព្រះរាជបន្ទូលនៃសម្ដេចសហជីវិន ដែលទ្រង់ថ្លែងខាងលើនេះ គឺទ្រង់បញ្ជាក់ឲ្យឃើញថា ព្រះពុទ្ធសាសនា ជាសាសនាដោះស្រាយនូវបញ្ហាពិភពលោក ដែលឋិតនៅក្នុងការតានតឹងនិងព្រួយបារម្ភ ឲ្យរួចដោះភាពការតានតឹងនិងព្រួយបារម្ភបាន បើពិភពលោកបានយកទៅពិចារណា នៅពិសោធ នៅកាន់តាម ដោយម៉ឺងម៉ាត់ ។

ព្រះបន្ទូលនេះ មានអត្ថន័យគម្ភីរភាពជ្រាលជ្រៅ ត្រូវតាមគោលពុទ្ធភាសិតពិតមែន ព្រោះថាព្រះពុទ្ធសាសនា ជាសាសនាប្រដៅឲ្យលះបង់អកុសលធម៌ មានទិដ្ឋិ មានៈ លោភៈ ទោសៈ មោហៈ ជាដើម ឲ្យចំរើនកុសលធម៌ មានអហិង្សា និងមេត្តាករុណាជាដើម បើមហាអំណាចក្នុងពិភពលោកបានយកព្រះពុទ្ធសាសនាទៅត្រិះរិះពិចារណា នៅពិសោធ នៅកាន់តាម ព្រមទាំងបានលះបង់អកុសលធម៌ ចំរើនកុសលធម៌ទាំងនោះ តាមគន្លងដែលព្រះពុទ្ធសាសនាប្រៀនប្រដៅហើយ មុខជាលែងប្រកាន់គ្នា ស្រឡាញ់រាប់អានយោគយល់គ្នាទៅវិញទៅមក ឥតទាស់ទែងខ្វែងគំនិតគ្នា ឥតធ្វើបង្ក្រាបទីវគ្នាឡើយ កាលបើដូច្នេះ លោកសន្និវាសនេះ មុខជានឹងទៅជាឋានសួគ៌មួយ មានតែសេចក្ដីសុខ សេចក្ដីចំរើន ឥតទុក្ខព្រួយជាពិតប្រាកដពុំខាន ។

ព្រោះហេតុនោះ បានជាថា ព្រះពុទ្ធសាសនាជាសាសនានាំសេចក្ដីសុខមកឲ្យចំពោះសកលលោក ។

# សំនាំដើម

## នៃគម្ពីរមធុរសវាហិនី

គម្ពីរមធុរសវាហិនីនេះ មុនដំបូងព្រះអរហន្តតាំងឡាយនៅមហាវិហារក្នុងលង្កាទ្វីប បានរៀបរៀងជាភាសាសីហឡៈ ។

ក្រោយមក ព្រះរដ្ឋបាលត្ថេរ នៅវត្តបរិវេណ បានប្រែពីភាសាសីហឡៈមកជាភាសាបាលី ។

ដល់មក ព.ស. ២៤៧៦ គ.ស. ១៩៣៤ សម្ដេចព្រះធម្មលិខិត លុី–ឯម ឧត្តមប្រឹក្សា គណៈមហានិកាយ ចៅអធិការវត្តលង្កា ក្រុងភ្នំពេញ កាលនៅជាព្រះសិរីសម្មតិវង្ស ចាងហ្វាងសាលាបាលីជាន់ខ្ពស់នៅឡើយ បានប្រែអំពីភាសាបាលីមកជាភាសាខ្មែរ រៀបរៀងជាសេចក្ដីទេសនា ហើយបានយកទៅដាក់តំកល់ទុកនៅមន្ទីរពុទ្ធសាសនបណ្ឌិត្យ ដើម្បីឲ្យបោះពុម្ពផ្សាយ ជាសាធារណប្រយោជន៍ដល់សិក្ខាកាមកុលបុត្រទូទៅ, តែពេលនោះ មន្ទីរពុទ្ធសាសនបណ្ឌិត្យពុំទាន់មានឱកាសបោះពុម្ពផ្សាយបាននៅឡើយ ។

លុះដល់មក ព.ស ២៥០៣ គ.ស. ១៩៦០ លោកអគ្គលេខាធិការពុទ្ធសាសនបណ្ឌិត្យ បានសុំឲ្យខ្ញុំពិនិត្យមើល បើឃើញថាគួរ នឹងចាត់ការបោះពុម្ពផ្សាយ ។ ខ្ញុំក៏បានយកចិត្តទុកដាក់ពិនិត្យកែសម្រួលពាក្យពេចន៍ខ្លះ ដោយសេចក្ដីសោមនស្ស ដើម្បីឲ្យគម្ពីរនេះបានរីកសាយជាសាធារណប្រយោជន៍តទៅ ។

វត្តលង្កា ក្រុងភ្នំពេញ ថ្ងៃ ១ មករា ព.ស. ២៥០២ គ.ស. ១៩៦០

ព្រះញាណកោសល ញាណ–ឈឹន

# មធុរសវាហិនី

សម្ដេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

## ភាគ ៣ ជង

មធុរសវាហិនី វណ្ណនា ធម្មានុសន្ធិ ព្រះសទ្ធម្មទេសនានេះ ទើបនឹងបានជាបុញ្ញាបរៈ លំដាប់រៀបរៀង ជាដំណាលសេចក្ដីតាំងពីធម្មកថិក សម្ដែងមកអំពីមុនកំនេ, គម្ពីរឯណាដែលប្រដាប់ដោយរឿងនិទានមួយៗ គត់ មានអត្ថសេចក្ដីពេះផ្អែមល្ហែម មានឈ្មោះថា "មធុរសវាហិនី" ខ្ញុំនឹងពណ៌នានូវសេចក្ដីនៃគម្ពីរនោះក្នុងកាលឥឡូវនេះ ។

ព្រះអដ្ឋកថាចារ្យ កាលដែលលោកប្រារព្ធសម្ដែងគម្ពីរឈ្មោះ មធុរសវាហិនីដ៏មានធម្មរសនឹងអត្ថរសមានខ្ទឹមសារដ៏វិចិត្រ ដោយន័យដ៏ឧត្ដមនេះ លោកបានប្រកាសបទរតនត្តយប្បណាម តាមសេចក្ដីអធិប្បាយនៃបុញ្ញាវារ្យតាំងឡាយពីបុរាណ ហើយទើបសម្ដែងនូវពុទ្ធរតនប្បណាមជាមុន ដោយបទព្រះគាថាដូច្នេះថា:

សត្តប្បសន្នចរណំ សរណំ ជនានំ
ព្រហ្មាទិមោលិមណិរំសិសមាវហន្តំ
បង្កេរុហាភមុទុកោមលចារុវណ្ណំ
វន្ទាមិ ចក្កវរលក្ខណសន្និធានំ ។

អធិប្បាយថា "ស្នាមព្រះបាទទាំងគូដ៏ប្រសើរឯណា របស់ព្រះបរមគ្រូ

សាហ្គរ្ទីរៈលោក ព្រមទាំងទេវលោក ជាតែផលមនុស្សនិងទេវតា ទាំងឡាយបូជាបរសើហើយ ជាទីពឹងពួនរោងជ្រក នៃជនទាំងជន ទាំងឡាយ ជាទំនាំមកនូវផ្កាឈូកដ៏មានត្រួតទន់ល្អនក្រៃពេក មាន ពណ៌ដូចមាស រុងរឿងប្រាកដស្មើដោយរស្មីនៃកែវមណី ដ៏ប្រដាប់នៅ កន្និកំពូលមកុដនៃទេវតាទាំងឡាយមានមហាព្រហ្មជាដើម ប្រកបដោយ លក្ខណៈកន្ទិចក្រដ៏ប្រសើរពេញដោយអាការទាំងពួង មានទាំងជុំទីងខ្នង កង់ដ៏រុងរឿងដោយរស្មីមួយពាន់ មានប្រាកដក្នុងកណ្ដាលផ្ទៃនៃព្រះបាទ ទាំងគូជាអស្ចារ្យ ខ្ញុំព្រះករុណា សូមបង្អោនអង្គលើកកំបង់អញ្ជលីថ្វាយ បង្គំចំពោះព្រះបាទទាំងគូរបស់ព្រះសាស្ដាចារ្យនោះ យ៉ាងនេះឯង ។

ព្រះអដ្ឋកថាចារ្យ បានធ្វើពុទ្ធរតនបណាមចប់ស្រេចហើយ ទើប សម្ដែងធម្មរតនបណាមតទៅទៀត ដោយបទព្រះគាថាដូច្នេះថា:

សិទ្ធំ ជនេន ចិរកាលមតន្ទិតេន
យម្ភាវិតា សមធិគច្ឆតិ ខេមមគ្គំ
យោ គាប្បរុក្ខរុចិធានធមណីវការី
តំ ធម្មមគ្គមសមំ បណមាមិ និច្ចំ ។

អធិប្បាយថា ព្រះវរយត្តធម៌ ព្រមទាំងព្រះនព្វលោកុត្តរធម៌ឯណា គឺប្រជុំជនមិនខ្ជិលប្រអូសខំទស្សព្វហ៍ចំរើនហើយ ដ៏សម្រេចអស់កាលដ៏យូរ ព្រះធម៌នោះសោត អាចញ៉ាំងប្រជុំជនឲ្យសម្រេចនូវសេចក្ដីសុខក្សេម

កក្រុទ្ធជាប្រមាណពិត ព្រះបរិយត្តិធម៌ ព្រមទាំងព្រះនព្វលោកុត្តរឯណា ដ៏រុងរឿង អាចឲ្យនូវប្រយោជន៍ទាំងពួងដល់ប្រជុំជនតាមប្រាថ្នាបាន បើដូចជាដើមកល្បព្រឹក្ស ពុំនោះសោត ដូចជាកែវមណីដ៏អាចឲ្យនូវសេចក្តីរុងរឿង ទឹងសេចក្តីប្រាថ្នាគាប់ចិត្តដល់ជនទាំងពួងពិត ខ្ញុំព្រះករុណា សូមបង្អោនអង្គលើកកំបង់អញ្ជលីថ្វាយបង្គំ ចំពោះព្រះបរិយត្តិធម៌ ព្រមទាំងព្រះនព្វលោកុត្តរធម៌នោះ ដ៏ប្រសើរឥតកែអ្វីជាទៃស្មើឡើយ សព្វ ៗ កាលដោយគោរព ។

ព្រះគន្ធរចនាចារ្យ បានសម្តែងធម្មគុណប្បណាមចប់ស្រេចហើយ ក៏សម្តែងសង្ឃគុណប្បណាមតទៅទៀត ដោយបទព្រះគាថាដូច្នេះថា:

សន្តិន្ទ្រិយំ សុគតសូនុវរំ វិសុទ្ធំ
យំ ទក្ខិណេយ្យមមិតំ សុចិបុញ្ញខេត្តំ
តាណេសិនំ សរណមុជ្ឈិតសព្វទុក្ខំ
វន្ទាមិ សង្ឃមហិតំ សិរសា មហគ្ឃំ ។

អធិប្បាយថា ព្រះអរិយសង្ឃឯណាដ៏បរិសុទ្ធ ជាបុត្រដ៏ប្រសើរនៃព្រះសុគត មានឥន្ទ្រិយទាំង ៦ ស្ងប់រម្ងាប់ហើយ ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ គួរទទួលទក្ខិណាទានរបស់សត្វលោក ជាបុគ្គលមានទឹកថ្លាស្អាត បាតសេចក្តីសៅហ្មងគឺកិលេសជាស្រេច ជាស្រែបុណ្យរបស់សត្វលោក ជាបុគ្គលស្វែងរកទីពឹងដល់សត្វលោក ដ៏បង្កើតជាទីពឹងដល់សត្វលោក

ជាបុគ្គលស្តាប់ឡើងនូវទុក្ខទាំងពួងដល់សត្វលោក ខ្ញុំព្រះករុណា សូមបង្អោនអង្គលើកកំបង់អញ្ជលីថ្វាយបង្គំ ចំពោះព្រះអរិយសង្ឃនោះ លោកឥតមានទុក្ខព្រួកដស្មើដោយកែវមណីមានដំឡៃច្រើន ដោយសេចក្តីគោរពដោយត្បូងសិរសា ។

លុះព្រះគន្ធរចនាចារ្យ បាននិពន្ធបទគន្ថប្បណាមចប់ស្រេចហើយ ក៏សម្តែងសរសើរផលានិសង្សគន្ថប្បណាមតទៅទៀត ដោយបទព្រះគាថាដូច្នេះថា :

យម្បត្តមេត្ថរតនត្តយថោមនេន
បុញ្ញេន តេន ទុរិតំ សកលំ បនុដ្ឋំ
វត្វាមហំ សុមធុរំ រសវាហិណិន្តំ
ភោ ភោ សុណាន្តុ សុជនាភិមុទាវហា សា ។

អធិប្បាយថា ផលបុណ្យឯណាដែលខ្ញុំបានសម្រេចហើយ ដោយកិរិយាពណ៌នាសរសើរនូវគុណព្រះរតនត្រ័យ ក្នុងបទបណាមគាថានេះ ផលបុណ្យដែលហូរជូនមកពុំដាច់ កើតឡើងក្នុងចិត្តរបស់ខ្ញុំទាំងអស់នោះ ខ្ញុំសូមផ្ចើនូវសេចក្តីអន្តរាយទាំងពួងឲ្យឃ្លាតចេញទៅឆ្ងាយ អំពីកាយរបស់ខ្ញុំ ហើយនឹងសម្តែងនូវគម្ពីរឈ្មោះមធុរសវាហិណីនោះ ដោយប្រពៃពិត បពិត្រអ្នកទាំងឡាយដ៏ចំរើនអើយ! ចូរអ្នកទាំងឡាយប្រុងផ្ទង់សោតបសាទ ត្រងរងស្តាប់ធម្មរសនឹងអត្ថរសគម្ពីរមធុរសវាហិណីនោះចុះ ឯគម្ពីរមធុរសវាហិណីនោះ នឹងនាំមកនូវសេចក្តីរីករាយចិត្ត ដល់សប្បុរសទាំងឡាយ

ដោយពិត ។

រឿងនិទានដែលមានក្នុងគម្ពីរនេះ គឺព្រះអរហន្តទាំងឡាយពីមុន លោកបានសម្តែងជ្រើសរើសរឿងនិទាន ដែលកើតមានឡើងក្នុងទីនោះៗ ប្រមូលមកដម្កល់ទុកដោយសីហឡភាសា រក្សាទុកក្នុងមហាវិហារដើម្បីមិនឲ្យបាត់បង់ឡើយ ដល់មកកាលក្រោយមានព្រះថេរមួយអង្គព្រះនាមវេទេហ នៅសំណាក់ក្នុងវិក្កុវិហារ លោកប្រកបដោយសីលគុណនិងការុណាគុណ បានប្រែពីសីហឡភាសា ត្រឡប់មកជាមគធភាសា (ភាសាបាលីវិញ) ដើម្បីប្រយោជន៍ដល់ប្រជុំជនច្រើន មានភិក្ខុសង្ឃជាដើម គ្រាន់នឹងសិក្សារៀនសូត្របានដោយងាយ ។

គម្ពីរនេះចែកជាពីរផ្នែកគឺ មធុរសវាហិនីជម្ពុទីបៈ ១ មធុរសវាហិនីលង្កាទីបៈ ១ ។ ផ្នែកមធុរសវាហិនីជម្ពុទីបៈ មាន ៤ វគ្គ ក្នុងវគ្គមួយៗ មានរឿងនិទានដប់ៗ ត្រូវជានិទាន ៤០ គត់ ដែលកើតមាននៅក្នុងជម្ពូទ្វីប (ឥណ្ឌា) ។ ផ្នែកមធុរសវាហិនីលង្កាទីបៈ មាន ៦ វគ្គ ក្នុងវគ្គមួយៗ មានរឿងនិទានដប់ៗ ត្រូវជានិទាន ៦០ គត់ ដែលកើតមានក្នុងលង្កាទ្វីប រួមទាំងពីរផ្នែកបាន ១០០ រឿងគត់ ពុំលើសពុំខ្វះឡើយ ។

ខ្ញុំសូមរៀបរៀងវគ្គ ព្រមទាំងរឿងនិទានទាំងនោះដូចតទៅនេះ :

## ធម្មសោណ្ឌកវគ្គទី ១ មាននិទាន ១០ គឺ:

ទី ១ ធម្មសោណ្ឌកមហារាជវត្ថុកថា សម្តែងរឿង

ព្រះបាទធម្មសោណ្ឌកមហារាជ ក្នុងវគ្គទី ១ តាមបទបាលីដូច្នេះថា :

អត្ថាគាំ ភគវតោ ជាដើម អធិប្បាយថា កាលពីមុនព្រះមានព្រះភាគជាព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់នៃយើង ពុំទាន់បានត្រាស់ដឹងនៅឡើយ គ្រានោះ ព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមកស្សបៈ ព្រះអង្គបានត្រាស់ឡើងប្រាកដ ក្នុងភទ្ទកប្បនេះ តែងសម្តែងធម៌ទេសនាប្រោសវេនេយ្យសត្វឲ្យបានសម្រេចដល់ព្រះនិព្វាន តាមគំណត់ដូចព្រះសម្មាសម្ពុទ្ធអំពីបុរាណរៀងមក ហើយព្រះអង្គទ្រង់ចូលព្រះបរិនិព្វានទៅៗ លុះដល់សាសនារបស់ព្រះមានព្រះភាគអង្គនោះ វិនាសហាយសូន្យបាត់បង់ទៅមិនយូរប៉ុន្មាន កាលនោះ ព្រះបរមពោធិសត្វជាអម្ចាស់នៃយើង ព្រះអង្គក៏ពុងកសាងបន្សំបារមីទៅឡើយ ព្រះអង្គបានច្យុតចុះចាកទេវលោក មកចាប់បដិសន្ធិក្នុងផ្ទៃព្រះឧត្តមមហេសីនៃស្តេចពារាណសី ជាស្តេចឧត្តមខ្ពង់ខ្ពស់ប្រសើរជាងស្តេចទាំងពួងក្នុងជម្ពូទ្វីប ។

ក្នុងកាលដែលព្រះបរមពោធិសត្វនៅក្នុងផ្ទៃព្រះមាតា គ្រប់ ១០ ខែបរិបូណ៌ហើយ ក៏ប្រសូតចេញចាកផ្ទៃព្រះមាតានោះក៏ជាអស្ចារ្យ មានធម្មសញ្ញា សេចក្តីសំគាល់ក្នុងធម៌ បណ្តាលកើតឡើងក្នុងចិត្តនៃសត្វពលរូប សត្វទាំងនោះ សឹងមានប្រាថ្នាចង់ស្តាប់ធម៌គ្រប់ៗគ្នា ក្នុងកាលនោះដែរ ។

ព្រោះហេតុនោះ ព្រះបរមក្សត្រិយ៍ជាព្រះវរមាតាបិតា ព្រមទាំងព្រះ

រាជវង្សក្សត្រិយ៍បានសន្មតព្រះនាមថា ធម្មសោណ្ឌកកុមារ ក្នុងកាលនោះឯង ៗ ព្រះរាជកុមារនោះ បានចំរើនដោយយសបរិវារជាច្រើន លុះដល់វ័យធំឡើងហើយ ក៏បានសិក្សារៀនសិល្បសាស្ត្រទាំងពួងចេះចាំស្ទាត់ សម្តេចព្រះវររាជបិតា ទ្រង់ប្រទានឋានន្តរសក្តិជាព្រះមហាឧបរាជ ៗ ព្រះធម្មសោណ្ឌកឧបរាជ ទ្រង់គង់តែងបំពេញកុសលកម្មបថទាំង ១០ និងបុញ្ញកិរិយាវត្ថុ១០ មានទានជាដើម លុះអំណើះពីសម្តេចព្រះវររាជបិតាហើយ ក៏សេនាបតីនិងព្រាហ្មណ៍បុរោហិត ចាត់ចែងថ្វាយរាជសម្បត្តិអភិសេកឧបរាជជាព្រះបរមក្សត្រិយ៍ស្នងសម្តេចព្រះវររាជបិតា ក្នុងកាលនោះៗ

ចំណែកឯព្រះឧបរាជបរមពោធិសត្វបានសោយរាជសម្បត្តិជាស្តេចដ៏ប្រសើរ ទ្រង់ព្រះនាមព្រះបាទធម្មសោណ្ឌកមហារាជ មានព្រះកិត្តិគុណ ល្បីល្បាញប្រាកដស្មើដោយស្តេចព្រះបរមចក្រពត្តិ ក្នុងនគរពារាណសី ៗ នគរនោះក៏រុងរឿងប្រាកដដូចទេវនគរ លុះព្រះអង្គគ្រងរាជសម្បត្តិកន្លងទៅបានកន្លះខែហើយ ស្តេចគង់នៅលើទីក្រឡាព្រះបន្ទំដ៏មានសិរីសួស្តី ហើយទ្រង់រំពឹងពិចារណានូវហេតុផ្សេង ៗ ជាដើមថា:

កិរិយាដែលអាត្មាអញបានសោយរាជសម្បត្តិ ដ៏មានសិរីយ៉ាងនេះហើយប្រាសចេញចាកព្រះធម៌ពុំបានស្តាប់ព្រះធម៌ដូច្នេះ ដូចជាអាកាសដែលប្រាសចាកព្រះអាទិត្យពុំមានវត្ថុអ្វីអាចបំភ្លឺលោក ដូច្នោះដែរ ៗ លុះទ្រង់រំពឹងដូច្នេះហើយ ក៏រំពឹងតទៅទៀតថា អាត្មាអញបានរាជសម្បត្តិ

ប្រសើរយ៉ាងនេះ ព្រោះតែបុណ្យដែលពុំបានខ្ជិលច្រអូសខំស្វាហាប់ខ្វល់ខ្វាយបំពេញបុញ្ញកិរិយាវត្ថុមានទានសីលជាដើមពីមុនមក គឺដោយរាជ-រិទ្ធិដ៏ស្តុកស្តម្ភដូចជាទេវរាជ ដែលបានសោយសម្បត្តិទិព្វក្នុងទេវនគរដោយពិត ៗ ម្យ៉ាងទៀតអាត្មាអញមានអានុភាពបានសម្រេចដោយសម្បត្តិទាំងឡាយគឺរូបជាទីគាប់ចិត្ត ល្បែងមហោស្រពគួរទស្សនាជាទីពេញចិត្ត សម្លេងពីរោះគួរចង់ស្តាប់ដោយប្រពៃ គ្រឿងក្រអូបគួរដល់កិរិយាហិតស្រូបយកក្លិនជាទីពេញចិត្ត រសអាហារឆ្ងាញ់ពិសាគួរជញ្ជប់ជ្រួតជ្រាបដោយអណ្តាត សម្ផស្សដ៏ទន់ត្រជាក់ស្រួលគួរប៉ះពាល់ដោយកាយដូច្នេះអាត្មាអញនឹងគាន់សេចក្តីប្រមាទ ដោយសម្បត្តិមានប្រមាណប៉ុណ្ណោះពុំគួរសោះឡើយ គួរតែលះបង់ឲ្យទានខ្លួនប្តូរនឹងឲ្យទានជីវិត ឲ្យទានស្រូវអង្ករ ព្រមទាំងសម្បត្តិទ្រព្យដល់ស្មូមទាំងឡាយ ទើបប្រពៃ ៗ តមកព្រះអង្គមានព្រះរាជហឫទ័យ ជ្រះថ្លាប្រាថ្នាចង់ស្តាប់ព្រះធម៌ទេសនាដែលព្រះជិនស្រីទ្រង់សម្តែងតែងតាំងទុកមក ជាធម៌ឲ្យនូវព្រះនិព្វានជាទីក្សេមចាកយោគៈ ជាធម៌អាចប្រហារបង់នូវជាតិជរាព្យាធិនិងមរណៈឲ្យអស់ទៅដោយពិត ៗ ម្យ៉ាងទៀត អណ្តូងស្រះប្រាសចាកទឹកភ្លៀង មិនមានទឹកដក់នៅ មិនរុងរឿងល្អមានឧបមាយ៉ាងណា កិរិយាដែលអាត្មាអញសោយរាជ្យជាស្តេច ហើយប្រាសចាកព្រះធម៌ ពុំបានស្តាប់ធម៌ទេសនាពុំរុងរឿងល្អមានឧបមេយ្យយ៉ាងនោះដែរ ៗ រាត្រីប្រាសចាកព្រះចន្ទជាទីពឹង

ទិស មិនរុងរឿងល្អមានឧបមាយ៉ាងណា កិរិយាដែលអាត្មាអញសោយ-
រាជ្យជាស្តេច ហើយប្រាសចាកព្រះធម៌ ពុំបានស្តាប់ធម៌ទេសនា ក៏មិនរុង
រឿងល្អមានឧបមេយ្យយ៉ាងនោះដែរ ។ ដំរីអាជានេយ្យដ៏ប្រសើរដែលចង
គ្រឿងប្រដាប់ហើយប្រាសចាកកុក មិនរុងរឿងល្អមានឧបមាយ៉ាងណា
កិរិយាដែលអាត្មាអញសោយរាជ្យជាស្តេច ហើយប្រាសចាកព្រះធម៌ពុំបាន
ស្តាប់ធម៌ទេសនា មិនរុងរឿងល្អមានឧបមេយ្យយ៉ាងនោះដែរ ។ ទឹក
សមុទ្រប្រាសចាកត្រើយមិនរុងរឿងល្អមានឧបមាយ៉ាងណា កិរិយាដែល
អាត្មាអញសោយរាជ្យជាស្តេចហើយប្រាសចាកព្រះធម៌ ពុំបានស្តាប់ព្រះ
ធម៌ទេសនាក៏មិនរុងរឿងល្អមានឧបមេយ្យយ៉ាងនោះដែរ ។ ព្រះបរមក្សត្រិយ៍
មានគ្រឿងប្រដាប់ដ៏ល្អហើយទ្រង់ព្រះពស្ត្រជាចអាក្រក់ មិនរុងរឿងល្អ
មានឧបមាយ៉ាងណា កិរិយាដែលអាត្មាអញសោយរាជ្យជាស្តេចហើយ
ប្រាសចាកព្រះធម៌ ពុំបានស្តាប់ធម៌ទេសនា ក៏មិនរុងរឿងល្អមានឧបមេយ្យ
យ៉ាងនោះដែរ ។ បើដូច្នេះ គួរតែអញស្វែងរកស្តាប់ព្រះធម៌ទេសនាត្រាតែ
បាន លុះទ្រង់ព្រះដំរិះដូច្នេះហើយ ក៏មានព្រះហឫទ័យចង់ស្តាប់ព្រះធម៌
ដែលជាធម៌បណ្តុះបណ្តាលឲ្យបានសម្បត្តិទាំង ៣ ប្រការគឺសម្បត្តិមនុស្ស១
ទេវតា១ ព្រះនិព្វាន១ ពុំបេះដាច់ឡើយ ។ ឯវំ ចិន្តេត្វា ចាតោះ
ព្រះនរិន្ទ្រាធិបតី បរមពោធិសត្វ ព្រះអង្គទ្រង់ពិចារណាយ៉ាងនេះ
ហើយ លុះវេលាព្រឹកព្រាងស្វាងព្រះសុរិយា ព្រះអរុណភ្លឺច្បាស់ស្រឡះ

ហើយ ព្រះអង្គទ្រង់យាងចេញអំពីសោយប្រាសាទដ៏មានសិរីសួស្តី ចេញទៅប្រថាប់នាចុងព្រះរាជរោង ដ៏មានពួកអមាត្យចោមរោមគាល់បម្រើដោយជុំវិញ ស្តេចគង់នៅលើរាជបល្ល័ង្កដ៏ប្រសើរ ដែលមានស្វេតច្ឆត្រគឺបុគ្គលលើកឡើងបើកបាំងពីលើ ដ៏ប្រដាប់ដោយកែវទាំង ៧ ប្រការដ៏រុងរឿងដូចព្រះឥន្ទ្រាធិរាជជាស្តេចនៃទេវតា ហើយស្តេចមានព្រះរាជឱង្ការទៅនឹងអមាត្យទាំងឡាយថា ភោ ន្តោ ម្នាលអ្នកទាំងឡាយដ៏ចំរើនអើយ បណ្តាព្រះធម៌ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងតែងតាំងទុកមកហើយ បើអ្នកណាបានចេះដឹងនូវព្រះធម៌នោះខ្លះ អ្នកនោះត្រូវសម្តែងព្រះធម៌នោះមកឲ្យយើងបានស្តាប់ផង ដ្បិតយើងមានសេចក្តីប្រាថ្នាចង់ស្តាប់ព្រះធម៌ទេសនាពន់ពេកណាស់ ៗ ឯអមាត្យទាំងអស់ក៏ក្រាបបង្គំទូលព្រមគ្នាថា បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គទាំងឡាយពុំបានដឹង ពុំបានចេះចាំព្រះធម៌នោះដល់តិចតួចឡើយ សូមព្រះអង្គទ្រង់ជ្រាប ៗ

ព្រះបរមពោធិសត្វ កាលបើទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ មានសេចក្តីទោមនស្សតូចព្រះហឫទ័យហើយទ្រង់ពិចារណាថា បើដូច្នេះគួរតែអញឲ្យដម្កល់នូវប្រាក់មួយពាន់កហាបណៈ លើ-កនៃដំរីឲ្យបុរសវាយស្គរត្រេចទៅក្នុងនគរទាំងអស់ គង់មានបុគ្គលណាមួយលោភចង់បានទ្រព្យរបស់អញ សម្តែងធម៌ទេសនាដោយបទព្រះគាថាប្រកបដោយបាទបួនដល់អញ ពុំលែងឡើយ កិច្ចដែលអញបានស្តាប់ព្រះធម៌នោះនឹងមាន

សេចក្ដីសុខ សេចក្ដីចំរើនអស់កាលជាយូរអង្វែងទៅអនាគតដោយពិត ៗ លុះព្រះពោធិសត្វទ្រង់គិតដូច្នេះហើយក៏ចាត់សេវកាមាត្យទាំងឡាយឲ្យធ្វើដូចព្រះតម្រិះនោះ លុះបានធ្វើទៅហើយ ក៏ពុំមានបុគ្គលណាមួយអាចនឹងសម្ដែងធម៌បានឡើយ ទើបព្រះអង្គត្រាស់បង្គាប់ឲ្យបង្កើនកហាបណៈច្រើនឡើងជាលំដាប់តាំងពី ពីរពាន់ បីពាន់ បួនពាន់ឡើងទៅ ដរាបដល់មួយកោដិជាកំណត់ថា អ្នកណាអាចសម្ដែងធម៌ទេសនាតែមួយព្រះគាថា ដែលមានបាទបួន ឲ្យយើងស្ដាប់យើងនឹងឲ្យប្រាក់មួយកោដិ សូម្បីទ្រង់ផ្សាយដូច្នេះក្ដី ក៏គង់ពុំមានបុគ្គលណាមួយអាចសម្ដែងធម៌ទេសនាថ្វាយព្រះអង្គបានឡើយ លំដាប់ជាខាងក្រោយមក ព្រះអង្គចាត់សេវកាមាត្យឲ្យវាយស្គរត្រូចទៅក្នុងនគរទាំងអស់ទៀតថា បើអ្នកណាអាចសម្ដែងធម៌ទេសនាឲ្យយើងស្ដាប់ យើងនឹងឲ្យធ្វើជាធំក្នុងស្រុកនិគមនិងជនបទ ពុំនោះសោតយើងនឹងឲ្យធ្វើជាសេដ្ឋី ជាសេនាបតីឬជាឧបរាជ មួយទៀតយើងឲ្យស្វេត·ច្ឆត្ររាជសម្បត្តិទាំងមូល ឯចំណែកយើងនឹងលះបង់នូវភាពជាស្ដេចហើយធ្វើខ្លួនឲ្យជាខ្ញុំបម្រើអ្នកនោះហោង ៗ ទោះបីព្រះអង្គត្រាស់បង្គាប់ដូច្នេះក្ដី ក៏ពុំបានជួបប្រទះបុគ្គលណាមួយចេះចាំធម៌អាចនឹងសម្ដែងថ្វាយព្រះអង្គបានឡើយ ៗ បពិត្រសប្បុរសទាំងឡាយ យើងគួរតែមានសម្បជញ្ញៈភ្ញាក់ខ្លួនថាការដែលបានជួបប្រទះនឹងធម៌ទេសនាម្ដងៗនេះ ជាការក្រពន់ពេកណាស់ បើបានប្រទះបានស្ដាប់ធម៌ទេសនាហើយ ឈ្មោះថាជាបុគ្គលមានភ័ព្វមាន

វាសនាធំបំផុតទីរកអ្វីប្រៀបផ្ទឹមគ្នានឹងឡើយ ។ ចំណែកឯព្រះបរមពោធិសត្វ កាលបើព្រះអង្គរកបុគ្គលអ្នកសម្ដែងធម៌ទេសនាពុំបានហើយ ក៏ដល់នូវសំវេគសង្វេគស្ទប់ក្នុងព្រះរាជហឫទ័យថា អញប្រាសចាកធម៌ទេសនាហើយ ប្រយោជន៍អ្វីនឹងសោយរាជសម្បត្តិទៅទៀត លុះទ្រង់ព្រះចិន្ដាដូច្នេះហើយ ក៏លះបង់រាជសម្បត្តិប្រគល់ដល់អមាត្យទាំងឡាយ ស្រេចហើយព្រះអង្គចេញចាកព្រះនគរទៅក្នុងកាលនោះឯង ។ ព្រះបាទធម្មសោណ្ឌក-មហារាជ កាលដែលព្រះអង្គចេញស្វែងរកព្រះសទ្ធម្ម តាមលំដាប់ស្រុកនិគមជនបទរាជធានីហូរហែទៅ ក៏បានទៅដល់ព្រៃហិមពាន្ត ។

ព្រោះហេតុនោះ ព្រះអរហន្តទាំងឡាយបាននាំរឿងនិទាននេះយកមកសម្ដែងទុកក្នុងគម្ពីរមធុរសវាហិណីនេះ លោកពោលជាបទព្រះគាថាថា បុរេ ភេរិញ្ញាភបេត្វា ធម្មសោណ្ឌោ ឧភាធីបោ ជាដើម អធិប្បាយថា ព្រះបាទធម្មសោណ្ឌកពោធិសត្វ ជាទីពឹងនៃជនទាំងឡាយ ព្រះអង្គចាត់សេវកាមាត្យឲ្យវាយស្គរត្រេចទៅក្នុងនគរស្វែងរកអ្នកប្រាជ្ញចេះសម្ដែងធម៌ទេសនា ទ្រង់នឹងព្រះរាជទានរង្វាន់តាំងពីពីរពាន់កហាបណៈដរាបដល់មួយកោដិ ក៏ពុំមានបុគ្គលណាមួយអាចហ៊ានទទួលយកឡើយ ហើយស្ដេចឲ្យដំឡើងថ្លៃតាំងពីឲ្យធ្វើជាធំក្នុងស្រុកជនបទ ដរាបដល់ឲ្យសោយរាជសម្បត្តិជាស្ដេច ព្រះអង្គនឹងធ្វើជាខ្ញុំបម្រើវិញ ក៏ពុំមានបុគ្គលណាមួយ អាចទទួលសម្ដែងធម៌ទេសនាថ្វាយព្រះអង្គបានឡើយ ។

ព្រះបរមក្សត្រិយ៍នោះ កាលបើព្រះអង្គរកបុគ្គលអ្នកសម្តែងធម៌ពុំបានហើយ ក៏ទ្រង់លះបង់រាជសម្បត្តិក្រោមស្វេតច្ឆត្រជាទីត ម្រកប្រគល់ឲ្យអមាត្យទាំងឡាយ ពុំមានព្រះហឫទ័យអាល័យឡើយ ហើយស្តេចចេញទៅកាន់ព្រៃហិមពាន្ត ក្នុងកាលនោះហោង ។ ដោយតេជៈបុណ្យព្រះមហាសត្វ ទីអាសនៈសម្តេចអម្រិន្ទ្រាធិរាជ ក៏បណ្តាលឡើងឲ្យក្តៅក្រហាយគួរជាទីអស្ចារ្យ ព្រះឥន្ទ្រស្តេចគង់ពុំបានកើតរំខានក្នុងព្រះទ័យ ក្នុងខណៈដែលព្រះអង្គចូលទៅដល់ព្រៃមហាវ័ននោះឯង ។

គ្រានោះ សក្កទេវរាជទ្រង់ព្រះចិន្តាថា: បណ្ឌុកម្ពលសិលាសនៈរបស់អញកើតជាក្តៅក្រហាយ ទីដ៏អង្គុយពុំបាន តើព្រោះហេតុអ្វីហ្ន៎? ព្រះអង្គទ្រង់រំពឹងគិតដូច្នេះហើយ ក៏បើកទិព្វចក្ខុប្រមើលមើលមនុស្សលោក ហើយពិនិត្យមើលជម្ពូទ្វីបទាំងអស់ បានឃើញព្រះបាទធម្មសោណ្ឌកមហារាជ ស្តេចស្វែងរកបុគ្គលអ្នកចេះសម្តែងធម៌ទេសនាពុំបាន ហើយទ្រង់លះបង់រាជសម្បត្តិឥតអាល័យ ស្តេចចូលមកកាន់ព្រៃហិមពាន្ត ។ លុះព្រះឥន្ទ្រាធិរាជទ្រង់បានឃើញដូច្នេះហើយ ក៏គិតពិចារណាតទៅទៀតថា ព្រះបាទធម្មសោណ្ឌកមហារាជអង្គណាដែលទ្រង់លះបង់រាជសម្បត្តិ ព្រមទាំងព្រះញាតិវង្សទាំងជីវិតនៃខ្លួនដើម្បីស្វែងរកស្តាប់ព្រះសទ្ធម្មក្នុងគ្រានេះ , ព្រះបាទធម្មសោណ្ឌកមហារាជអង្គនោះមិនមែនជាសាមញ្ញសត្វដទៃផ្តេសផ្តាសទេ គឺជាអង្គពោធិសត្វទីដ៏បាន

ត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធមួយព្រះអង្គក្នុងកប្បនេះដោយពិត ព្រះអង្គមានព្រះហឫទ័យចង់ស្តាប់ធម៌ទេសនា ប៉ុន្តែស្វែងរកបុគ្គលអ្នកប្រាជ្ញចេះសម្តែងធម៌ពុំបាន ហើយទ្រង់ចូលមកកាន់ព្រៃធំនេះ បើទ្រង់ពុំបានស្តាប់ធម៌ហើយ ក៏នឹងដល់នូវសេចក្តីទុក្ខធំដោយពិត បើអញមិនទៅសង្គ្រោះផងទេ យល់ឃើញជាពុំសមហេតុផលឡើយ, គួរតែអញទៅក្នុងទីនោះនៅថ្ងៃនេះ ដើម្បីស្រោចស្រប់ព្រះពោធិសត្វនោះ ដោយទឹកអម្រឹតរសគឺព្រះធម៌ ហើយនាំយកទៅដម្កល់ទុកក្នុងរាជសម្បត្តិដដែលវិញទើបគួរ ។ សម្តេចព្រះសហស្សនេត្រទ្រង់គិតយ៉ាងនេះហើយ ក៏ហោះចុះមកពីស្ថានតាវតឹង្សទេវលោកនាយមកកាន់ស្ថានមនុស្សលោក ទ្រង់លះបង់អត្តភាពប្រក្រតីហើយ កាន់យកភេទជាយក្សអារក្សទឹកយ៉ាងធំ គួរខ្លាចស្ញប់ស្ញែងពន់ពេកដើរចូលមក មានមុខឆ្ពោះទៅកាន់សំណាក់ព្រះមហាសត្វ ហើយសម្តែងខ្លួនឲ្យប្រាកដស្ថិតនៅក្នុងទីពុំឆ្ងាយពីព្រះបរមពោធិសត្វនោះឡើយ ។ ព្រោះហេតុនេះ បានជាព្រះអរហន្តទាំងឡាយលោកសម្តែងជាបទព្រះគាថាដូច្នេះថា ព្យគ្ឃច្ឆសីហមហិសោភតហត្ថិ ជាដើម អធិប្បាយថា ព្រះនរិន្ទ្រាធិបតីធម្មសោណ្ឌករាជ ព្រះអង្គមានសេចក្តីអផ្សុកមានប្រាថ្នាចង់ស្តាប់ធម៌ ហើយស្តេចចេញទៅអំពីនគរពារាណសី ត្រេចចូលទៅក្នុងព្រៃសេលព្រឹក្ស ប្រកបដោយញាតស្បាតដ៏ជិតសុទ្ធតែបន្លាដ៏ប្រទាំរឹករវរ ដោយសត្វសាហាវ មានខ្លាធំ ខ្លាឃ្មុំ សត្វសីហៈនឹងក្របីព្រៃគោព្រៃ, ដំរី

ខ្លាជម្បងជាដើម ， នៅអាស្រ័យក្នុងព្រៃនោះឯង ， ដោយតេជះអានុភាព បុណ្យបារមីព្រះពោធិសត្វនោះ អាសនៈថ្មកែវដ៏មានពណ៌ល្អដូចសំពត់ កម្ពលក្រហមលឿងរបស់ព្រះឥន្ទ្រាធិរាជ ក៏បង្កើតក្តៅក្រហល់ក្រហាយ ឥន្ទគង់ពុំបាន នាំរំខានក្នុងព្រះទ័យ ទើបបើកទិព្វចក្ខុមើលមើល ស្ថានមនុស្សលោក លុះបានជ្រាបហេតុនោះសព្វគ្រប់ហើយ ក៏ហោះ ចុះមកពីស្ថានទេវលោកនាយ មកកាន់ស្ថានមនុស្ស ហើយនិម្មិតអាត្មា ជាយក្សកាចបើងរឹងរូសគួរខ្លាចពន់ពេក មានសម្បុរខៀវស្រងាត់ដូចជា កំពូលភ្នំអញ្ជន មានមាត់ធំ មានចង្កូមគួរខ្លាច លៀនចេញមកខាងក្រៅ មានភ្នែកទាំងពីរធំក្រហមប្រាលដូចជាគំនរសម្រាមដែលភ្លើងឆេះ ហើយ មានច្រមូងខ្ទូងកណ្តាល មានចុងច្រមុះក្រហម មានសក់ទីងពុកមាត់ជា ដុំរង មានពណ៌ក្រហមដូចរណ្តាតភ្លើង មានផ្ទៃពោះពណ៌ខៀវ មាន សម្លេងឮបន្ទឹកដូចផ្គរលាន់គួរស្ញែង មានក្រចកដៃប្រឡាក់ដោយឈាម ជាប់ជានិច្ច មានបាតដៃធំពុំដែលលាងទឹកម្តង មានដម្បងដែកគ្រឿងអាវុធ ក្នុងដៃជាប់មិនដាច់ មានចង្កូមទីងបង្ហូរមាត់គួរស្ញែង មានថ្ពាល់ប្រកប ដោយសរសៃជ្រួញ ៗ ដូចជាវល្លិ៍ មានតែសាច់មនុស្សជាអាហារបរិភោគ ប្រក្រតី មានជើងទាំងពីរក្រហមដូចរងើកភ្លើង សម្តែងខ្លួនឈរនៅក្នុង ចន្លោះភ្នំ ឲ្យប្រាកដដល់ព្រះនរាធិបតីធម្មសោណ្ឌកមហារាជនោះឯង ។

គ្រានោះ ព្រះមហាសត្វបានឃើញឥន្ទយក្សស្ថិតនៅក្នុងទីជិតនៃខ្លួន

ដូច្នោះហើយ  ក៏ពុំបានខ្លាចញាប់ញ័រតក់ស្លុតចិត្តនិងព្រឺព្រួចរោមឡើយ
ព្រោះព្រះឥន្ទ្របានរំពឹងគិតថា  យក្សដែលមានសភាពយ៉ាងនេះ មុខជា
ចេះសម្តែងធម៌ទេសនាដោយពិត,  បើដូច្នោះ ត្រូវតែអញចូលទៅជិត
ក្នុងសំណាក់អារក្សទឹកនោះហើយនិងស្តាប់ធម៌ទេសនា ដ្បិតកិរិយាដែល
បានស្តាប់ធម៌ទេសនានោះជាទីនាំមកនូវសេចក្តីសុខ និងប្រយោជន៍ដល់
អញអស់កាលជាយូរអង្វែងទៅឯអនាគតពុំលែងឡើយ  លុះព្រះបរម
ពោធិសត្វទ្រង់គិតដូច្នេះហើយ  ក៏ទ្រង់រំពឹងតទៅទៀតថា ថ្ងៃនេះ
ត្រូវតែអញចូលទៅជិតយក្សនោះហើយសួរយក្សទើបគួរ  ទើបព្រះឥន្ទ្រ
យាងចូលទៅជិតនិយាយសន្ទនាជាមួយនឹងយក្សនោះ  ពោលជាបទ
ព្រះគាថាដូច្នេះថា  អស្មិំ វនស្មិំ តរុស ណ្ឋាម ណ្ហិតោ ជា
ដើម អធិប្បាយថា  បពិត្រមហាយក្ស ! ដ៏មានខ្លួនប្រដាប់ដោយ
ទ្រង់ទ្រាយពេញជំទង់  តួអ្នកមានអានុភាពច្រើន សឹងប្រដាប់ដោយ
គ្រឿងអាភរណៈផ្សេង ៗ ស្ថិតនៅក្នុងព្រៃនេះ  អ្នកជាបុគ្គលមានចិត្ត
ពុំបានតក់ស្លុតខ្លាចអ្វីឡើយ  ចំណែកខាងយើងបានលះបង់រាជសម្បត្តិ
និងពួកញាតិទាំងឡាយដើរស្វែងរកបុគ្គលអ្នកសំដែងធម៌ទេសនា  បាន
ចូលមកកាន់ព្រៃនេះ  បើយើងសួរនូវសេចក្តីសង្ស័យឯណាចំពោះអ្នក
សូមអ្នកសម្តែងប្រាប់សេចក្តីសង្ស័យនោះដល់យើង  បពិត្រយក្ស !
ថាបើអ្នកបានចេះព្រះធម៌  សូមអ្នកសម្តែងធម៌ក្នុងបទព្រះគាថាមួយ

ដែលព្រះសុគតបានសម្ដែងហើយ ដល់យើងឥឡូវនេះផង ។

លំដាប់នោះឥន្ទយក្សតបវិញថា បពិត្រមហាកដ ! យើងបាន ចេះព្រះធម៌ដែលព្រះជិនស្រីទ្រង់សម្ដែងទុកមកដោយចំណែកមួយ ជាធម៌ដ៏ប្រសើរវិសេសជាងសេតាំទពួងមែន តែបើយើងសម្ដែងធម៌នោះដល់ព្រះអង្គហើយ តើព្រះអង្គនឹងបូជាវត្ថុអ្វីដល់យើងជាអ្នកសម្ដែងធម៌វិញ ? ។

គ្រានោះ ព្រះមហាសត្វតបថា បពិត្រមហាយក្សដ៏ចម្រើន! បើយើងស្ថិតនៅក្នុងកងសម្បត្តិទៅក៏ យើងនឹងបូជាដល់អ្នកឲ្យវិសេសបច្រើនទៅបាន ឥឡូវយើងចូលមកក្នុងព្រៃនេះតែម្នាក់ឯង បើវៀរលែងតែកាយរបស់យើងចេញហើយ យើងនឹងរកវត្ថុវិសេសបូជាដូចម្ដេចបាន ប្រសិនបើ អ្នកប្រាថ្នាចង់បរិភោគសាច់ឈាមរបស់យើង ១ នឹងលះកាយនេះបូជាព្រះធម៌ ឲ្យអ្នកបរិភោគជាអាហារក្នុងថ្ងៃនេះឯង ដ្បិតស្បៀងអាហារដទៃរបស់អ្នកក៏ពុំមានដែរ អ្នកត្រូវសំដែងធម៌ទេសនាឲ្យយើងស្ដាប់ជាមុនសិនចុះ យើងនឹងលះកាយនេះបូជាដល់អ្នកបរិភោគក្នុងកាលជាខាងក្រោយដោយពិត ។ ឥន្ទ-យក្សបានស្ដាប់ហើយពោលតបថា បពិត្រមហាកដ! យើងមានសេចក្ដីស្រេកឃ្លានពេកណាស់ ដរាបណាយើងបានបរិភោគសាច់នឹងផឹកឈាមឲ្យឆ្អែតស្រួលខ្លួន បន្ទាប់ទើបសេចក្ដីក្រវល់ក្រវាយក្នុងកាយ

ជាមុនសិន ដកបនោះទើបអាចនឹងសម្ដែងធម៌ទេសនាឲ្យព្រះអង្គស្ដាប់បាន ដ្បិតយើងអត់អាហារយូរថ្ងៃណាស់ហើយ សេចក្ដីស្រេកឃ្លានតែងបៀតបៀនញាប់ញ័រសព្វសព៌ាង្គកាយ ទំនងសម្ដែងធម៌ទេសនាដូចម្ដេចបាន ។

លំដាប់នោះ ព្រះមហាសត្វបានស្ដាប់ហើយក៏ពោលថា បពិត្រយក្ស! ប្រសិនបើ អ្នកបរិភោគយើងមុនហើយ សឹមសម្ដែងធម៌ទេសនាជាខាងក្រោយ តើនឹងសម្ដែងធម៌ឲ្យអ្នកណាស្ដាប់ បើយើងស្លាប់ទៅហើយ , ចំណែកអ្នក មានលាភបាននូវសាច់បរិភោគ ព្រោះតែការបានសម្ដែងធម៌ឲ្យយើងស្ដាប់ប៉ុណ្ណោះឯង , ដូច្នេះត្រូវអ្នកពិចារណាឲ្យបានដឹងដោយសមគួរតាមពិតចុះ ។

លុះព្រះបរមពោធិសត្វទ្រង់ត្រាស់យ៉ាងនេះហើយ ឥន្ទ្រយក្សក៏ទូលតបវិញថា បពិត្រមហាពជ ! ពាក្យនេះប្រពៃហើយ , បើដូច្នោះត្រូវព្រះអង្គស្ដេចឡើងទៅលើភ្នំនេះហើយ ស្ថិតនៅលើកំពូលភ្នំទំលាក់ព្រះកាយចុះមកសំដៅមាត់ខ្ញុំ, កាលបើព្រះអង្គលោតទំលាក់ព្រះកាយចុះមកហើយ ខ្ញុំនឹងសម្ដែងធម៌ទេសនាឲ្យព្រះអង្គស្ដាប់បណ្ដើរកាលនោះឯង, បើព្រឹត្តិការណ៍បែបនេះសមហេតុហើយលាភដ៏ប្រសើរ ដែលព្រះអង្គបានស្ដាប់ធម៌ទេស. នាក្ដី លាភដែលខ្ញុំបានបរិភោគសាច់ឈាមក្ដី នឹងបានស្មើគ្នាតាមពិត , ការដែលខ្ញុំបរិភោគនូវសាច់នឹងឈាមសោត ក៏នឹងមានប្រាកដដូច្នេះឯង ។

(នៅមានត)

# មហោសថជាតក

លោកអ៊ឹម-ភន ចម្លងពីសាស្ត្រស្លឹករឹត ព្រះពុទ្ធវង្ស កិម-គួរ ពិនិត្យ

## ឆមោ ៣ ជង

បញ្ចាលោ សព្វសេនាយាតិ ឥទំ សត្ថា ជេតវនេ វិហរន្តោ អត្តនោ បញ្ញាបារមី អារព្ភ កថេសិ ។

សត្ថា នោះ សត្ថវាហោ សត្ថនាយកោ ព្រះអង្គជានាយក តែងនាំទាំគៀរគរប្រមូលបញ្ចូលអស់ពពួកសត្វនិករអមរជន ទាំងអស់ទេវតាមនុស្សសត្វផងទាំងឡាយដាក់ដល់ដំកល់ក្នុងទូទី ដ៏សំរិទ្ធី បរិបូណ៌ពោលគឺអម្រឹតបុរីស្រីមហានគរនិព្វាន ដ៏ជាឋានបរមសុខក្សេមប្រសើរ វិហរន្តោ នោះ ចតូសុ ឥរិយាបថេសុ វីតិនា-មេន្តោ ក៏ព្រះអង្គគង់សម្រេចសម្រាន្ត ដោយបន្ទូរព្រះឥរិយាបថស្រេចគត់ កំណត់ព្រះអង្គនោះមានបួន មិនឲ្យជួនខ្ទួរសន្ទុះតំរេះចិត្តនៃសត្វផងទាំង-ឡាយ ជេតវនេ ក្នុងឋានអារាមនាមហៅព្រះស្រីជ័យជេតពនសុគន្ធ-កុដីស្រីមហាវិហារ អារព្ភ នោះ អារម្មណំ កត្វា ព្រះអង្គធ្វើឲ្យជាហេតុ ជាអារម្មណ៍បន្ទិចស្រេចហើយ ទ្រង់ប្រារព្ធនូវនោះបញ្ញាបារមី នៃព្រះអង្គឯង កថេសិ នោះ ធម្មំ ទេសេសិ ទើបព្រះអង្គសំដែងថ្វីន៏ព្រះធម៌វិសេសទេសនា ឥទំ មហោសថជាតកំ នូវទំពាន់ដ៏·

ណាលកាលព្រះអង្គស្ដេចត្រាច់ត្រាត់ ទៅក្នុងភពវដ្ដសង្សារត្រកាលយោន យកកំណើតកើតជាព្រះពោធិសត្វមួយព្រះអង្គ ទ្រង់ព្រះនាមករបវរវិសេស ឈ្មោះព្រះមហោសថនេះ ៗ អាទិកាថាបទេន អត្ថជា ឧប-លក្ខិតំ ទើបព្រះអង្គមកកត់សំគាល់នូវទំនងគន្ធងដើមបទកំណត់អក្សរ បវរព្រះគាថានេះជាដើមអាទិគី បញ្ញោ សព្វសេនា អាតិ នេះឯងដ៏ជាប្រធានដើមបទកំណត់ព្រះមហោសថជាតកនោះឯងហោង ៗ

ឯកាទិវសម្ហិ ភិក្ខុ ធម្មសភាយំ សន្និសិន្នា តថា-គតស្ស បញ្ញាបារមី វណ្ណយន្តា និសីទិំសុ បពិត្រអើយ មានកាលសម័យថ្ងៃមួយ រីអស់ពពួកភិក្ខុសង្ឃអង្គអហេន្ទាំណា ស្រពផងទាំងឡាយ សឹងដ៏មានចិត្តៈរះសប្បាយពេកពយ បប្រួលគ្នាទៅអង្គុយជុំនុំ នៅឰដ៏ធម្មសភាសាលា ដ៏ជាឋានជុំនុំតែងទីនស្ដាប់ធម៌វិសេសទេសនា នោះហើយ មានភិក្ខុត្រីមួយព្រះអង្គគង់ឰដ៏ដើមអាសនាជាបង្អស់ ហើយបណ្ដាលនូវពាក្យមេត្រីទៅនឹងអស់ភិក្ខុកំឡោះផងទាំងឡាយថា ភិក្ខវេ ម្នាលភិក្ខុផងទាំងឡាយអើយ រីព្រះដ៏មានបុណ្យអម្ចាស់វិសេសថ្លៃនៃយើងនេះ មហាបញ្ញោ ព្រះអង្គមានព្រះប្រាជ្ញានោះដ៏ច្រើនមហិមាក្រៃ ឥតអ្នកឯណាដទៃផ្ទឹមស្មើនឹងព្រះអង្គនោះបានឡើយ ៗ បុថុបញ្ញោ ព្រះអង្គមានព្រះប្រាជ្ញានោះក្រាស់មហិមាក្រៃពេក ៗ ហាសបញ្ញោ

ព្រះអង្គមានព្រះប្រាជ្ញានោះ ដ៏ជ្រៅការសម្រេចសម្រួលបញ្ចូលចិត្តឲ្យ
ជាទីស្រឡាញ់នៃអប់មនុស្សបត្តទាំងឡាយ ។ គម្ភីរបញ្ញា ព្រះអង្គ
មានព្រះប្រាជ្ញានោះ ដ៏ជ្រៅឆ្ងាយទូលាយក្រៃ ។ ភូរិបញ្ញា ព្រះអង្គមាន
ព្រះប្រាជ្ញានោះ ដ៏ផុលដ៏នឹងឯង ឥតគ្រូពីព្រេងណាទៅប្រៀនប្រដៅព្រះអង្គ
ឡើយ ។ លហុបញ្ញា ព្រះអង្គមានប្រាជ្ញានោះដ៏ស្រាលស្រេចល្អល្អះ
មហិមាក្រៃ ។ ជវនបញ្ញា ព្រះអង្គមានព្រះប្រាជ្ញានោះ ដ៏ឈ្លាស
វៃលឿនឆាប់មហិមាក្រៃពេកដូចជវនមហាហង្ស ។ តិក្ខបញ្ញា ព្រះ
អង្គមានព្រះប្រាជ្ញានោះ ដ៏មុតថ្លាមហិមាក្រៃពេកដូចបំពៅវគភាពក្រៃត្តិ
ក្រុងភារទ្វារ ។ និព្វេធិកបញ្ញា ព្រះអង្គមានព្រះប្រាជ្ញានោះ
តែងកាចឲ្យសត្វផងទាំងឡាយទៀសទំបង់ ។ បរប្បវាទមទ្ទនោ.
អត្ថោ បញ្ញាចុកាវេង ព្រះអង្គមានព្រះប្រាជ្ញានោះ ផ្ចាញ់ផ្ចាំញី
បុកបែនគិនប្រាជ្ញាអ្នកដទៃឥតបើនឹងហ៊ានប្រកួតផងបានឡើយ ឧទិត្វា
ព្រះអង្គកាចឲ្យផ្ចាញ់ដ៏ប្ដូន្ទានលោមលួងប្រដៅ ព្រាហ្មណោ នូវអស់
ព្រាហ្មណ៍ផងទាំងឡាយ កូដទន្តាទយោ ជាម មានឈ្មោះ
កូដទន្តព្រាហ្មណ៍ឯងជាដើម បរិព្វាជកេ នូវអស់បរិព្វាជកផងទាំង
ឡាយ សច្ចកិយាទយោ មានសច្ចកព្រាហ្មណ៍ឯងជាដើម យក្ខេ ក៏
នូវអស់យក្សផងទាំងឡាយ អាឡវកាទយោ ដ៏មានអាឡវកយក្ស
ឯងជាដើម ទេវតាយោ នូវអស់ទេវតាផងទាំងឡាយ សក្កាទ-

យោ ដ៏មានឥន្ទ្រាធិកជងឯងជាដើម ព្រហ្មានោ ច នូវអស់ព្រហ្មផង ទាំងឡាយ ពកា ច យោ ដ៏មានពកព្រហ្មឯងជាដើម ៗ រីព្រះតថាគតអម្ចាស់វិសេសថ្លៃនៃយើងនេះ ព្រះអង្គអាចឲ្យទទួលដំបូន្មានលោម លួងប្រដៅ ដោយនូវអានុភាពព្រះប្រាជ្ញាទិព្វថ្លៃនៃព្រះអង្គ អាចធ្វើឲ្យ អស់មហាជនផងទាំងឡាយទៀតសប់បង់នោះហើយ ព្រះអង្គអាចឲ្យទទួល ដំបូន្មានដល់អ្នកបួសនោះ មួយអន្លើនូវអស់ពពួកមហាជនផងទាំងឡាយក្តី ក៏ព្រះអង្គអាចនាំទៅសណ្ឋិតនៅព្រះដ៏លើផ្លូវមគ្គផលអំពល់នូវនិព្វាន ដ៏ ជាឋានបរមសុខក្សេមប្រសើរហោង ៗ

បពិត្រអើយ រីអស់ភិក្ខុសង្ឃផងទាំងឡាយនោះ មកជុំគ្នាស្រដី សរសើរអំពីព្រះប្រាជ្ញាបារមីថ្លៃនៃព្រះដ៏មានបុណ្យនោះហើយ វាមិនសោះ សូន្យទៅឡើយ ក៏សឹងឮជ្រួតជ្រាបដការទៅដល់ព្រះសោតទិព្វថ្លៃ វិសេសនៃព្រះដ៏មានបុណ្យ ព្រះអង្គជ្រាបដំណឹងហើយ ព្រះអង្គទ្រង់ព្រះ ចិន្តាពិចារណាថា ឥឡូវនេះ អស់ភិក្ខុសង្ឃផងទាំងឡាយ ទៅអង្គុយ ជុំនៅព្រះធម្មសភាសាលា ហើយសឹងស្រដីសរសើរដំណើរអំពីព្រះបារមី ទិព្វថ្លៃនៃអញតថាគតហើយ ហៈនូ ! យើ ! និងកប់ជាអស្ចារ្យក្រៃអ្វីដូច្នេះ ហ្នឹង ! អញតថាគតបានត្រាស់ជាព្រះពុទ្ធប្រាកដហើយ បើដូច្នេះហើយ រីធម៌វិសេសទេសនានៃអញតថាគតកាលកើតជាបាមហោសថបណ្ឌិតអ្នក ប្រាជ្ញនោះ សមនឹងប្រាកដព្រះដ៏កណ្តាលជុំនុំនៃអស់ភិក្ខុសង្ឃផងទាំង

ឡាយ នៅញុំងធម្មសភាសាលានោះឯងមិនទៅឡើយ ម្ល៉ោះហើយទើប ព្រះអង្គស្រង់ទឹកទៅទូវទឹកអប់ត្រឡប់ ទូវគន្ធពិដោរ គឺកិច្ចផងតែងផង ត្រង់ទាំមកទបង្អាកបំរើ ព្រះអង្គស្រង់ស្រេចហើយ ទើបស្តេចទ្រង់នូវត្រៃ ចីវរបវរមហាបង្សុកូលេ ឃ្លុំគ្រលុំស្រេចស្តេចលីលាយាត្រាចេញទៅអំពី ព្រះសុគន្ធកុដីសិរីមហាវិហារ ដ៏មានព្រះដំណើរនោះសីហនាទគតាគតប៉ូច ដំណើរកេសរពេជសីហ៍ចេញកំឡោះ ផ្លោះចេញអំពីលង្អែកគុហាមាស ដ៏ប្រាសលែងក្តីកង្វាចនូវម្រឹគផងទាំងឡាយ កាលណាបើព្រះអង្គស្តេច លីលាទៅដល់ធម្មសភាសាលានោះហើយ ព្រះអង្គឡើងទៅគង់ញុំងលើ គ្រែបញ្ញត្តបវរពុទ្ធាសនា ដ៏ប្រដាប់ប្រសើរប្រពៃ ទើបព្រះអង្គមានព្រះ ពុទ្ធដីកាដណ្តឹងថា ម្នាលអាវុសោភិក្ខុផងទាំងឡាយអើយ នាអាវុ-សោបបួលគ្នាមកអង្គុយជុំនុំគ្នានូវញុំងធម្មសភាសាលានេះ តើមានបើស្រដី និយាយអំពីដំណើរសេចក្តីអ្វីខ្លះ ។ ហ្ន៎! ម្តេចក៏អាវុសោមិនបបួលគ្នាចេញ ទៅសង្កត់ក្រវើនចំរើនមេត្តាភាវនា ប្រាថ្នាសម្បត្តិអរហត្តនិព្វានដ៏ជាឋាន ប្រសើរទើទៃ ។ ហ្ន៎, ម្តេចក៏មកអង្គុយស្ងៀមព្រងើយអ្វីនៅនេះដូច្នេះ ? ។

ឥមាយ ជាមាតិ វុត្តេ អស់ភិក្ខុផងទាំងឡាយនោះ ស្តាប់ព្រះ បន្ទូលថ្លៃនៃព្រះដ៏មានបុណ្យដូច្នោះហើយ សឹងលុតជង្គង់លើកកំបង់អញ្ជ-លីដាក់លើសិរសាអាត្មាភាព ក្រាបថ្វាយបង្គំទូលថា ភន្តេ ភគវា បពិត្រព្រះដ៏មានបុណ្យអម្ចាស់វិសេសថ្លៃខ្ញុំអើយ អស់យើងខ្ញុំទាំង

អម្បាលនេះ មកអង្គុយជុំនុំគ្នានៅធម្មសភាសាលានេះ មិនស្រដីអំពី ឥត្ថីភាព បុរសភាព ឲ្យជាមន្ទិលពិភាល់ក្នុងកំឡុងព្រះសាសនាព្រះអង្គ ដ៏ជាអម្ចាស់នេះឡើយ, បពិត្រព្រះដ៏មានបុណ្យអើយ នាយើងខ្ញុំទាំង អម្បាលនេះ មកស្រដីសរសើរតែអំពីព្រះប្រាជ្ញា ព្រះបារមីថ្លៃនៃព្រះអង្គ នោះ យល់កើតជាអស្ចារ្យក្រៃកាល ប្រសើរក្រៃពេកក្នុងលោកនេះ ឥត បុរសបុគ្គលឯណាមួយនឹងផ្ទឹមឲ្យត្រឹមស្មើនឹងព្រះអង្គឡើយ ៗ អស់ភិក្ខុផង ទាំងឡាយ ទូលព្រះដ៏មានបុណ្យនូវប្រការអម្បាលនោះហើយ ទើបព្រះ ដ៏មានបុណ្យព្រះអង្គបន្ទូលវិញថា ភិក្ខវេ ម្នាលភិក្ខុផងទាំងឡាយ អើយ នឹងពប់ហៅថាអស្ចារ្យអ្វីដូច្នេះ នាអញតថាគតបានត្រាស់ ច្បាស់ប្រាជ្ញាសព្វញ្ញុតញ្ញាណបានជាព្រះពុទ្ធប្រកដហើយនេះ ដែល លោកនឹងពប់ហៅជាអស្ចារ្យនោះ គឺនាកាលមុននាយឡើយនោះ កាលអញតថាគតមានប្រាជ្ញាពុំទាន់ចាស់ បារមីពុំទាន់ទុំ តែងសង្វាត សន្សំសាងបន្ទុំពោធិសម្ភារបារមី ខ្មីក្រវើនខំបំរើនឲ្យបានត្រាស់ជាព្រះពុទ្ធ ប្រាកដនោះ គឺកាលអញតថាគតយោនយកកំណើត កើតជាពោធិសត្វ មួយព្រះអង្គទ្រង់ព្រះនាមឈ្មោះចៅមហោសថបណ្ឌិតអ្នកប្រាជ្ញ អាចផ្ចាញ់ ព្រះបាទចុលណីព្រហ្មទត្តរាជ ហើយនូវអាចារ្យកេវដ្តព្រាហ្មណ៍នោះក្ដី ទើបហៅថាអស្ចារ្យក្រៃកាលក្រៃអេះ ៗ វត្វា តុណ្ហី អហោសិ ព្រះដ៏មានបុណ្យ ព្រះអង្គមានព្រះបន្ទូលសំដែងថ្លែងធ្វើឲ្យជាហេតុជាទំនង –

គន្ធបន្តិចទៅក្នុង ព្រះអង្គគង់ស្ងៀមស្តាប់ពាក្យព្រះពុទ្ធដីកាវិញហោង ។ តេហិ យាចិតោ អតីតំ អាហរិ បពិត្រអើយ ក្នុងកាលនោះ រីអស់ភិក្ខុសង្ឃអង្គអរហន្តាទាំងណា ស្រួតផងទាំងឡាយនោះ បានដឹងហេតុ ព្រះដ៏មានបុណ្យនូវប្រការអម្បាលនោះហើយ សឹងជំលើកកំបង់អញ្ជលី ដាក់លើសិរសាអាត្មាភាព ក្រាបថ្វាយបង្គំប្រណម្យសូមអារាធនាទិមន្ត ព្រះដ៏មានបុណ្យទូលថា ភន្តេ ភគវា បពិត្រព្រះដ៏មានបុណ្យប្រសើរ អើយ សូមទាននាកាលអម្បាញ់មិញនោះ ព្រះអង្គមានព្រះបន្ទូលថាកាល មុននាយនោះ ព្រះអង្គយោនយកកំណើតកើតសម្ភពប្រសូតជាពោធិសត្វ មួយព្រះអង្គ ទ្រង់ព្រះនាមករបវរវិសេសឈ្មោះហៅ ព្រះមហោសថ នោះ គឺពោះយើងខ្ញុំទាំងបានយល់ បានដឹងជាក់ច្បាស់ប្រាកដ ឲ្យធ្លាយ ទូលាយនោះឥតអង្គីមានឡើយ បពិត្រព្រះដ៏មានបុណ្យប្រសើរអើយ សូមទានរីអស់យើងខ្ញុំទាំងអម្បាលនេះ សូមអារាធនាទិមន្តព្រះអង្គ សូម ព្រះអង្គយកនូវប្រាជ្ញាទិព្វវិសេសមួយឈ្មោះ បុព្វេនិវាសានុស្សតិញាណ ដ៏ជាសំណាញ់តែនមកក្រាលឱបក្រសោបនូវព្រះជាតិកំណើតព្រះអង្គនោះ នាំមកចារចែងសំដែងនូវព្រះធម៌វិសេសទេសនា ជាសណ្តាប់ប្រាប់អស់ យើងខ្ញុំនាកណ្តាលជំនុំឥឡូវនេះហោង ។ រីព្រះដ៏មានបុណ្យព្រះអង្គ ស្តេចទ្រង់នូវព្រះសណ្តាប់អស់ភិក្ខុផងទាំងឡាយនោះហើយ ព្រះអង្គ ទទួលយកនិមន្តអស់ភិក្ខុផងទាំងឡាយស្រេចហើយ ទើបព្រះអង្គបន្ទូល

សូត្រជាបទព្រះគាថាដូច្នេះ :

អតីតេ ភិក្ខវេ មិថិលាយំ វិទេហរដ្ឋេ វិទេហោ នាម រាជា រជ្ជំ ការេសិ ។ ប្រែថា ភិក្ខវេ ម្នាលអាវុសោភិក្ខុផងទាំងឡាយអើយ អតីតេ កាលេ ក្នុងកាលកន្លងហួសនូវកប្បកល្បទាំងកំបាំងបាត់ស្ងាត់ កន្ទង់រម្ងង់ទៅហើយនោះ ក្សណនោះ មានមហា·ក្សត្រាធិរាជមួយព្រះអង្គទ្រង់ព្រះនាមករបវរវិសេស ឈ្មោះហៅព្រះបាទវិទេហរាជសោយរាជសម្បត្តិ ស្ថិតនៅដោយនូវទសពិធរាជធម៌សម្មាអាជីវៈចិញ្ចឹមអស់រាស្ត្រប្រជាមហាជនផងទាំងឡាយ នៅក្នុងមិថិលាបុរីស្រីមហានគរបវររាជដ្ឋាន ហើយមានអ្នកប្រាជ្ញទាំង៤ នោះជាអ្នកចេះធម៌អាថ៌សេចក្តីលោកិយលោកា ជាភ្នាក់ងារតែងទូន្មានប្រៀនប្រដៅនៃ ព្រះមហាក្សត្រាធិរាជនោះឯងហោង ។ អ្នកប្រាជ្ញទាំង៤នាក់នោះសោត មួយឈ្មោះអាចារ្យសេនក, មួយឈ្មោះអាចារ្យ បុក្កុស, មួយឈ្មោះអាចារ្យកាមិន្ទ, មួយឈ្មោះអាចារ្យ ទេវិន្ទ ។ អ្នកប្រាជ្ញទាំង៤នោះ សឹងមានប្រាជ្ញាស្មើគ្នាទាំង ៤ នាក់នោះឯងហោង ។

តទា រាជា ពោធិសត្តស្ស បដិសន្ធិគ្គហណទិវ·សេ បច្ចូសកាលេ ឯវរូបំ សុបិនំ អទ្ទស ។ល។ រតិតំ សាសបពីជមត្តម្បិ បញ្ញាយតិ ។ បពិត្រអើយ ពួង

កាលនោះ រីព្រះបាទវិទេហរាជ ស្ដេចចូលទៅផ្ទំនៅក្នុងក្រឡាព្រះបន្ទំ
បរមសុខសួស្ដីប្រសើរ ដ៏ប្រដាប់មានសិរីសួស្ដីប្រពៃ ស្ដេចផ្ទំលក់ជាសុខ
សប្បាយ លុះទៀបហៀបនឹងព្រឹកបែកបច្ចូសកាលផាលប្រាលឡើងស្ដេច
ទ្រង់ព្រះសុបិនក្នុងកាលថ្ងៃនឹងចាប់បដិសន្ធិនៃព្រះពោធិសត្វនោះឯង ។
ព្រះមហាក្សត្រាធិរាជ ស្ដេចទ្រង់ព្រះសុបិន មានសុភាពបន្ទូរថាដូច្នេះ
ស្ដេចយល់ហាក់ដូចភ្នំកើនធំទាំង ៤ ឆេះឡើងភ្លឺរុងរឿង ជាបន្ទាយ
ហាក់យល់ភ្នំឡើងមួយភ្លឺត្រឡង់ប៉ុនអំពិលអំពែក ឆេះជ្រែកផាលពល
លេចឡើងក្នុងកណ្ដាលភ្នំកើនធំទាំង ៤ នោះឯង ដ៏ឆេះផាលពលឡើង
ត្រឡង់ប៉ុនអំពិលអំពែកនោះ សឹងភ្លឺឡើងរៀងរបជរបទៅដល់ព្រហ្ម
នាបេដ៏ពណ្ណរាយល្អ ដ៏អាចឲ្យភ្លឺរុងរឿងទៅដល់សកលកំពែងចក្រវាឡ
ផាលទៅអស់ទ្វីបទាំង ៤ ហើយស្ងិតនៅ ដោយហោចទៅសោត នៅ
សល់ប្រមាណប៉ុនគ្រាប់ស្ពៃ ព្រោយរាយជ្រុសមកក្នុងផ្ទៃក្រោមសឹងដ៏
យល់ប្រាកដ ៗ រីអស់លោកជនព្រមទាំងទេវតា សឹងនាំនូវសាធុការ
បណ្ណាការមកបូជានាភ្នំភ្លើងតូចនេះជាដើម គឺទៀនធូបគន្ធមាលាផ្កា
មាសរតនាករផង ឥតគណនា គ្នារាប់ពុំបានឡើយ ហើយរីអស់
មហាជនផងទាំងឡាយ សឹងដើរទៅដើរមកជុំវិញដ៏ល្វើកភ្លើងនោះ
ក៏ សូម្បីនឹងមានមាត្រាកំដៅដល់ រោមមួយក្ដីក៏មិនក្ដៅឡើយ ។ រីព្រះ
បាទវិទេហរាជ ទ្រង់ព្រះសុបិនស្រេចស្ដេចទ្រង់តើនឡើងអំពីក្រឡា

ព្រះបន្ទំ ហើយស្តេចមានព្រះហឫទ័យនោះ ភិតខ្វាបពុំអាចនឹងទប់បាន ឡើយ ហើយស្តេចតើនឡើងអំពីក្រឡាព្រះបន្ទំ ហើយស្តេចមានព្រះរាជហឫទ័យទ្រង់ព្រះចិន្តាពិចារណាថា ឱ! សុបិនអញនេះ នឹងកើតមានប្រការនោះតើដូចម្តេចទៅអេះ? ព្រះអង្គទ្រង់ព្រះចិន្តាពិចារណាស្រេចហើយស្តេចគង់ស្ងៀមនៅហោង ។

អរុណំ ឧដ្ឋាបេសិ លុះព្រះអាទិត្យដិតផាលប្រាលឡើងបន្តិចកូវ អាចារ្យទាំង ៤ នោះមកកាន់ឋានព្រះមហាក្សត្រអំពីព្រឹកព្រហាមប្រយោជន៍នៅបំរើគាល់ហ្វៅ ចូលទៅក្នុងព្រះរាជមន្ទីរកើ្តអំពីបុកណានៃស្តេចស្រេចហើយ ក្រាបថ្វាយបង្គំប្រណម្យទូលសួរដណ្តឹងថា ទេវបពិត្រព្រះនរបតីស្រីសម្មតិទេពមហារាជក្សត្រថ្លៃអម្ចាស់វិសេសខ្ញុំអើយ នាព្រះអង្គស្តេចផ្ទំកំឡុងរាត្រីនេះ តើជាសុខសប្បាយទូលាយកំឡុងព្រះហឫទ័យថ្លៃឬមួយពុំសុខសប្បាយ? ។ ក្សណនោះ ព្រះបាទវិទេហរាជស្តេចស្តាប់ពាក្យនៃអាចារ្យទាំង ៤ ទូលសួរដណ្តឹងដូច្នោះហើយកូវ ស្តេចបន្ទូលវិញថា ហៃអាចារ្យទាំង ៤ អើយ សុខំ មេ សុខនៃអញ, ន កុតោ នឹងមានអំពីឯណា ហៅអើយ នាអញដេកយប់មិញនេះ អញយល់សប្តិមានសភាពបង្គួរថាដូច្នេះ ។

(នៅមានត)

## ផ្នែកអក្សរសាស្ត្រ

# រឿងមរណមាតា

(តមក)

ដោយលោកបី.សុវណ្ណ បម្លងពីសាស្ត្រស្លឹករឹត

## បទព្រហ្មគីតិ

លង់លុះសាយណ្ហ សូរ្យាទេវទន្ទាចទៅ មរណមាតាពៅ ចូលបង្គំដើមព្រឹក្សា ៗ ស្រេចហើយនាំវិលវិញ វិលទៅដេញគោយាត្រា ឆ្ពោះមកបានគ្រឹហា ដើរដេញបលុះដល់មក ៗ ដល់បានឃ្លានចំណី ស្ងួនឥតបីហ៊ានសួរគេ បាយក្ដាំងទូរបាយកក លុះដល់មកបំរើគេ ៗ ព្រឹកល្ងាចរៀងរាល់ថ្ងៃ កិច្ចការក៏ស្ងួនធួនថៃ រងទុក្ខគេដាក់ដេរ គ្មានបោលល្ហែប្រាណស្រណុក ៗ រងតាំងពីដប់ឆ្នាំ ទុក្ខទ្រូងទ្រាំជាំចាំងមុខ ឆ្អេះឆ្អាបត្រីប្រហុក ភក់អាចម៍គោពោរពេញកាយ ៗ សំពត់មួយបង្កើះ ស្អុយឆ្អាបឆ្អេះផាច់ពោយ ឥតឈ្នួតទីងគ្របកាយ ខ្លួនទទេទុបអង្គប្រាណ ៗ នឿយព្រួយក្តៅក្រោ រកនរណាអាណិតគ្មាន ទោះអត់ទោះស្រេកឃ្លាន ទោះឈឺថ្កាត់ឥតគេថៃ ៗ សុំបាយបានតិចណាស់ ដោយបាតខ្ទះសល់ដែលគេ ស្ងួនអើយសន្សំថៃ បានបរិភោគក្ទះពោះ ៗ មិនដែលឆ្អែតបានម្ដង ស្គមលងងោងស្ទើរមិនរស់ ស្គមឃើញឆ្អឹង

ចាំងអស់ ពោះធ្លូស្បិតដិតផ្អិតខ្ទង ៗ ម្ចាស់ប្រើមិនប្រណី ទីនសុំអ្នកសំពន វែកឈាមផ្តែពោះខ្ទន់ ដូចគេសាប់ឥតបន្ទោះ ៗ មិនមានទឹកប្រណី មេការលើឥតសប្បុរស ខ្ញុំទក់ក្រយមិនអស់ ហើយប្រើគូទក់ក្រយដេរ ៗ គា ស្បូស្មុនកំព្រា ចល់ទុក្ខាមិនមានថ្លៃ លុះយប់នាងរៀបថៃ ទ្រព្យរបស់នាង ដេកទៅ ៗ យាមេអគ្គីរត្ត ទៀបទៅឯពេលយប់ជ្រៅ បិសាចមាតាទៅ ដើមល្អសប្រែកាឡា ប្រែប្រាណដូចនារីស្រី គុលកេសីជាមាតា ដើរដល់ ទៀនគ្រឹហា នាងមរណមាតាទៅៗ ចរចូលគន្ធដំណេក ឃើញកូនដេកកើត មិនសៅ ទាចផ្កាកុលគ្គោ កូលខ្យិកខ្យូលពុំស្រួលស្មោះ។ បុកណៃនសែន អនេក គាណិតពេកពោរពេញពោះ កើតទុក្ខសោកស្រណោះ ទឹក កាស្បូរករុណិតកូន ៗ បិសាចជាមាតា សែនសោកាថានស្ងួន ដេកម្នាក់ ឯងសោះសូន្យ សមកូនស្ងួននាងនោះ ៗ ដេកទុបដៃក្របិត គ្មានសំពត់ គ្របអង្គា កន្ទេលគ្មានក្រឡា ដេកនោបផ្កាល់ចាំ ៗ មាសម្តាយម្តេចពិបាក ខ្ញុំនេភោកយាកម៉េះមាសមៃ កន្ទប់ខ្ទង់ជាំសែ ដូចគេសាប់សត្វបពាត្តិ ។ សំពត់ដាចរយ៉ៃ ស្គមអង្គកាយឃើញតែកង កម្សត់មកផ្តល់នាង ឡើងម៉េះណា មាសមៃ ៗ មួសខាំបោសរៀប ពងពោះសាប់ឥតគេថៃ ម្តាយមើលមុខមាសស្នេហ៍ មាសមៃមានទេលក្ខណ៍គ្រប់ ៗ ដេក លក់មុខប៉ប្រឹម សើចញញឹមស្រស់ចំប្រប់ មិនមានបើកប្រអប់ ពពី មាត់ដូចអស់ស្រី ៗ ដាក់ដៃដូចប្រណម្យ ថ្វាយចន្ទ្រីកែវចាំងច័ សក់

ស្ងួនដាប់សិរសី មិនរបូតសាត់សោយ ។ មិនមានជាមមើ ត្រអៀន
អើប្រុះប្រែក្រាយ ហេតុកម្មប្ងួនឯងម្តាយ យើងតាំងពីមកពីព្រេង ។
ទើបឲ្យកូនស្ងួនងើ បុណ្យច្រើនហោងមែនជាក់ស្តែង តែកម្មនាំ
បង្អែង បំក្លាត់ចេញឲ្យឆ្ងាយបុណ្យ ។ យល់ជាដូច្នោះមាន កម្មបុរាណ
តាមមកទាន់ ជ្រែកចេញឲ្យបាត់បុណ្យ ចូលមិនទាន់ទឹងជួយបាន ។
បិសាចកុលកេសី សោះបុត្រហើយស្រោកស្រាន្ត បន្ទោសោកកំសាន្ត
ហើយថ្លែងថ្លាំកូនថៃថា ។ អំពីនេះតទៅ ចូរកូនពៅបង់ទុក្ខា ម្តាយមក
នៅតេក្បា ដើមល្អួយតាំងពីនេះ ។ ចូរនាងកំហាន្តចិត្ត លែងគិតយកគិត
ចោលឡែសោះ ម្តាយនឹងមើលពិគ្រោះ គិតប្រយោជន៍ឲ្យមាសម្តាយ ។
បិសាចកុលកេសី ប្រាប់បុត្រសព្វស្រុះសាយ សព្វស្រុះពាក្យបរិយាយ
ហើយនិមិត្តទៅបង់បាត់ ។ សាបិតុជ្ជិត្តា កុមារីកាភ្ញាក់ឡើង
ថ្ងាត់ ដៃស្ទាបរកម្តាយបាត់ ពិតពុំយល់កើតទុក្ខា ។ ពិលាបសែន
សោកសល់ នាងនឹកដល់គុណមាតា លើកដៃដាក់សិរសា ប្រណម្យ
សែនសោកសល់ខ្លាត ។ ក្តៅក្តួលក្នុងឥន្ទ្រីយ សោកជននីពីអញ្ញាត្រ
លុះព្រឹកភ្លឺឡើងស្អាត សោកស្រយុតអស់អង្គកាយ ។ ស្ងួនវិរសោយ
ទុក្ខ ទៅលុបមុខលាងផ្ទាំងបាយ បំអិនគោជន៍តាំងឡាយ លើកយក
ទៅជូនបិតា ។ ហើយនាងធ្វើចំណី គោជន៍សាលីត្រីញាំភ្លា ហូប
ហើយនាងគោក្តា ហើយនាងក្រោកបុត្រហា ។ មើលក្រោលឲ្យគោ

ចេញ ហើយនាងដេញទៅម្នីម្នា តៀងតោទៅព្រឹក្សា ដល់ហើយ នាងបេះ ផ្កាក្រ ៗ ម្ទេះរត្តខ្ទឹងម្ទេះលា យុថ្កាមហាហឹង្សមារតី ក្តាំងផ្កាស្រលី ស្រលិត នួនស្រីក៏ការ ៗ ហើយនាងធ្វើចំណី ភោជន៍សាលីត្រីញាំភ្លា ឆត្រទង់ជ៍ រៀបជា ជួរជុំវិញព្រឹក្សានោះ ៗ ហើយនាងលើកក័ស្តុភារ គ្រឿងបូជាដាក់ ចំពោះ បូជាព្រឹក្សានោះ នាងទឹកគន់ចន់ស្រន់ថា ៗអ្នកម៉ែអ្នកមានគុណ គុណ មហាធ្ងន់ឥតឧបមា អញ្ជើញអ្នកមាតា មកទទួលក័ស្តុតាំងឡាយ ៗ នូវអស់ គ្រឿងបូជា តាំងក្រៃផ្កាដែលខ្ញុំថ្វាយ ខ្ញុំបួមសុខសប្បាយ អាត្មាខ្ញុំកំព្រាព្រាត់ ៗ សូមអ្នកម៉ែមេត្តា ប្រែកាឡាឲ្យប្រាកដ ដូចមុនដូចកំណត់ ឲ្យឃើញច្បាស់ ជាក់កុំឃ្លាត ៗ តេជៈនាងសច្ចា ឯមាតាកាឡាស្អាត ជាមនុស្សជាក់សុទ្ធ សាធកុលគេសីស្រីមាតា ៗ ដូចកាលរស់ជាមនុស្ស មុខស្រៀបស្រស់សម កាយា ចេញមកពីព្រឹក្សា ឈរចំពោះមុខទេវី ៗ នាងមរណមាតា លើកហត្ថា ទៀនវន្ទីយ មាតាហើយទេវី អរឥតប្រៀបឥតឧបមា ៗ នាងថាអ្នកម្តាយ អើយ ថ្ងៃនេះហើយស្បើយទុក្ខា កូនយល់ដួងភក្ត្រា អ្នកល្អលន់ពន់ ប្រមាណ ៗ អញ្ជើញអ្នកមាតា មកក្បែតនៅឋាន រក្សាកូនឲ្យបាន សុខ សប្បាយតទៅមុខ ៗ ទោះគោនូវក្របី ឃ្វាលប្រក្រតីសូមឲ្យសុខ ទោះ មនុស្សចិត្តអាក្រក់ សូមរសាយក្លាយបាត់ទៅ ៗ បិសាចស្លាប់បុត្រី ទើបស្រដីថាហៃទៅ មាសមេពីនេះទៅ ម្តាយមកនៅចាំរក្សា ៗ កាក្រែងអស់សត្រូវ កុំកូនទៅព្រួយចិន្តា ថាហើយប្រែកាឡា និមិត្តបាត់

រំពេចទៅ ៗ កុមារីមើលយល់ច្បាស់ កើតទុក្ខក្តាត់សោកសុបសៅ
តាំងពីថ្ងៃនេះទៅ នាងប្រណិប័តន៍ដើមព្រឹក្សា ៗ ព្រឹកល្ងាចជាប្រក្រតី
ធ្វើចំណីភោជនា ផ្កាភ្ញីទៅបូជា រាល់ៗថ្ងៃពុំដែលដាច់ ៗ

បទពំនោល

ន័យនេះឈប់ម៉្វះនិទាន ថ្ងៃឯក្សត្រក្សាន្ត ព្រះបាទនិមលធម្មរាជ ៗ
ឯកអគ្គីទ្រើសទ្រង់អំណាច សេពសុខសោយរាជ្យ បូរីពជកស្ត្រីរដ្ឋា ៗ
មួយថ្ងៃព្រះទ័យក្សត្រា ចង់លេងព្រឹក្សា ក្រសាលកំសាន្តព្រះទ័យ ៗ
ត្រាស់ប្រើអមាត្យឆាប់រៃ រៀបយានប័ប្រពៃ ទីនាំងគជេន្ទ្រប្រញាប់ ៗ
អមាត្យបត់បាទទូនស្តាប់ បន្ទូលបង្គាប់ បង្គំប្រណម្យលុតលា ៗ ទៅ
ប្រាប់បង្គាប់សេនា នៅពលរក្សា គជេន្ទ្រទីនាំងក្សត្រថ្ងៃ ៗ សេនា
យោធាក្រាសក្រៃ រៀបរួចឆាប់រៃ ក៏ឡើងក្រាបទូលក្សត្រា ៗ ស្តេចប្រដាប់
សព្វគ្រប់ប្រការ ព្រះបាទក្សត្រា ស្តេចចេញចុះពេជ្ររ័ត្នរម្យ ៗ ហៅ
អស់នាម៉ឺនតូចធំ អករយាយជួបជុំ បង្គំប្រយ័ត្នរក្សា ៗ រាំងរោះតាំង
បណ្តា ស្រីស្នំក្រមការ ពាំយាមប្រយ័ត្នបរី ៗ ផ្តាំស្អាតព្រះបាទចក្រី
ចេញស្រង់វារី ហើយសោយព្រះស្ងោយខុជា ៗ ពុំលង់ព្រះអង្គ
ក្សត្រា ទ្រង់គ្រឿងរចនា មកុដអាភរណ៍ពាយ ៗ រង្សីរស្មីឆើតឆាយ
ឆើតឆោមពណ្ណរាយ ពព្រាតពព្រោងល្អល្អះ ៗ អស់អង្គគ្រប់ទ្រង់ក្រះ ដូច
ចន្ទ្រថែងច្បាស់ បារមីកណ្តាលវេហា ៗ ទ្រង់ស្រេចសម្តេចក្សត្រា

ចាកទីសុវណ្ណ ស្ដេចយាងព្រះបាទឡើងគង់ ៗ គជេន្ទ្រនរេន្ទ្រកមង្គល
គាប់បញ្ចង់ នរនាថកណ្ដាលយោធា ៗ ថ្កើងអង្គថ្កើងពន្សមហិមា ថ្កើង
រឹទ្ធិចេស្ដា ប្រកបប្រកៃខ្ពង់ខ្ពស់ ៗ ស័ទ្ធត្រៃត្រុំហែពីរេះ ភ្លេងភ្លាត់ប្រគោះ
ប្រគំរងំលើយល្វេង ៗ សេនាចើរដើរឥតក្រែង ឆាត់ធំជាក់ស្ដែង ក្រអឹត
ក្រអួនក្រពា ៗ សំពើមត្រមើមមហិមា បិត្តមុតហានក្លា កំរៀបជង្ហៃជាមុខ ៗ
ចេះសិល្បសាគមគង់គុន ធ្នូតធាប់ពេកពន់ បន្ទុបបង្អាក់ចេះស្ទាត់ ៗ
ពលសេះៗសោតធំធាត់ ក្មៀវក្លាស្ទុះស្ទាត់ កំរៀបក្រោយពលចើរដើរ ៗ
ពលរថប្រាកដច្បាស់ឡើង ពលគជេន្ទ្រថ្កើង បន្ទាប់ទ័នាំងក្បត្រា ៗ ស្ដេច
ចេញចាកប្រាង្គសុវណ្ណ តាំងហោមបត្រា ពួកឆ្រំពង់ពន្ទឹក ៗ កាំភ្លើងបាញ់ព្រួ
សន្ធឹក ស្គរទំពាតត្រឹក គគ្រាំគគ្រេងស័ព្ទសាន ៗ យោធាសេនាទាហាន
ហៃក្បត្រថ្កើងថ្កាន ចរចូលព្រះព្រៃព្រឹក្សា ៗ រំលោងស្រាងស្រាង
សាខា ជិតដើមបព្វតា ស្រឡូតស្រង៉ាត់ទូរគម ៗ គគីរស្ពុរគីរំងក្ដុំ កកោះ
សុក្រំ ត្រសុំត្រភាយសាខា ៗ ព្រះពាយផាត់ផាយបុប្ផា ផ្កុំកូនគន្ធា
ក្រអូបក្រអែបលើបល្វេង ៗ ត្រាចត្រៀកធ្លាធ្លង់ថ្កែស្រែង ទ្រមូងខ្ពុងត្បែង
ទ្រមែងទ្រមួចឆាំរៅ ៗ ស្ពឺស្ពង់ពក់រងើភីការ ភីកុលទន្លា ទន្ទាប់
ប្រដាក់ដើមចាប ៗ ព្រឹក្សានានាដពារ គ្មានខ្ពស់គ្មានទាប មិនតូច
មិនធំស្មើគ្នា ៗ ស្ដេចយាងទៅព្រៃព្រឹក្សា សប្បាយទយា មនោរមា
គេស្រមក្សាន្ត ៗ ព្រឹក្សាផលាផែនមាន ព្រីងព្រួសក្ដុជាន ទ្រមូងទ្រមួច

ខ្ទរោ ។ បេកបាន់សណ្ដាន់សណ្ដា សណ្ដែកទៀបតា· ទឹមទេសធូរទេ លាំងសាត ។ មាក់ប្រាងមាក់សាងមាក់បាត មាក់ដោកស្វាយស្វាត ពន្រើពាជ្រៀងក្រូចក្រាយ ។ យោធាសេនាទាំងឡាយ ឡើងបេះ ប្រញាយ ប្រញាប់ដណ្ដើមគ្នាបេះ ។ ស្វាយកែកាប់មែកប្រឡេះ ខ្ទះ ផ្ទះទេះ ខ្ទះបេះមកថ្វាយក្សត្រា ។ ហើយពលសកលបរិពារ សប្បាយ មហិមា ប្រឡូកប្រឡែងសើចសាទ ។ ស្ដេចដល់មណ្ឌលមួយមាន ស្រះ ស្រង់ជលស្អាទ គន្ធាថ្វាយធំយល់ដី ។ មច្ឆានៅនាស្រះស្រី ច្រើនក្រៃឥត បី ឥតបើរៀបរាប់គណនា ។ ឈូកប្រាលន្ទោលសីងថ្កា ឈូកសបុប្ផា គេសរសំញែងពេញពាស ។ លំបង់ស្បង្កុំដេរដោស សម្បុរដូចមាស បុប្ផាក្រអូបឈ្ងុយឈ្ងប់ ។ ក្សត្រកន្ទុសម្រាន្តក្រោមម្លប់ ពលពាសគ្រាន់ គ្រប់ រៀបសង់ពន្លាថ្វាយក្សត្រ ។ សង់ស្រេចរំពេចរួចថ្វាត់ រួចថ្វាយមហា-ក្សត្រ ស្ដេចឡើងលើពន្លាជ័យ ។ សត្វសត្វស្រងាត់ពេកក្រៃ បបាតប្រ-ពៃ ប្រឡំរងំឆ្លើយគ្នា ។ ប៉ោលតោកកោកទទា ក្រូចក្រៀល សារិកា ត្រលីង ត្រលោងមាទក្រៃ ។ សុរិយាវេលាល្ងាចថ្ងៃ ទំពុងព្រឹក្សព្រៃ ចូលឈប់ ព្រលប់សន្ធ្យា ។ តែងតាំងប្រទីបជ្វាលា ព្រោងព្រាតមហិមា ស្ដេចចូល ក្រឡាបន្ទំ ។ ភ្លេងជួរជន្ត្រីប្រគំ ត្រស័ង្ខស័ព្ទសម. រងំពីរោះមហិមា ។ ចរៀងច្រៀងជួរឆ្លើយគ្នា មានតែសកវាទ សីងដារឿងលោមលេងថ្វាយ ។ សព្ទនោះពីរោះក្បោះក្បាយ សូរស័ព្ទឆ្ងាយ គឹកកងរំពងព្រៃភ្នំ ។ ក្នុងព្រៃ

សត្វរយាសយំ ផ្សាផ្សប់ប្រឡំ ទីងសព្ទចំរៀងសកក៏ ។ ព្រះពាយ
ផាត់ផាយបុប្ផា ការកេសរផ្កា រំពេករំពាកប្រយង្គ ។ រំដួលក្លិនឈ្ងួលធុំហ៊ឹង
ផាយផាត់ត្រូវត្រង់ ក្រអូបក្រៃអបល្អប់ល្អន ។ ក្តាំងឆាបម្យ៉ាមហាហ៊ឹង កន្ទង់
ក្រេតក្រន់ ហើយត្រាច់ត្រេកត្រេះកេសរ ។ ផ្កាផង់ល្អប់ល្អង់ខាយខ្ចរ ក្លិន
ក្រៃបគន្ធ ត្រឡប់តាំងព្រះពន្លា ។ ដោយខ្យល់បក់ដល់ក្សត្រា ឈ្ងុយ
ឈ្ងប់មហិមា ស្រង៉ូតស្រងាត់ហឫទ័យ ។ ឯពួកក្រុមមឿងច្រើនក្រៃ គយ
គន់រំពៃ យាមល្បាតសត្វព្រៃសព្វវាល ។ រាទក្លិនក្លីឡើងវន្ទាល គោម
គុបក្លីប្រាល ពព្រាតពព្រោងពេញព្រៃ ។ ប្រយ័ត្នមហាក្សត្រជៀសជ័យ
កាន់គ្រឿងគ្រប់ដៃ កាំភ្លើងលំពែងស្នាដាវ ។ ដាក់ទ័ពកាយជួរក្នុងក្រៅ
ស្កាត់ខ្ទាត់មកទៅ ក្រវើនក្រវែលគ្មានឈប់ ។ ពួកចោរដើរប្រោមពលគ្រប់
គយល្បាតយាមយប់ មិនឈប់គ្រប់ច្រកព្រឹក្សព្រៃ ។ ស្តេចផ្ទំបរមសុខ
សោយ្យ ស្កលស្កប់ហឫទ័យ លុះព្រាងព្រឹក្សព្រះសុរិយា ។ ស្តេចតើនចាក
ព្រះសុវណ្ណា ស្រប់ព្រះកន្ត្រា រួចសោយព្រះស្រីស៊ួងបាន ។ សេនាយោ-
ធាតាមដាន គង់គល់ច្រើនជាន់ ជាជួរជុំជិតក្សត្រា ។ ទើបស្តេចមានព្រះ
ឧង្ការ បង្គាប់សេនា ឲ្យអស់ពលពាលសេនីយ ។ រៀបយានសូរ្យកាន្តរង្សី
ត្បៀតព្រះចក្រី ស្តេចចេញប្រពាតព្រឹក្សា ។ មន្ត្រីសេនីយសេនា រៀបរង់
ក្សត្រា របបរបៀបរៀបរៀង ។ នាយពួកព្រះក្លស់ព្រះក្លេង ព្រះអង្គស្តាំ
ឆ្វេង ព្រះពាតព្រះស្រីស្រេចស្រាប់ ។ (នៅមានត)

# រឿងក្រុងអេហ្ស៊ីប

## ចែងអំពីការវិនិច្ឆ័យនៃការាឃូស

ភិក្ខុ ម៉ែន - រៀម

សិស្សពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ប្រែចេញពីភាសាអង់គ្លេស

---

នៅប្រទេស អេហ្ស៊ីប កាលណាបើច្បាប់ត្រឹមត្រូវល្អ ត្រូវគេដឹកនាំឲ្យទៅលើផ្លូវលលា ផ្តេសផ្តាស (មិនយុត្តិធម៌) ពួកជនជាតិ អេហ្ស៊ីប តែងពោលសុភាសិតមួយបទឡើងថា "ដូចការវិនិច្ឆ័យនៃការាឃូស" (Judgment of Karakoush) ។

រឿងនេះតើដូចម្តេចទៅ ?

រឿងនេះ មាននិទានថា :

គ្រាមួយ មានចោរម្នាក់ លបចូលទៅលួចទ្រព្យសម្បត្តិ ក្នុងផ្ទះមួយ, វាឡើងតាមរបងសួនច្បារ ទៅប្រឹងគាស់បើកបង្អួចផ្ទះឲ្យបើក ដើម្បីចូល ។ ដោយស៊ុមបង្អួចមិនសូវមាំទាំ ហើយស្រាប់តែរបើកឃ្វាំងឡើងទៅទាំងក្នុងក្តាមនោះ, ចោរក៏របូតហក់ធ្លាក់ទៅក្នុងផ្ទះ បណ្ដាលឲ្យបាក់ជើង ។

ថ្ងៃក្រោយមក ចោរនោះស្រែកថ្ងូរដោយការឈឺចាប់ព្រោះបាក់ជើង ទៅឈរនៅពីមុខលោកចាងហ្វាងតុលាការឈ្មោះ ការាឃូស

បង្ហាញជើងបាក់ដល់លោកតានហ្វាងហើយ វានិយាយប្ដឹងថា:

- ព្រះតេជព្រះគុណ! វិជ្ជាជីវៈ របស់ខ្ញុំបាទគឺធ្វើជាចោរ, ពម្សិលមិញនេះ ខ្ញុំបាទបានចូលទៅកាន់ផ្ទះបុរសម្នាក់ កាលដែលខ្ញុំបាទកំពុងតែខំខ្វេះគាស់បង្អួចផ្ទះឲ្យបើកមកខាងក្រៅ ស្រាប់តែវាបើកឃ្វាំងទៅខាងក្នុងវិញ ធ្វើឲ្យខ្ញុំបាទហក់ធ្លាក់បាក់ជើងដូច្នេះឯង ។

កាពឃូស ស្រែកប្រាប់ពួកអ្នកយាមក្រសួងតុលាការឲ្យទៅនាំខ្លួនម្ចាស់ផ្ទះនោះ មកឲ្យគាត់ ។ ពេលនោះម្ចាស់កម្មសិទ្ធិផ្ទះ តក់ស្លុតជាខ្លាំងដោយសេចក្ដីខ្លាច ព្រោះមិនដឹងជាខ្លួនមានរឿងអ្វី បានជាស្រាប់តែត្រូវគេប្រអូសប្រទាញ មកឲ្យឈរនៅចំពោះមុខលោកតានហ្វាងកាពឃូសដូច្នោះ ។

កាពឃូស បានចាប់និយាយពីការចោទប្រកាន់របស់ចោរ ចំពោះម្ចាស់ផ្ទះ, ហើយគាត់ថែមថា ៖

- ព្រោះហេតុអ្វី បានជាអ្នកឯងធ្វើបង្អួចខ្ជីខ្ជា មិនឲ្យមាំទាំ ដែលជាហេតុឲ្យវាបាក់ចូលទៅខាងក្នុង នាំបណ្ដាលឲ្យមានគ្រោះថ្នាក់បាក់ជើងចោរយ៉ាងនេះ ?

បន្ទុកនៃសំនួរបែបនេះ តើឲ្យគ្នាអ្នកម្ចាស់ផ្ទះឆ្លើយយ៉ាងណា ? ហើយតាំងពីកាលណា ៗ មក ដែលឃើញមានចោរណាមានសិទ្ធិការពារខ្លួន ប្រឆាំងនឹងមនុស្សសុចរិតជាម្ចាស់របស់ដែលវាព្យាយាមលួចបែប

នេះទេ ? ៗ ប៉ុន្តែ ដោយអ្នកម្ចាស់ផ្ទះ បានដឹងថា "ការប្រកែកជាមួយកាកយូស ជាការឥតផល", ទើបគាត់គិតមួយសន្ទុះ រួចឆ្លើយថា :

– ព្រះតេជព្រះគុណ ! បន្ទប់ផ្ទះខ្ញុំបាទ ដែលធ្វើឡើង មិនបានជាប់លាប់ត្រឹមត្រូវនោះ មិនមែនជាកំហុសរបស់ខ្ញុំបាទទេ; ខ្ញុំបាទសូមស្បថជូនថា «រូបខ្ញុំបាទពិតជាបានបង់ថ្លៃឈ្នួលឲ្យជាងឈើគ្រប់គ្រាន់រួចស្រេច ហើយថែមទាំងបានប្រាប់ជាងឈើនោះឲ្យធ្វើបន្ទប់យ៉ាងមាំ ដើម្បីនឹងចៀសវាងគ្រោះថ្នាក់បែបនេះដែរ ទាន !» ៗ

ពេលនោះ កាកយូសបានបង្គាប់ដោយប្រើសំឡេងដូចរន្ទះថា :

– បើយ៉ាងហ្នឹង ទៅនាំជាងឈើមក !

កាលជាងឈើមកដល់, លោកចាងហ្វាងកាកយូស និយាយដោយពិរោះថា :

– អ្នកម្ចាស់ផ្ទះនេះ គាត់និយាយអះអាងថា «ខ្លួនគាត់បានជួលអ្នកឯងឲ្យធ្វើបន្ទប់យ៉ាងមាំឲ្យគាត់ ដោយថ្លៃឈ្នួលពេញលេញ. ចុះហេតុអ្វី បានជាកាលនោះ អ្នកឯងត្រឡប់ជាធ្វើបន្ទប់តគ្រេតគ្រត មិនឲ្យមាំទាំ ដែលជាហេតុបណ្ដាលឲ្យបាក់ដើរហោរកំសត់នេះ នៅពេលដែលវាចំគាស់ឲ្យរបើកនោះទៅវិញ ?

ចំពោះជុំសំនួរនេះ ជាងឈើក័យឡើងមុខស្លាំង ព្រោះគាត់គ្មានទឹកនាដល់ការបោទប្រកាន់បែបនេះឡើយ ៗ ប៉ុន្តែ ជាងឈើក៏បានដឹងថា

« វាគ្មានប្រយោជន៍អ្វី នឹងដៃកកក់ជាមួយ កាកឃូស », ដូច្នេះហើយ បន្ទាប់ពីការឈប់ផ្អាកបន្តិចមក, គាត់ឆ្លើយថា :

– ព្រះតេជព្រះគុណ ! ស្ពឹមបង្អួចដែលមិនជាប់លាប់ត្រឹមត្រូវនោះ មិនមែនជាកំហុសរបស់ខ្ញុំបាទទេ, ពីព្រោះកាលដែលខ្ញុំបាទកំពុងតែ រោះដែកគោល ឲ្យជាប់ត្រឹមត្រូវនោះ មាននារីប្រកបដោយរូបឆោម លោមពណ៌ម្នាក់ ស្លៀកសំពត់ក្រហមឆ្អៅ ដើរកាត់ក្រោមបង្អួចនោះ; ម៉្លោះហើយ ខ្ញុំបាទក៏ទៅជារំភើបខ្វល់ប្រហល់ចិត្ត ដោយសារទិដ្ឋភាព នោះ បណ្ដាលឲ្យខ្ញុំបាទវាយដែកគោលវៀចតែម្ដងទៅ ។

កាកឃូស ចង់ដឹងឈ្មោះស្ត្រីនោះ បានឲ្យគេទៅនាំនាងនោះមក ឲ្យគាត់មើល ។ កាលនាងនោះមកដល់, ចាងហ្វាងកាកឃូស ក៏ ញញឹមដាក់ និយាយឡើងវិញ នូវពាក្យដែលជាងកោរ៍បានថ្លែងប្រាប់ គាត់, គាត់ពោលថា :

– បើកុំតែមានរូបឆោមលោមពណ៌ល្អ និងសំពត់ក្រហមរបស់នាង ឯងហ្នឹង ម៉្លេះសមជាងឈើគ្មានកន្លងភ្ញាក់រំភើបចិត្តដោយសារទេ, បង្អួចក៏ បានមាំល្អ ហើយចោរក៏គ្មានគ្រោះថ្នាក់ធ្លាក់បាក់ជើងដូច្នេះឡើយ ។

ចំពោះការចោទប្រកាន់នេះ, នាងនោះបានឆ្លើយដោយញញឹមថា:

– រូបឆោមដ៏ឆើតរបស់ខ្ញុំ គឺបានមកពីព្រះអាល្ល៉ោហ៍, រីឯសំពត់ ក្រហមខ្ញុំវិញ គឺបានមកពីជាងជ្រលក់ ; ជាងជ្រលក់នោះឯងហើយ

ដែលបានជ្រលក់សំពត់នេះឲ្យក្រហម ធ្វើឲ្យខូចខ្ញុំ ទៅជាទីទាក់ចិត្តនៃជាន់ឈើ ។

កាកយូស ស្រែកបង្គាប់ថា ៖

– ហ៎! បើអ៊ីចឹង ទៅហៅអាជាងជ្រលក់នោះមកឲ្យអញ ។

ពីរ-បីនាទីក្រោយមក ជាងជ្រលក់បានមកដល់, ឈរពីមុខតានីញ៉ូរីកាកយូស ។ ស្រែកសន្ធាប់ថា ៖

– យី! អាជាងជ្រលក់ផ្តេសផ្តាស, គ្មានគិតគ្រែងវែងឆ្ងាយសោះ, ហេតុយ៉ាងម៉េច បានជាឯងជ្រលក់សំពត់នាងនេះឲ្យក្រហម នាំឲ្យមានការទាក់ចិត្តដល់ជាន់ឈើ ដែលជាហេតុឲ្យគាត់ភ័យដៃគេគាលវៀច នាំឲ្យស៊ឺមបង្គួចមិនមាំ ហើយបណ្តាលឲ្យបាក់ជើងបោះនេះ នៅពេលដែលកាំទៅគាស់ខ្មោះឲ្យបើក ? ។

ជាងជ្រលក់សំពត់នឿងឆ្ងល់ ទៅជាឡប់បាត់ស្មារតី ។ គាត់និយាយអង្វរសុំទោស ដោយសំដីជាប់ៗ ច្រើនបែបច្រើនយ៉ាងណាស់, ប៉ុន្តែ សុំទោសយ៉ាងណាក៏ដោយ មិនអាចឲ្យកាកយូសស្ងប់ស្ងាត់បំបាត់ទោលបានឡើយ ។ ទីបំផុត គាត់ស្រែកបង្គាប់ទៅទាហានថា ៖

– នាំគាត់នេះ យកទៅចងព្យួរនឹងទ្វារគុកទៅ! ។

កាលនោះ ដោយជាងជ្រលក់នោះជាមនុស្សខ្ពស់ស្តួក, កាលដែលទាហាននាំគាត់ទៅចងព្យួរនឹងទ្វារគុក, ទ្វារគុកនោះទាបហួស

រកចំណីរមិនកើត ៗ ម៉្លោះហើយតាហាន គំរត់ទៅប្រាប់កាកយូស វិញថា «ពួកខ្ញុំខំចុះមិនកើតទេ ពីព្រោះដានដ្រលក់ខ្ពស់ពេក មិនល្មមនឹងចំណីបានឡើយ» ។

កាកយូស ដែលមិនធ្លាប់ឲ្យគេកោតខ្លាចដោយស្រួល ១ ស្រែកសន្ធាប់ឲ្យតាហានដែលកំពុងតែញាប់ញ័រភ័យតក្កមនោះវិញថា :

– ថយចេញទៅ ! ទៅរកអាដានដ្រលក់ណាដែលទាប មកចំណីរ៉ាវ ជំនួសអាខ្ពស់នោះទៅ !

កាលនោះ តាហានបានចេញទៅតាមបង្គាប់លោកចាងហ្វាង ហើយរកបានដានដ្រលក់ទាបម្នាក់ ៗ ទុកណាជាដានដ្រលក់ទាបនេះ អង្វរករថា ខ្លួនគ្មានទោសពៃរ៍យ៉ាងណាក៏ដោយ តាហានក៏ឥតស្ដាប់សោះ គិតតែពីប្រមូលប្រទាញគាត់ យកទៅចំណីរគ្រន់ទ្វារគុកទាល់តែបាន ១

ដូច្នេះហើយ បានជា ភៅប្រទេសអេហ្ស៊ីប កាលណាអំពើយុត្តិធម៌ ឬហេតុការណ៍បើកផ្លូវទៅរកអំពើលលាផ្ដេសផ្ដាស ដែលគ្រប់ដណ្ដប់បៀតបៀនមកលើអំពើសុចរិតឥតទោសនោះ ហើយឲ្យសេរីភាពទៅលើអំពើអយុត្តិធម៌ គឺថា កាលណាគេយកអំពើអយុត្តិធម៌មកជះជាន់គ្របសង្កត់ពីលើអំពើយុត្តិធម៌ ដោយឲ្យសេរីភាពទៅលើអំពើអយុត្តិធម៌វិញនោះ ពួកជិតជាតិអេហ្ស៊ីប តែងនិយាយថា:

« ដូចតារ៉ាវិនិច្ឆ័យនៃកាកយូស » ។

# សុភាសិតជាតិប៊ុល(១) នឹងទូគូល្មើរ(២)

លោក ភិយ-ប៊ុក ប្រែពីភាសាបារាំង

---

១– ចិត្តមិនមែនដូចដង្គត់ ដែលគេបត់បែនបានតាមបំណងទេ ។

២–សេចក្ដីស្នេហាប្រៀបដូចជាសត្វលា ដែលគេផ្ដាច់កន្ទុះចេញ ។

៣– អង្កាម បើទុកជាមានពណ៌សម្បុរស្រស់យ៉ាងណា ក៏គេមិនអាចយកទៅធ្វើជាម្សៅបានទេ ។

៤– កល្យាណមិត្តមានប្រាជ្ញា ប្រសើរជាងកល្យាណមិត្តល្ងង់ខ្លៅ ។

៥– ស្រឡាញ់នារីដែលគេមិនស្រឡាញ់ខ្លួន ប្រៀបដូចជាយកដំបងគោះក្ដួនឈើតូច ឲ្យជ្រុះទឹកសន្សើម ។

៦– ការប្រាស្រ័យនឹងមនុស្សល្ងង់ខ្លៅ ដូចមនុស្សមានម្រាមដៃមួយដំបៅ បើកាត់ម្រាមដៃនោះចេញនាំឲ្យឈឺ បើទុកម្រាមដៃនោះដំបៅនឹងធ្វើឲ្យពង្រុះឈាមរលុះរលួយមិនខាន ។

៧– បើយើងចង់ដើរឲ្យឆាប់រហ័សតាមផ្លូវ ត្រូវកុំទៅជាមួយនឹងសត្វបន្ទាយ ។

៨– ត្រូវទៅម្នាក់ឯង ប្រសើរជាងទៅជាមួយមនុស្សពាលទុច្ចរិត ។

៩– អ្នកណាដែលមិនបានជ្រើសរើសទឹកខ្ទឹង មុននឹងអង្គុយ

---

(១) ជាតិប៊ុល ៖ ជាប្រជាជាតិនៃទ្វីបអាហ្វ្រិក សម្បុរស្បែកស ។ (២) ជាតិទូគូល្មើរ ៖ ជាជាតិសេណេកាល់ ដែលជាកូនកាត់ពួកជាតិប៊ុល នឹងជាតិស្បែកខ្មៅ ឬពួកអូរ ។

ដល់អគ្គិយទៅ មុខជាក្រោកឡើងជាប់ចំបើងនឹងខោអាវមិនខាន ។

១០- នារីដែលគ្មានទរណាទូន្មាន ច្រើនតែមានប្ដីអកុសល ។

១១- នារីជាទឹកត្រជាក់ ដែលធ្វើឲ្យបុរសស្លាប់ ឬទឹកជ្រៅល្អម នឹងធ្វើឲ្យបុរសលិចលង់បាន ។

១២- តាមដល់ពេលអនុណោះ តែងហើរទៅរកស្រែចម្ការ មិន ដែលឃើញស្រែចម្ការមករកតាមទេ ។

១៣- កិច្ចការអ្វីដែលគេពិសោធតាំងពីបុរាណកាលមកមិនបាន ការ យើងត្រូវតែលះបង់ ។

១៤- បុរសជាអ្នកធ្វើគេហដ្ឋានឲ្យសំបូណ៌ដោយគោគទ្រព្យ ប្រពន្ធ ជាមេគេហដ្ឋាន ។

១៥- អ្នកដែលជាមេគ្រួសារ ត្រូវតែធ្វើក្អែកខ្វាក់ត្រចៀកថ្លង់ បើ មិនដូច្នោះទេ គ្រួសារនោះនឹងអន្តរាយតទៅអនាគត ។

១៦- ការបិតនៅម្នាក់ឯង ប្រសើរជាងការបិតនៅជាមួយ មនុស្សពាលទុច្ចរិត ។

១៧- គេហដ្ឋានសង់នៅជិតគ្នាពុំប្រសើរឡើយ ចិត្តបិតនៅជិត គ្នាប្រសើរជាង ។

១៨- បើពាក្យសួរជាប្រាក់ ពាក្យឆ្លើយនឹងទៅជាមាស ។

១៩- គេដឹងព្រឹក្សាដែលមានផ្លែច្រើន តាំងពីវាចេញផ្កា ។

២០- ផ្លែដែលគេលីលើស្មា នឹងបាច់ម្រឹគមិនបានទេ ។

២១- គេលញ់ដីឥដ្ឋក្នុងពេលវានៅទន់ ។

២២- ព្រះរាជអាណាចក្រ ភរិយា នឹងកាំភ្លើង គេមិនដែលឲ្យអ្នកដទៃខ្ចីទេ ។

២៣- បើទុកជាចចកសូត្រធម៌ទាំងយប់ទាំងថ្ងៃ កូនពពែក៏នៅតែមិនទុកចិត្ត ។

២៤- អ្នកដែលមិនធ្លាប់ឆ្លងទន្លេ មិនត្រូវប្រមាថមើលងាយអ្នកដែលលិចលង់ក្នុងទន្លេនោះទេ ។

២៥- ស៊ូឲ្យស្អប់ កុំឲ្យប្រមាថមើលងាយ ។

២៦- សំលៀកបំពាក់បិទបាំងកាយបាន តែមិនអាចបិទបាំងពូជអំបូរបានទេ ។

២៧- អ្នកមានភោគទ្រព្យ គង់ចៀសក្រមិនរួច ។

២៨- អ្នកឈ្នះ គង់ថ្ងៃណាចាញ់មិនខាន ។

២៩- សេចក្ដីស្រេកឃ្លានជារោគ មានអានុភាពជាងរោគទាំងឡាយ ។

៣០- អាហារដែលឆ្ងាញ់ពីសា គឺអាហារដែលគេនាំមកដល់កំពុងឃ្លាន ។

៣១- ការទើបនឹងទទួលទុក្ខលំបាកម្ដង មិនមែនធ្វើឲ្យរហែក

ពោះនោះទេ ។

៣២- មនុស្សមិនមែនដូចជាហោប៉ៅស្បែក ដែលគេជ្រើសរើសយកតែធំនោះទេ ។

៣៣- មាសនឹងទង់ដែង មើលមួយភ្លែត មានសភាពប្រហែលគ្នា តែធម្មជាតិខាងក្នុងនៃវត្ថុទាំងពីរនោះខុសគ្នា ។

៣៤- កាំភ្លើងស្ងិតនៅស្ងៀម តែវាមិនមែនគេទេ ។

៣៥- ទឹកពិតមែនតែត្រជាក់ តែអាចសម្លាប់មនុស្សបាន ។

៣៦- បើឯងពោលពាក្យ ត្រូវពោលតែពាក្យ ចំពោះអ្នកណាដែលស្តាប់បាន ។

៣៧- បើវាចាឈឺ ឲ្យតែត្រចៀកជាបានហើយ ។

៣៨- អ្នកណាអួតខ្លួនឯង អ្នកនោះនឹងស្អប់ខ្លួន ។

៣៩- ចូរទុកឲ្យក្រពតវាប៉ោងតាមចិត្តចុះ កាលណាវាបែកពោះវាឈប់ប៉ោងឯង ។

៤០- អ្នកណាកាន់អាហារឆ្ងាញ់ អ្នកនោះមុខជាលើកអាហារតម្រង់ចំមាត់ខ្លួនមិនខាន ។

៤១- វត្ថុជារបស់ខ្លួនប្រសើរជាងវត្ថុអ្នកដទៃ ។

៤២- ទទួលចំណែកនៃភោគទ្រព្យ ប្រសើរជាងការទទួលពរ ។

៤៣- អ្នកណាលោភ អ្នកនោះមុខជាមានសេចក្តីទុក្ខលំបាកមិន

ទាន ។

៤៤ - អ្នកដែលឡើងដើមឈើធំទើបបានបេះផ្លែបរិភោគ អ្នកដែលគ្រាន់តែស្ថិតនៅក្រោមដើមឈើធំនោះ ប្រាកដជាវិលត្រឡប់មកផ្ទះវិញទទេ ។

៤៥ - ទន្លេបើទុកជាមានទឹកពេញព្រៀបយ៉ាងណាក៏ដោយ នៅតែចង់បានទឹកថែមទៀត ។

៤៦ - អ្នកណាពោលថា អញចំណេញ អ្នកនោះនឹងញុំាងក្រឡ ដេញតាមពីក្រោយ ។

៤៧ - អ្នកណាចង់បានកូនហួសប្រមាណ អ្នកនោះមុខជារៀបវិវាហមង្គល នឹងស្ត្រីដើមមិនខាន ។

៤៨ – អណ្តាត បើវាទៅជាសិង្ហ វាលោតខាំម្ចាស់វា ។

៤៩ – អណ្តាត វាលក់ក្បាលម្ចាស់វា ។

៥០ – អណ្តាតចិញ្ចឹមមាត់ ។

៥១ – កុំមើលអ្នកបានលាភ ត្រូវមើលអ្នកឲ្យលាភវិញ ។

៥២ – មានពាក្យពិតខ្លះ ដែលគេមិនអាចពោលបាន សូម្បីពោលទៅដើម្បីស្រោចស្រង់ជីវិតបិតាក៏មិនត្រូវពោលដែរ ។

៥៣ – បើអ្នកណាស្គាល់ឯង ហើយស្អប់ឯង អ្នកនោះមុខជានិយាយតែពាក្យអាក្រក់ពីឯង ។

៥៤- វាចាប្រៀបដូចជាទឹក ទឹកបើហូរចេញពីទីកន្លែងណាហើយ មិនដែលត្រឡប់មកកន្លែងដើមវិញទេ ។

៥៥- អ្នកដែលគ្រាន់តែនិយាយ ហើយមិនធ្វើ រមែងមិនសម្រេចប្រយោជន៍អ្វីឡើយ ។

៥៦- សច្ចៈជាមាស មាសបើគេកប់ទុកក្នុងដីឬទុកក្នុងទូ ក៏នៅតែមាសដដែល ។

៥៧- ចិត្តជាធម្មជាតិរហ័សណាស់ ដូចសេះដ៏លឿន ប៉ុន្តែមិនអាចលះវិចិកិច្ឆាឲ្យស្រឡះបានទេ ។

៥៨- បើពាក្យកុហក នៅតាមផ្លូវពីព្រឹក សច្ចៈចេញដំណើរពេលល្ងាច សច្ចៈនោះនឹងដេញទាន់កុហកមិនខាន ។

៥៩- ពាក្យកុហកក្តៅដូចទឹកពុះ តែមិនអាចចំអិនវត្ថុអ្វីបានឡើយ

៦០- មុននឹងពោលពាក្យផ្ទុសវាទ ចូរឯងក្រឡេកមើលពីក្រោយខ្នងឯងសិន ។

៦១- រុក្ខជាតិមានផ្កា ពួកភមរជាតែងនៅបោមពេម ។

៦២- ការដើរសូមទានគេ មិនអាចធ្វើខ្លួនឲ្យទៅជាសេដ្ឋីបានទេ ។

៦៣- អ្នកណាមួយកំពុងមានកំលាំងមិនធ្វើការ បែរទៅជាដេក អ្នកនោះនឹងត្រូវក្រោកឈរឡើងវិញ ដល់ពេលខ្សោយធ្វើការមិនកើត ។

៦៤- ចំណេះដូចគ្នានឹងចម្ការ បើចម្ការនោះមិនបានភ្ជួររាស់ មិន

បានថែទាំ លទ្ធផលក៏គ្មាន ។

៦៥– បើចង់ឲ្យបាតដៃស្អាត ត្រូវយកបាតដៃទាំងពីរដុសគ្នាទៅវិញទៅមក ។

៦៦– អ្នកមានចិត្តខន្តីជាគ្រូមនុស្សក្នុងពិភពលោក អ្នកគ្មានចិត្តខន្តីមិនអាចធ្វើគ្រូអ្នកដទៃបានទេ ។

៦៧– អ្នកណាមិនមានចិត្តខន្តីចំពោះការរងផ្សែងភ្លើង អ្នកនោះនឹងមិនបានច្បងឈើទេ ។

៦៨– បើចង់បានទឹកឃ្មុំ ត្រូវតែកុំខ្លាចឃ្មុំទិច ។

៦៩– ការរហ័សហួសប្រមាណនឹងធ្វើឲ្យខូចខាតមិនខាន ។

៧០– ដាស់មនុស្សដែលដេកលក់ស៊ប់ ប្រសើរជាងដាស់មនុស្សដែលធ្វើជាដេកលក់ ។

៧១– មនុស្សមាន ៣ ពួកគឺ ពួកទី ១ ប្រៀបដូចចំណីគ្មានអ្នកណាជៀសវាងរួច ត្រូវតែចូលទៅជិតខានមិនបាន ។ ពួកទី ២ ប្រៀបដូចជាឱសថ មានគេត្រូវការមួយដងមួយកាល ។ ពួកទី ៣ ប្រៀបដូចជារោគ គ្មានអ្នកណាត្រូវការសោះឡើយ ។

៧២– គ្រឿងសំលៀកបំពាក់ចាស់ សម្រាប់ការពារគ្រឿងសំលៀកបំពាក់ថ្មី ។

៧៣–ខ្លួនមិនមែនជាពស់ ទៅបរិភោគអាហារពស់មុខជាស្លាប់មិនខាន ។

៧៤– ជីញ្ជក់ដែលដេកផ្ងារពោះ ខ្នងទល់ដី គឺជីញ្ជក់ស្លាប់ ។

# រឿងសាមកុក

## កណ្ឌទី ៣៩

ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

| |
|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ |
| អ្នកវាងវៃឆ្លាសបើបានអាន |
| នឹងចេះឧបាយកលបំណាន |
| ទាំងមានសន្តានស្នេហាជាតិ។ |

តាំងពីជីវបីដឹងថា ក្លួលើកទ័ពមកក្នុងស្រុកកេងជិវ ជីវឃីមកដល់ស្រុកកាំងតាំង ស្លុះអាសាក៏ខ្ចួនឲ្យចៀមទ័ពធំ លើកទៅតាំងស្រុកកាំងហែ ទៀតពីកៅរកជីវឃីដល់បន្ទាយ ក្លួមានសំបុត្រទៅដល់ជីវបី ។

---

នាងនឹកុកថៃនិយាយថា កូនអើយ! កាលបងអ្នកឯងជិតនឹងមរណភាពបានផ្តាំទុកថា ការអ្វី ៗ ខាងក្នុង បើមិនសម្រេច ក៏ឲ្យប្រឹក្សាសាកសួរទៀវបៀវ ការអ្វីខាងមុខ បើមិនសម្រេចឲ្យសួរជីវយី សេចក្តីទាំង ២ ខនេះកូនភ្លេចហើយឬ ? ។ ស៊ុនក្វនឮដូច្នោះ ក៏ត្រេកអរឃើញបានដូចគេស្រង់ទុក្ខអស់ចេញ ប្រៀបដូចដេកលក់ហើយភ្ញាក់ឡើង មានសេចក្តី

ត្រេកអរណាស់រកទីបំផុតគ្មាន ទើបបង្គាប់មនុស្សបំរើឲ្យទៅប្រាប់ជីវយើឯស្រុកគួនយ៉ុន លុះបំរើមិនទាន់ចេញទៅ ទទួលជីវយើដឹងថា ចូចូលើកកងទ័ពមកតាំងនៅជាយទន្លេស្រុកកេងជីវ បំណងនឹងមកវាយយកស្រុកកាំងតាំង ជីវយើក៏ស្រូតរូតចូលមក ។

ឡោស៊ុកដឹងថា ជីវយើមកដល់ក៏រួសពន់ទៅសួរ ហើយប្រាប់សេចក្ដីដែលស៊ុនគួនប្រឹក្សាពិគ្រោះរិះគិតតបរាំងនឹងចូចូនោះគ្រប់ប្រការ ។ ជីវយើថា ការនេះអ្នកកុំតក្កអីឡើយ ទុកជាធុរៈលើខ្លួនខ្ញុំចុះ ខ្ញុំនឹងបានរិះគិតធ្វើការនោះ អ្នកចូរស្រូតជាប្រញាប់ទៅអញ្ជើញខុងបេងឲ្យមកជួបនឹងខ្ញុំបន្តិចចុះ ។ ឡោស៊ុកក៏ឡើងសេះប្រញាប់ទៅអញ្ជើញខុងបេង ។

ខណៈនោះទៀវចៀវ, កោះយ៉ុង, ទៀវហៀន, ប៉ោជិត ចូលទៅសួរជីវយើគំនាប់គ្នាហើយ ទៀវចៀវសួរថា អ្នកទៅធ្វើការឯស្រុកគួនយ៉ុននោះ បានឮដំណឹងកិច្ចការរាជការដូចម្ដេចខ្លះ? ។ ជីវយើឆ្លើយថា មិនដឹង ។ ទៀវចៀវថា ឥឡូវចូចូលើកកងទ័ពមកតាំងនៅជាយទន្លេស្រុកកេងជីវ ឲ្យមានសំបុត្រមកបញ្ចុះបញ្ចូលស៊ុនគួន ឲ្យចេញទៅទទួលចំណុះទើបមិនប្រទូសរ៉ាយ តែឃើញថាមិនមែនជាពាក្យសុចរិត គិតប្រទូសរ៉ាយយើងជាប្រាកដ អស់យើងខ្ញុំបានពិគ្រោះប្រឹក្សាថា ត្រូវឲ្យស៊ុនគួនចេញទៅទទួលចំណុះតាមប្រវេណី ឥឡូវឡោស៊ុក ទៅនាំខុងបេងមកនិយាយនឹងទៅហ្វាយយើង នឹងឲ្យចេញទៅតស៊ូនឹងចូចូ ទាំងខ្លួន

ទៅស្រុកក៏យល់ឃើញដូច្នោះដែរ យើងខ្ញុំពលគ្នាមិនពេញចិត្ត ព្រោះឃើញថា ខុងបេងនោះខុសគ្នានឹងច្បាប់ រឺគិតតែសងសឹកគ្នាជាជាប់ ទងជឿកាន់យកពាក្យនោះជាពិតប្រាកដមិនពាន់បាន សេចក្តីទាំងអម្បាលនេះក៏នៅមិនទាន់ចុះសម្រុងគ្នា ទទួលចាំតែអ្នក ឥឡូវអ្នកឯកឯលហើយ ចូរទៅប្រឹក្សាឲ្យឃើញច្បាស់លាស់ខុសនឹងត្រូវចុះ ។

ជីវយើឮដូច្នោះក៏សួរថា អស់អ្នកពលគ្នាប្រឹក្សាយល់ថាឲ្យចេញទៅគំនាប់ចុងនោះព្រមគ្នាហើយឬ ? ។ ទៀវទៀវថា ទប្រឹក្សាយល់ឃើញព្រមគ្នាហើយ ។ ជីវយើថា ដែលនឹងទៅគំនាប់ចុងនោះ ខ្ញុំក៏យល់ឃើញដែរ តែថាវេលានេះអ្នកនាំគ្នាទៅវិញសិនចុះ ចាំព្រឹកស្អែកសឹមខ្ញុំទៅជួបនឹងស៊ិនគួន ប្រាប់និយាយឲ្យចុះសម្រុងគ្នាតែម្តង ទប្រឹក្សាទាំងអស់ក៏លាទៅវិញ ។ ទៀវតៅ នឹងហានតុង អ៊ុយកាយ ខាងពួកតា-ហានក៏ចូលទៅរកជីវយើគំនាប់ហើយនិយាយថា លោកដឹងឬទេ ? ស្រុកកាំងតាំងនេះ ជារបស់អ្នកដទៃហើយ ។ ជីវយើតបថា ខ្ញុំមិនដឹងសោះ ។ ទៀវតៅ ឆ្លើយថា យើងខ្ញុំពលគ្នាជាខ្ញុំពឹងការពារបស់បិតាស៊ិនគួន មានសេចក្តីឧស្សាហ៍តាមមក ស៊ូធ្វើការច្បាំង ១០០ គ្រា មិនបានគិតដល់ជីវិត លុះបានមកតាំងខ្លួននៅស្រុកកាំងតាំងនេះ ឥឡូវចៅហ្វាយខ្ញុំជឿស្តាប់ពាក្យសំដីប្រឹក្សាទាំងពួង នឹងលើកយកស្រុកទៅ

ប្រគល់ឲ្យប្អូនកែសេចក្តីអៀនខ្មាសគ្នាន យើងខ្ញុំពល់គ្នាចាំទ្រាំអត់សង្កត់ចិត្ត គិតមិនឃើញផងសោះ គ្រានេះអ្នកគំអញ្ជើញមកហើយ សូមឲ្យទៅនិយាយជំរាបដល់ស៊ិនគួន កុំឲ្យធ្វើតាមពាក្យអ្នកទាំងអម្បាលណោះ ត្រូវតែការពារស្រុកទុក ទោះបីប្អូនលើកមក យើងខ្ញុំពល់គ្នានឹងយកជីវិតដាក់ជាមុខ ស៊ូចំប្រាំងទាល់តែស្លាប់ទៅចុះ ។

ដីវយីសួរថា អ្នកទាំងអស់ យល់ឃើញព្រមគ្នា ហើយឬ? ។ អ៊ុយកាយព្ទះហើយ ក្រោកឡើងយកដៃទាប់ក្បាលកន្ត្រាក់ធក់ហើយថា ទោះបីក្បាលនេះនឹងធ្លាក់ចេញ ក៏មិនទៅសុំលំអុតលំឱនប្អូនឡើយ ។ នាយទាហានទាំងពួងក៏ស្រែកឡើងព្រមគ្នាថា យើងក៏ជាចិត្តមួយនឹងគ្នាទាំងអស់ៗ ដីវយីថា អ្នកពល់គ្នាយល់ឃើញព្រមគ្នាដូចម្តេច យើងក៏យល់ឃើញតាមដែរ តែវេលានេះឲ្យត្រឡប់វិលទៅវិញសិនចុះ ព្រឹកស្អែកយើងនឹងទៅជួបស៊ិនគួន ទើបនិយាយឲ្យចុះសម្រុងគ្នាបាន ។ ទៀវកៅនូវអស់នាយទាហានក៏គំនាប់លាដីវយីចេញទៅ ។

វេលាល្ងាច ឡោសុកក៏នាំខុងបេងទៅជួបនឹងដីវយីៗ ឲ្យអង្គុយទីសមគួរហើយ ឡោសុកក៏សួរដីវយីថា ឥឡូវប្អូនគិតនឹងប្រទូសព័យយើងៗ នឹងចេញទៅគំនាប់ដោយល្អឬនឹងធ្វើប្រការម្តេច សូមឲ្យអ្នកមានប្រសាសន៍ឲ្យច្បាស់ចុះ ។ ដីវយីថា ឯប្អូនគិតធ្វើការទាំងនេះ គឺកាន់យកព្រះតម្រាស់ព្រះចៅហៀនតេជាធំ យើងនឹងរឹងទទឹងសោតក៏ដូច

ជាចិត្តក្បត់នឹងផែនដី  មួយៈទៀតទាហានចចកក៏ច្រើនសរុបតែមានថ្វីដៃខ្លាំង ពូកែណាស់  ខាងយើងក៏មានទាហានតិចស្តួចស្តើង  ឃើញថាតស៊ូនឹង ចចកមិនបាន  បើប្រសិនជាចេញទៅលំអុកលំទុនចចកវិញប្រហែលជា បានសេចក្តីសុខ  ខ្ញុំយល់ឃើញដូច្នេះជាប្រាកដ  វេលាព្រឹកស្អែកនឹង ចូលទៅដំកបស៊ិនគួនឲ្យប្រើមនុស្សចេញទៅគំនាប់តាមប្រវេណី ។ ឡោ- សុកបានឮដូច្នោះខឹងណាស់ឆ្លើយថា  អ្នកនិយាយនោះខុសណាស់  ឯអា- ណាខេត្តស្រុកកាំងតាំងនេះ  បាននិយាយរាជការជាតំណាមក  លុះដល់ ពាជួរមនុស្សហើយ  មិនដែលទៅចំណុះចុះចូលអ្នកឯណា  គ្រានេះអ្នក លើកទៅឲ្យចចកនោះព្រោះឃើញប្រយោជន៍អ្វី  កាលស៊ិនសេកនឹងដល់ សេចក្តីស្លាប់នោះ  បានផ្តាំទុកនឹងខ្ញុំថា  ឲ្យជួយទំនុកបំរុងស៊ិនគួនជាប្អូន ប្រាថ្នាថានឹងឲ្យស្រុកកាំងតាំងនៅខ្ជាប់ខ្ជួនដូចបានបង្អែកទៅលើគ្នា  ហេតុ ម្តេចបើការភ័យអាសន្នមកដល់ហើយ  អ្នកត្រឡប់លះបង់មិនជួយទំនុក បំរុងវិញ  បណ្តោយទៅតាមពាក្យមនុស្សប្រចុចប្រចែង  ផ្តេសផ្តាស ដូច្នេះ ៗ  ដីវយើថា  ស្រុកកាំងតាំងនេះមានអាណាខេត្តឡើងដល់ ៦ មណ្ឌល  មនុស្សចំណុះស្រុកក៏ច្រើន  បើយើងប្រាថ្នាឲ្យតស៊ូនឹងចចកគ្រា នេះ  ក៏ដូចជាធ្វើឲ្យអាណាប្រជានុរាស្ត្របានសេចក្តីទុក្ខក្តៅ  នឹងមាន ពាក្យគរហានិន្ទាដល់យើងម្នាក់ឯង  ហេតុដូច្នេះទើបយើងឲ្យស៊ិនគួនចេញ ទៅគំនាប់ចចកប្រាថ្នានឹងឲ្យបណ្តារាស្ត្របានសេចក្តីសុខ ។

ខុនបែនឃើញជីវយើទឹងឡោសុកដេញដោលគ្នាមិនចុះរុះ ក៏អង្គុយញញឹមចាំស្តាប់ ។ ជីវយើថា អ្នកសើចចំអកខ្ញុំឬ ? ។ ខុនបែនថា ដែលខ្ញុំសើចដូច្នេះមិនមែនចំអកឲ្យអ្នកទេ ខ្ញុំអត់ញញឹមទឹងឡោសុកមិនបាន ព្រោះគ្មានដឹងលក្ខណៈខុសត្រូវអ្វីសោះ មានតែមាត់និយាយហើយមកដេញដោលអ្នក ។ ឡោសុកថា ហេតុម្តេចបានជាលោកអាចារ្យសើចចំអកឲ្យខ្ញុំថាមិនដឹងអ្វីដូច្នេះ ។ ខុនបែនថា ដែលជីវយើនិយាយនោះ គឺឲ្យទៅគំនាប់ណេនត្តួច្ចូ ខ្ញុំក៏យល់ឃើញដែរ ។ ឡោសុកថា ហេតុម្តេចបានជាលោកមកចោទដូច្នេះវិញ ។ ខុនបែនថា ឯបួច្ចូនោះមានគំនិតគិតដោយបញ្ញាយ៉ាងសុខុមជ្រៅទូលាយណាស់ ដឹងចាត់ចែងទាហាន កងការសង្គ្រាមថាធ្ងន់ឬស្រាល បើយើងទៅប្រឹងតស៊ូនឹងបួច្ចូ ក៏រមែងដល់នូវសេចក្តីវិនាសដល់ជីវិតពុំខាន ទៀតពីទៅហ្វាយខ្ញុំក៏គាន់ទិដ្ឋមានៈហានតស៊ូនឹងបួច្ចូ ក៏ដល់នូវសេចក្តីព្រួយលំបាកចាល់តែក្លាត់មកនៅស្រុកកាំងហែ ឯជីវយើជាមនុស្សបេះគិតល្អិតល្អណាស់ ទើបអាចលះទិដ្ឋិទៅគំនាប់បួច្ចូ ប្រាថ្នានឹងរក្សាបុត្រភរិយាទីងអាណាប្រជារាស្ត្រ ប្រុងឲ្យបានសេចក្តីសុខ នោះក៏គួរហើយ ។ ឡោសុកខឹងណាស់ថា លោកនិយាយនេះដូចដឹកដៃខ្ញុំទៅលុតជង្គង់គំនាប់បួច្ចូ អាសត្រូវពងសម្បត្តិគួរហើយឬ ? ។

ខុនបែនថា អ្នកកុំខឹងនឹងខ្ញុំឡើយ ដែលទឹងទៅគំនាប់បួច្ចូនោះ

ខ្ញុំមិនឲ្យលំបាកទេ ចំពោះតែខ្លួន ១ ត្រូវជូនទឹកទន្លេទៅ បើលោកអ្នកមិនទៅក៏បានដូចគ្នា ហើយឧបាយរបស់ខ្ញុំ ៗ នឹងយកតែមនុស្ស ២ នាក់ ចុះទូកតូច ១ ជូនទៅកេប្តី ៗក៏នឹងនាំទាហាន ១០០ ម៉ឺន លើកទ័ពត្រឡប់ទៅវិញភ្លាម ៗ ជីវយើសួរថា ដែលអ្នកនឹងឲ្យមនុស្សតែ ២ នាក់ជូនទៅកេប្តីក៏អាចនឹងឲ្យប្តីលើកទ័ពត្រឡប់ទៅវិញនោះដូចម្តេច? ចូរថាឲ្យច្បាស់សិន ៗ ខុងបេងថា កាលខ្ញុំនៅឯភ្នំងឿឡុំងកាំងនៅឡើយនោះ ខ្ញុំដឹងថាប្តីឲ្យធ្វើប្រាសាទទុកនៅកន្លែង ១ ប្របឆ្នេរទន្លេចៀងហោជាទីសប្បាយ ហើយបាត់យកស្រីដែលមានរូបល្អមកទុកជាច្រើន ព្រោះចិត្តប្តីនោះក្រាស់ក្នុងផ្លូវកាមគុណខ្លាំង ហើយដឹងថានាងទៀវកុកឡោ នៅស្រុកកាំងតាំងមានបុត្រី ២ នាក់ មានរូបល្អស្អាតនឹងកេស្រីឯទៀតផ្ទឹមស្មើគ្មាន ប្តីមានចិត្តកំណាន់ក្នុងការប្រតិព័ទ្ធ បាននិយាយទុកថា បើច្បាំងយកស្រុកកាំងតាំងបានហើយ នឹងទទួលយកស្រីទាំង ២ នាក់នោះនៅទុកជាទីបំរើផ្គាល់ខ្លួន ទោះបើនឹងស្លាប់ទៅក៏មិនបានវិលវល់ក្នុងសន្តានចិត្ត ដែលប្តីលើកទ័ព ១០០ ម៉ឺនមកនេះក៏ព្រោះប្រាថ្នាចង់យកស្រី ២ នាក់ជាប្រុសគល់ក្នុងចិត្ត ប្រសិនបើអ្នកយកមាសតែមួយតម្លឹងទៅជូននាងទៀវកុកឡោ ទិញយកបុត្រីទាំង ២ នាក់នោះទៅជូនប្តីបានដូចសេចក្តីប្រាថ្នារបស់ប្តីហើយ ប្តីក៏លើកទ័ពត្រឡប់ទៅវិញជាប្រាកដ សូមឲ្យអ្នករិះគិតថ្នាក់ថ្នមធ្វើតាមពាក្យខ្ញុំនេះ

ចុះ បើបានហើយមិនព្រួយដៃគន្លាតទៅទៀតឡើយ ៗ ជីវយីថា ដែលបួនមានសេចក្ដីគំណាន់ចិត្តគិតប្រតិព័ទ្ធចំពោះស្ត្រីទាំង ២ នាក់នោះ ហេតុម្ដេចបានជាអ្នកដឹងប្រាកដ មានអ្វីជាកស្តុតាងនៅខ្វះ ? ៗ

ខុនបេនថា ឯចិត្តបួនស្រឡាញ់ស្រីទាំង ២ នាក់នោះ បានសរសេរជាពាក្យកាព្យឃ្លោងទុក ខ្ញុំក៏បានចាំសេចក្ដីជាសំខាន់ រួចខុនបេនក៏សូត្រពាក្យឃ្លោងនោះឱ្យជីវយីស្ដាប់ថា :

អនិច្ចាថ្ងៃទេវី ២ ឆ្វេងស្ដាំ    បងចាំរៀបទុកដាក់បំណង
មួយឈ្មោះយ៉ុកឡុងមួយគឺមហាង    ទីងប៉ិត្រកង់ទុបថើបស្រី ៗ
គឺនាមនាងកៀវស្រៀវស្រៀបស្រស់    ទាំង២ឲ្យអស់ចិត្តបេតី
មួយឆ្វេងមួយស្ដាំលើកបួមបី    ឲ្យប្អូនប្រិមប្រិយសុខសិកន្ត ៗ

ជីវយីបានព្ទចំណោះនាងកៀវទាំង ២ ដូច្នោះ ក៏ខឹងខ្ញាំងណាស់ ដូចគេយកត្បូងទៅដុតចំលើថ្ងៃមប្រមាត់ ក៏ស្ទុះក្រោកឡើងលើកដៃចង្អុលទៅត្រង់ទិសឯជើង ចំលើស្រុកកេងជីវថា ម៉ែអាសត្រូវផែនដីម្ដេចអាឯងព្រហើន ហ៊ានបរពាប្រមាថៈមើលងាយអញជាខ្សែងលេង ៗ ខុនបេនឃើញជីវយីប្រឡោតខឹងដូច្នោះ ក៏ក្រោកឡើងធ្វើជាហាមឃាត់ថា ហេតុម្ដេចផែនដីអ្នកមិនស្រឡាញ់ ក៏ទៅស្រឡាញ់ឯស្រី ២ នាក់នោះវិញ ទីងបានជាប្រយោជន៍អ្វី ?

ជីវយីថា អ្នកមិនដឹងទេឬ នាងតែកៀវជាបងនោះ គឺជាភរិយា

ស៊ុនសេកទៅហាយខ្ញុំ នាងសៀវកៀវជាប្អូនក៏ជាភរិយារបស់ខ្ញុំ ចុច្ឆចរតាមើលឆាយយ៉ាងនេះបានជាខ្ញុំខឹងក្តៅណាស់ ៗ ខុងបេងធ្វើជាភ័យតក់ស្លុត ចុះទៅគំនាប់ហើយថា ខ្ញុំមិនដឹងសោះឡើយបានជានិយាយហួសទៅ ដូច្នេះខុសខ្លាំងណាស់ សូមឲ្យអ្នកអាណិតអត់ទោសទៅចុះ ៗ ជីវយ៉ីថា អាសត្វកញ្ជាស់នេះ ខ្ញុំមិនសុំជាន់ផែនដីរួមគ្នាឡើយ ៗ

ខុងបេងថា អ្នកកុំធ្វើការដោយទោសោដូច្នោះ ត្រូវតែគិតជាក់ច្នមឲ្យបានល្អ ដែលនឹងប្រទេឡាតតាមចិត្តខឹងដូច្នោះ តទៅមុខក៏នឹងចួសការមិនខាន ៗ ជីវយ៉ីថា អ្នកនិយាយនោះត្រូវហើយ ឯខ្លួនខ្ញុំក៏បានទទួលពាក្យស៊ុនគួនពីដើមមក ដែលនឹងទៅលំទុនបួច្ឆនោះ ខ្ញុំស៊ូតែស្លាប់មិនព្រមទៅគំនាប់សោះឡើយ ខ្ញុំមកពីស្រុកគួនយ៉ឺងកុងគ្រានេះ ក៏គិតជានឹងមកបាត់បែងរៀបចំទាហានបំរុងនឹងតស៊ូ តែជាកំឡាំងសេចក្តីគិតរបស់ខ្ញុំតែម្នាក់ឯងឃើញមិនស្រួល សូមឲ្យអ្នកជួយឧទ្ធគ្រោះទំនុកបំរុងផង ៗ

ខុងបេងថា បើក្តកមិនមានសេចក្តីរង្កៀសក្នុងចិត្តទេ នឹងឲ្យខ្ញុំជួយក៏ល្មមនឹងរិះគិតទៅបាន បើខុសត្រូវប្រការម្តេចទៅខាងមុខសូមជួយដាស់តឿនតាមដម្រេះប្រាជ្ញា ៗ ជីវយ៉ីថា អ្នកនិយាយនេះក៏ត្រូវល្អហើយ បើដូច្នោះពេលព្រឹកស្អែក ខ្ញុំនឹងចូលទៅឯកាបស៊ុនគួន នឹងនិយាយឲ្យរៀបចាត់ចែងទាហានទុកឲ្យស្រេច ដើម្បីនឹងលើកទៅកបាត់បួច្ឆឲ្យបាន ៗ ខុងបេង

ទីងឡោស៊ុកបានស្លាប់ហើយ ក៏គំនាប់លាដីវយើមកកាន់ទីសំណាក់វិញ ។

លុះពេលព្រឹក ស៊ិនគួនទីងពួកនាម៉ឺនខាងក្រសួងរដ្ឋបាល ទីងពួកក្រុមព្រះនគរបាលព្រមគ្នាទៅជួបជុំ ។ ដីវយើចូលទៅគំនាប់ហើយនិយាយថា ឥឡូវនេះខ្ញុំបានដឹងថា ចូច្វូលើកទ័ពមកទីង ធ្វើអន្តរាយដល់ស្រុកយើងនោះ តើលោកគិតប្រការម្តេច? ។ ស៊ិនគួនឃើញដីវយើចូលមកនិយាយដូច្នោះ មានអំណរណាស់ ទើបយកសំបុត្រដែលចូច្វូឲ្យមកនោះ ហុចឲ្យទៅដីវយើមើល ។ ដីវយើហែកសំបុត្រមើលហើយថា អាចោរត្រូវផែនដីកញ្ចាស់នោះវាគិតថា ស្រុកកាំងតាំងគ្មានមនុស្សល្អទីងជីងដល់វា វាប្រាថ្នាទីងបញ្ចុះបញ្ចូលឲ្យយើងស្ងាប់ចិត្ត ។ ស៊ិនគួនបានឮដូច្នោះក៏សួរថា សេចក្តីទាំងអម្បាលនេះ អ្នកយល់ឃើញប្រការម្តេច ? ។ ដីវយើថា លោកបានប្រឹក្សាទីងអស់អ្នកពលគ្នាហើយឬ? យល់ឃើញព្រមគ្នាប្រការម្តេចខ្លះ? ។

ស៊ិនគួនថា ខ្ញុំប្រឹក្សាមិនទាន់ចុះរុះគ្នាសោះ ដែលទីងឲ្យយើងទៅគំនាប់ក៏ថា ទីងឲ្យតស៊ូក៏ថា សេចក្តីទាំង ២ នេះបែកខ្ញែកគ្នាដោយខ្លួន បានជាឲ្យអញ្ជើញអ្នកមកគ្រានេះ ប្រាថ្នាទីងឲ្យនិយាយ ឲ្យបានដាច់ស្រេច ។ ដីវយើថា ដែលប្រឹក្សាឃើញថា ទីងឲ្យទៅចំណុះចូច្វូនោះ គឺនរណាខ្លះ? ។ ស៊ិនគួនរាប់ប្រាប់ឈ្មោះឲ្យស្តាប់ ។ ដីវយើក៏សួរទៀវទៀវថា ដែលអ្នកទីងឲ្យចេញទៅគំនាប់ច្វូនោះ ដោយយល់ឃើញប្រការម្តេច? ចូរថាឲ្យច្បាស់មកចុះ ។ ទៀវទៀវថា ខ្ញុំឃើញថាចូច្វូមកប្រាបប្រាម;

ប្រកទេសទាំងអស់នេះ ព្រោះកាន់ព្រះដម្រាស់ព្រះចៅហៀនតេជាធំ, មួយទៀត ចុច្ចបានស្រុកគេងដីវប្រមូលផ្សំទាហានទុកជាច្រើន ឃើញថាមានកំឡាំងធំទូលាយឆ្ងាយណាស់ យើងតស៊ូមិនបានទេ បានជាយល់ថាត្រូវទៅចំណុះចុះចូលតាមប្រវេណីសិន តទៅមុខសឹមគិតប្រែប្រួលទៅតាមការ អ្នកពាល់គ្នាមកប្រឹក្សាឃើញត្រូវព្រមគ្នាដូច្នេះ សុទ្ធតែមនុស្សមិនកើតទាំងអស់ ព្រោះស្រុកកាំងតាំងនេះ មានចៅហ្វាយស្រុកតគ្នាមកដល់ ៣ ដួរហើយ មិនដែលទៅចំណុះអ្នកណាសោះ ហេតុអ្វីគ្រានេះអ្នកពាល់គ្នាប្រឹក្សាឲ្យលះបង់ប្រវេណីចេញដូច្នោះ ទីងជាប្រយោជន៍អ្វី? ។

ស៊ុនគួនថា កាលពួកអ្នកទាំងនេះប្រឹក្សាយល់ដូច្នោះហើយ បើខាងអ្នកមិនយល់ឃើញតាមទេ តើនឹងឲ្យធ្វើប្រការម្ដេចទៅវិញ? ។ ជីវយើថា ចុច្ចនោះជាមហាខុបកដក៏មែន តែជាសត្រូវពជសម្បត្តិរបស់ព្រះចៅហៀនតេ ឯខ្លួនលោកក៏ជាមនុស្សមានប្រាជ្ញាទីងតម្រេះរិះគិត ហើយប្រកបដោយសេចក្ដីកតញ្ញូសុចរិតណាស់ មិនគួរនឹងទៅចំណុះចុះចូលចុច្ចដែលជាមនុស្សកែកតញ្ញូទ្រស្ដក្សត់ផែនដីនោះទេ, មួយទៀត ស្រុកកាំង-តាំងបរិបូណ៌ដោយស្រូវអង្ករចំណីត្រីសាច់ព្រះទាំងមនុស្សចំណុះស្រុកក៏ច្រើន គួរតែកំចាត់សត្រូវផែនដីឲ្យសូន្យចេញទើបប្រពៃ ដែលចុច្ចលើកគង់ទ័ពមកនោះទីនេះក៏យូរហើយ ខាងម៉ាថេងទីងឃ្លាន់ស៊ុយក៏ជាហរិគ្គាដែរ ឃើញថាទឹងហរិរវៀងគ្នាជាខាងក្រោយ, ប្រការមួយទៀតទាហានចុច្ចសុទ្ធ

តែមនុស្សពូកែអ្នកលើ មិនចុះប្រសប់ការដើរទឹកសោះ ទោះលើកមកច្បាំងក៏មិនសូវស្ទាត់ ហើយវេលានេះជារដូវប្រាំង ស្មៅទឹកចំបើនទាំងពួង ក៏ឃើញថាមិនមានទឹកជួនល្មមនឹងមាត់សេះបរិភោគ ឯទាហានទាំងពួង សោតក៏សុទ្ធតែមនុស្សព្រៃ នឹងស៊ីផឹកប្រើទំកខទ្វេក៏ខុសទម្លាប់ ច្រើនតែឈឺថ្កាត់គ្រប់គ្នា ឃើញថាកំឡាំងកងទ័ពនឹងថយៗចុះគ្រប់វេលា ទោះបីធ្វើការតែងជាប់គ្នា ក៏គង់នឹងចាញ់ប្រៀបខាងយើង ការសឹកសង្គ្រាមជាន់នេះខ្ញុំគ្មានវិតក្កសោះឡើយ នឹងសូមអាសាលោកលើកទ័ពទៅតាំងនៅកំពង់ស្រុកកាំងហៃ កំចាត់បច្ចុះបញ្ចឲ្យបាន ។

ស៊ុនក្ងួនបានស្តាប់សព្វគ្រប់មានអំណរណាស់ ទើបនិយាយថាដែលអ្នកគិតកស៊ូនឹងច្បាំងនោះក៏ដូចចិត្តរបស់ខ្ញុំ ។ ជីវយី វា ឯខ្លួនខ្ញុំបាននេះ ទោះបីនឹងស្លាប់ក្នុងសង្គ្រាមក៏មិនបានគិតស្តាយជីវិតសោះ ខ្ញុំបានមកគិតមិនអស់ចិត្តតែនឹងលោកក្រែងមិនមាំមួន ។ ស៊ុនក្ងួនហូតយកក្រប៊ីចេញមកហើយ ក៏កាប់ចំមុមតុប្រកាសជាអាជ្ញាសិទ្ធិទុកថា ឧណានឹងរកនិយាយឲ្យយើងចេញទៅចំណុះបច្ចមិត្តនេះទៀត នឹងត្រូវកាត់ក្បាលចេញ និយាយហើយក៏ហុចក្រប៊ីនោះ ទៅឲ្យជីវយីកាន់ជាអាជ្ញាសិទ្ធិក្នុងកងទ័ពបម្រាប់មុខនាហ្មឺនមេកងធំ ទ័ពបួនឲ្យទៀតទៅជាប៉ុ ឡាក់ បើអ្នកឯណាមិនបាននៅក្នុងបង្គាប់បញ្ជាទេ ត្រូវឲ្យកាត់ក្បាលអ្នកនោះចេញ ជីវយីគំនាប់ហើយ ក៏ទទួលយកក្រប៊ីលើកប្រកាសឡើង

ដល់ថ្ណាទាហានទាំងពួងថា ឥឡូវយើងបានកញ្ញាសិទ្ធិមកជាទីសម្រេចកិច្ចការក្នុងកងទ័ពហើយ ចូរអ្នកពលគ្នាតាំងចិត្តធ្វើការកុំបីប្រមាទ ដែលយើងលើកទ័ពទៅតតាំងច្បាំងនឹងចូចូគ្រានេះ ត្រូវទៅព្រមគ្នាឯក្បែរជាយទន្លេ បើនរណាឃើញយូរក្នុងកំណែនមិនទាន់ការពការ យើងនឹងឲ្យដាក់ទោសអ្នកនោះដោយសហ័ស និយាយហើយក៏លាស៊ុនគួនចេញទៅដល់ផ្ទះ ហើយឲ្យអញ្ជើញខុងបេងចូលទៅប្រឹក្សាថា ឥឡូវចៅហ្វាយខ្ញុំព្រមឲ្យតស៊ូនឹងចូចូហើយ សុំឲ្យអ្នកជួយគិតឧបាយដែលនឹងធ្វើកិច្ចការនោះផងចុះ ៗ

ខុងបេងថា ដែលអ្នកនឹងឲ្យខ្ញុំជួយគិតការនោះក៏មិនជាអ្វីទេ ល្មមនឹងជួយគិតតាមដម្រេះប្រាជ្ញាបានខ្លះដែរ តែថានៅមិនទាន់ទុកចិត្ត ដោយឃើញអារម្មណ៍ចៅហ្វាយអ្នកនៅវិលវល់ណាស់ ៗ ជីវយីថា អ្នកឃើញយ៉ាងម្ដេចបានជាថាដូច្នេះ ? ៗ

ខុងបេងថា ខ្ញុំឃើញចៅហ្វាយអ្នកព្រួយដំណឹងថា ទាហានចូចូច្រើនបារម្ភព្រួយថា ទាហានខាងនេះតិចក្រែងតស៊ូមិនបាន សូមកុំឲ្យអ្នកភ្ញាក់ផ្អើលធ្វើអ្វី ត្រឡប់ចូលទៅនិយាយយកចិត្តយកថ្លើមចៅហ្វាយអ្នកកុំឲ្យភ័យតក់ស្លុតរន្ធត់ដូច្នោះ ត្រូវតែខំប្រឹងឲ្យមាំមួន ទើបខ្ញុំនឹងរកគិតការស្រួល ៗ ជីវយីថា អ្នកនិយាយនេះត្រូវណាស់ ហើយជីវយីក៏ត្រឡប់ចូលទៅជួបនឹងស៊ុនគួនៗក៏សួរថា ពេលយប់ងងឹតថ្មើនេះ អ្នកចូលមកមានកិច្ចធុរៈអ្វី? ៗ

ជីវយីថា ខ្ញុំបាទនឹងកេណ្ឌអាហារទាំងពួងនោះ ទៅគិតធ្ងន់ក្នុងចិត្តបន្តិច ទើបត្រឡប់មកជួបនឹងលោក ប្រាថ្នានឹងចង់ដឹងថា លោកមានសេចក្តីវិតក្កអ្វីខ្លះឬគ្មានទេ ។ ស៊ុនគួនថា ដែលអ្នកត្រឡប់មកសួរខ្ញុំយ៉ាងនេះត្រូវហើយ ខ្ញុំក៏នៅមានសេចក្តីវិតក្កបន្តិចដែរ ព្រោះចូឆូមានអាហារច្រើន ខាងយើងមានអាហារតិចណាស់ ក្រែងតស៊ូនឹងគេមិនបាននឹងជួបការពៅ ។

ជីវយីថា ការនេះឯងហើយ បានជាខ្ញុំបាទចូលមកជំរាបលោក ប្រាថ្នានឹងពន្យល់ឲ្យលោកចូលចិត្ត ព្រោះចូឆូមានសំបុត្រមកថា មានអាហារ១០០ម៉ឺននោះ សេចក្តីនេះមិនមែនទេ គឺជាកលឧបាយបញ្ឆោតទេតើ ឯអាហារចូឆូនោះមានប្រហែល១៥-១៦ម៉ឺនប៉ុណ្ណោះ ដប់អាហារអ្នកស្រៀវជាមនុស្សចាំចិត្ត គិតតែនឹងដោះខ្លួនចេញពីចូឆូគ្រប់ពេលព្រឹកល្ងាច ទោះបីនឹងធ្វើការក៏មិនពេញដៃ មួយទៀតអាហារចូឆូក៏ដើរមកផ្លូវឆ្ងាយ សព្វសារពើអ្វីៗក៏ទញ់ទាល់ទាំងគ្រប់អស់ហើយ យើងនៅជិតស្បៀងអាហារក៏បរិបូណ៌គ្រប់សព្វទាំងអស់នឹងស៊ូមិនបានឬ ទោះបីច្រើនក៏ដូចតិច លោកកុំវិតក្កៈឡើយ ខ្ញុំបាទនឹងសុំអាសាយកអាហារយើងតែ៥ម៉ឺន នឹងគិតធ្វើការកំចាត់ចូឆូចេញឲ្យបាន ។ ស៊ុនគួនបានស្តាប់ដូច្នោះ ក៏ពេញអំណរណាស់ លើកដៃស្ទាបអង្អែលខ្នងជីវយីហើយថា ដែលអ្នកពន្យល់ឲ្យយើងអស់សង្ស័យដូច្នេះ ជាគុណច្រើនណាស់ នេះហាក់

ជាបានអ្នកជួយឧបត្ថម្ភ បើត្រឹមតែលើរទេះចៀវខ្ញុំក៏ពឹងមិនបាន ពីថ្ងៃនេះ
ទៅខ្ញុំអស់សេចក្ដីព្រួយវិតក្កទៀតហើយ អ្នកទឹងទៀតទៅ ឡោសុក ចូរទំ
ចាត់ចែងប្រមូលអាហារស្រូតលើកទៅចុះ ខ្លួនខ្ញុំនឹងលើកអាហារជូនទៅ
តាមក្រោយ បើខ្វះខាតប្រការម្ដេច ចូរប្រើបំរើឲ្យមកប្រាប់ខ្ញុំ សឹមខ្ញុំលើក
ទៅគប្បីនឹងក្ដួចឆ្ងាយខ្លួនឯង ។ ដរាយើញដូច្នោះគំអប់បង្ស្រយគំនាប់លា
ត្រឡប់ចេញទៅវិញ ទើបគិតថាខុនបេននេះនិយាបរាជ្ញវៃមាំមួនណាស់
ដឹងចិត្តរបស់ចៅហ្វាយយើងជាងយើងទៅទៀត, មួយទៀតនឹងគិត
ការអ្វីក៏ឈ្លាតឹមត្រូវដូចនឹងដើរបើក្បាលយើងបាន បើយើងស្ងៀមទុក
គ្រានេះ យូរទៅនឹងត្រឡប់ជាបត្រូវ ត្រូវតែគិតកំចាត់ចេញឲ្យបាន
ហើយឲ្យហៅឡោសុកចូលមក ប្រាប់សេចក្ដីស្ងាត់ដែលនឹងគិតសម្លាប់
ខុនបេនចេញឲ្យស្លាប់គ្រប់ប្រការ ។

ឡោសុកថា អ្នកគិតដូច្នេះមិនត្រូវសោះ ព្រោះចួនលើកទ័ពមក
នឹងប្រមូលយកដល់យើង តែនៅកំចាត់ចេញមិនទាន់បាន បើអ្នកទៅ
សម្លាប់ខុនបេនចេញហើយ ការសឹកសង្គ្រាមក៏នឹងជាប់ដៃគ្នាតទៅថ្ងៃ
មុខជាអន្លង់ តែខ្លួនអ្នកមួយគ្មាននរណាជួយគិតសោះ នឹងមិនជួន
ក្នុងដើមទ្រនំណាស់ទៅឬ ? ឯខុនបេននេះ មានជម្រះប្រាជ្ញាគួរនឹង
ជួយអ្នកបាន, មួយទៀតដូកាត់កិនខុនបេនក៏នៅក្នុងស្រុកកាំងតាំង
ដែរ បើប្រទៅនិយាយបបួលឲ្យចូលមកនៅជួយធ្វើការខាងយើងនឹង

មិនល្អទេឬ ? ។ ដីវយើក្ដះហើងគឹយល់ថា ត្រូវ លុះវេលាព្រឹកកឹឲ្យទៅហៅនាម៉ឺនមុខមន្ត្រីចូលមកព្រមគ្នាក្នុងទីប្រជុំ ។ ខណៈនោះ ទៀតៅមានសេចក្ដីតូចចិត្តថា ខ្ទនអញជាចាស់ជាងអាយុដីវយើ ។ នៅក្មេងឡើងអគ្គិយទិក្ដស់ ទឹងឲ្យយើងជាចាស់ទាបមុខ ទៅអគ្គិយប្រឹក្សាការក្នុងទីទាប ឲ្យបុត្រមកជំនួសហើយប្រាប់ថាឈឺ ។

ដីវយើក៏និយាយទឹងនាម៉ឺនទាំងពួងថា កងទ័ពបូធូលើកមកគ្រានេះចំសន្ធឹកសន្ធាប់ណាស់ ឯយើងទឹងគិតធ្វើការនោះទឹងធ្វេះឡូះឡោះពុំបានទេ អ្នកពល់គ្នាទឹងធ្វើការជាមួយទឹងយើង មិនត្រូវខ្ជិលច្រអូសមានពុតត្បុតគេចវេះ បើនរណាមិនពេញចិត្តប្រឹងធ្វើការទេ យើងនឹងកាត់ក្បាលចេញតាមអយ្យការសឹក ហើយដីវយើក៏តាំងអ៊ុយកាយ ហានគុង ជានាយកងទ័ពស្រួច លើកទាហានចុះទូកចម្បាំងឲ្យព្រមព្រៀងគ្នា ឲ្យដីវឃើម, ដីវថាយ លើកទាហានមួយកង, ឲ្យឡូកសុន តាំងសុិត លើកទាហានមួយកង, តាំងលីហាង ដួទី លើកទាហានជាកងល្បាត ។

លុះដីវយើចាត់ចែងនាយទ័ពនាយកងសម្រេចហើយក៏បង្គាប់ថា អ្នកពល់គ្នាចូរស្រូតច្រញាប់ទៅត្រៀមប្រចាំឲ្យមូលគ្នា បើបានឮក្សពារវេលាណា យើងទឹងលើកកងទ័ពចេញទៅតាំងនៅមាត់ជ្រោយស្រកសាំកាំងនាយទ័ពនាយកងទាំងពួង ក៏គំនាប់លាចេញទៅចាត់ចែងទាហានត្រៀមទុកស្រេច តាមពាក្យដីវយើបង្គាប់ ។

ឯទៀវជូបុត្រទៀវគៅ ឃើញជីវយីតាស់តែងទាហាន ព្រមទាំងទំពាគាកទ័ពទឹកដូច្នោះ ក៏យកសេចក្ដីទៅជំរាបទៀវគៅជាបិតាគ្រប់ប្រការ ទៀវគៅឮដូច្នោះក៏យំណាស់ យកដៃគក់ដើមទ្រូងហើយថា ជីវយីនេះអញគិតថាជាក្មេងមិនទាន់ដឹងអ្វី ឥឡូវឃើញបេះដូងជាងមនុស្សចាស់ទៅទៀត គ្រឡប់មានដម្រេះប្រាជ្ញាអង់អាច ដឹងរៀបចំទាហានក្មេងកង់ទ័ពត្រឹមត្រូវតាមក្បួនទ័ពក្នុងសង្គ្រាម ល្មមសមគួរដែលនឹងធ្វើជាមេកងធំបាន ដែលខ្លួនអញមកគិតប្រមាថមើលងាយខុសដូច្នេះមិនគួរសោះ ទៀវគៅក៏ទៅរកជីវយីដល់ទីលំនៅ ហើយក៏និយាយសូមទោសថា ខ្ញុំបានជាកាន់ទិដ្ឋិមានះព្រោះថាចាស់ មើលងាយអ្នកថាតែនៅក្មេងមិនបានមកប្រឹក្សាការងារ តំណាប់អ្នកនោះខុសពេកណាស់ សុំឲ្យអ្នកករុណាអត់ទោសខ្ញុំចុះ ។ ជីវយីអស់សំណើចហើយថា ដែលអ្នកប្រមាថមើលងាយនោះ ខ្ញុំមិនប្រកាន់ទោសទេកុំឲ្យព្រួយ ។ ទៀវគៅបានទទួលទោសដូច្នោះហើយក៏លាត្រឡប់ទៅវិញ ។

លុះវេលាព្រឹក ជីវយីឲ្យហៅជូកាត់កិនចូលមកនិយាយថា ខ្ញុំបងប្អូនអ្នកជាមនុស្សមានដម្រេះប្រាជ្ញា ហេតុម្ដេចទៅធ្វើខ្ញុំនឹងឡាវពីដូច្នោះ មិនសមសោះគួរតែនឹងមកនៅនឹងស៊ុនគួនទៅហ្វាយយើង ក៏នឹងមានយសបណ្ដាស័ក្ដិជាសុខសាន្ត អ្នកប៉ូទៅនិយាយល្បួងលួងលោមខ្ញុំបងប្អូនអ្នកឲ្យកលឡៅពីទៅមកនៅធ្វើការងារផែនដីជាមួយគ្នានឹង

យើង ព្រោះខ្លួនអ្នកនៅទីនេះដែរ បងប្អូននឹងបានឃើញមុខគ្នាព្រឹកល្ងាច នឹងមិនល្អឬ ? ។ ជូកាត់កិនថា ខ្ញុំមកនៅនឹងស៊ិនគួននេះ ក៏មិនទាន់មានសេចក្តីគាប់ប្រសើរអ្វីសោះ បើដូច្នោះ ខ្ញុំនឹងទៅនិយាយនឹងប្អូនខ្ញុំមើល បើព្រមមកនៅនឹងអ្នកជាសេចក្តីគាប់ប្រសើររបស់ខ្ញុំស្រាប់ , ជូកាត់កិនគំនាប់ហើយក៏ឡើងសេះស្រុតរូតទៅ ជួបនឹងខុងបេងដល់ទីសំណាក់ ។ ខុងបេងឃើញជូកាត់កិនជាបងមកដូច្នោះក៏មានអំណរណាស់ ចេញមកគំនាប់ហើយក៏នាំចូលទៅក្នុង អ្នកទាំង ២ ក៏យំលើកគ្នាព្រោះឃ្លាតចាកមកយូរ ។

ជូកាត់កិនក៏និយាយនឹងខុងបេងថា ប៉ែះអុី , សុកហៃ ពីដើមនោះដឹងឬទេ ? ។ ខុងបេងបានឮសំដីដូច្នោះក៏ដឹងថា ជីវយីប្រើឧបាយឲ្យមកនិយាយបញ្ចុះបញ្ចូលទើបឆ្លើយថា ប៉ែះអុី , សុកហៃ ជាមនុស្សជាន់បុរាណ ត្រូវការអ្វីកុំនាំមកនិយាយឡើយ ។ ជូកាត់កិនថា ប្អូននិយាយនេះដូចជាគេគិតបងប្អូនគ្មានសោះហើយ ឯប៉ែះអុី , សុកហៃ បងប្អូន ២ នាក់កើតផ្ទៃជាមួយ ផឹកទឹកដោះជាមួយគ្នា ព្រោះដោយសេចក្តីស្រឡាញ់ ដូចបងប្អូននឹងបងកើតរួមខេរជាមួយគ្នា ធំដោះជាមួយគ្នា ទោះនឹងទៅធ្វើការអ្វី ៗ នៅទីឯណាក៏ត្រូវតែទៅជាមួយគ្នា ទោះនឹងស្លាប់វេលាណាក៏ត្រូវតែស្លាប់ជាមួយគ្នាដែរ ដោយហេតុសេចក្តីស្រឡាញ់ បើប្អូននឹងបងកើតមកជាមួយគ្នា ហើយទៅធ្វើរាជការនៅទីទៃៗ ពីគ្នា មិន

បានឃើញមុខគ្នាព្រឹកល្ងាចដូច្នេះ ក៏មិនដូចប្រវេណីបងប្អូនគេពីដើម នឹងមិនមានសេចក្តីអប្បយសដល់គេទាំងពួងឬ? ។

ខុងបេងថា ដែលបងមានប្រសាសន៍នោះ ខ្ញុំបាទមិនទាន់ឃើញផងសោះ ព្រោះយើងបងប្អូនកើតក្នុងផែនដីព្រះចៅហៀនតេ គួរណាស់តែកាន់ចិត្តគិតកតញ្ញូនឹងផែនដី ហេតុដូច្នេះបានជាខ្ញុំបាទស៊ូទៅនៅនឹងឡេវពី ព្រោះឃើញថាជាពូជព្រះវង្សព្រះចៅហៀនតេ ដើម្បីមិនឲ្យបង់ប្រវេណីបុរាណ ហេតុម្តេចបានជាបងលះបង់ចោលផែនដីព្រះចៅហៀនតេស្រឡះ ស្ទុះស្ទែងមកនៅក្នុងស្រុកកាំងតាំងឲ្យរឹតតែឆ្ងាយបងប្អូនទៅទៀត ដូចជាគ្មានចិត្តគិតនឿតពេកអាល័យសោះឡើយ ពេលនេះហើយគួរតែបងលះបង់ចោលស្រុកកាំងតាំងចេញ វិលទៅនៅធ្វើរដ្ឋការនឹងខ្ញុំបាទវិញ ឲ្យបានឃើញមុខគ្នាយប់ព្រឹកទើបគួរ ។ ជូកាត់កិនបានស្តាប់ដូច្នោះក៏គិតថា ខ្លួនអញសុំអាសាមកល្បងលួងលោមខុងបេង ឥឡូវខុងបេងត្រឡប់ល្បងលួងលោមឯងវិញដូច្នេះ ក៏ទាល់គំនិតមិនដឹងបើនឹងគិតនិយាយដូចម្តេចទៅទៀត, ជូកាត់កិនក៏លាខុងបេងត្រឡប់ទៅប្រាប់ជីវយីគ្រប់ប្រការ ។

ជីវយីឮហើយក៏មិនបានជាប្រការម្តេច [illegible] លាស៊ុនគួន ហើយនិយាយថា ខ្ញុំនឹងសុំអាសាលើកទ័ពទៅច្បាំងនឹងចូចូ ។ (នៅមានត)

ពាក្យវប្បធម៌

# លោក សម - ហ៊ាំង

*សមាជិកគណៈកម្មការវប្បធម៌ រៀបរៀង*

---

## អស់លោកអ្នកអានទាំងឡាយ !

ពាក្យវប្បធម៌ ដែលចុះផ្សាយនៅលើទំព័រទស្សនាវដ្ដីកម្ពុជសុរិយា នេះ ជាសេចក្ដីថ្លែងតាមសំឡេងគណៈកម្មការវប្បធម៌ ដែលមានផ្សាយតាមវិទ្យុជាតិពីក្នុងឆ្នាំ១៩៥៩រួចមកហើយ ។ ហេតុដែលបានជាយកមកបោះពុម្ពផ្សាយក្នុងទីនេះទៀត មកពីលោក ចាប - ពិន អធិបតីក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ជាអ្នកចាត់ការខាងទស្សនាវដ្ដីកម្ពុជសុរិយា មានបំណងចង់ឲ្យសំឡេងគណៈកម្មការវប្បធម៌ ដែលបានផ្សាយរួចហើយនោះ ជាប់ជាលាយល័ក្ខណ៍អក្សរលើទំព័រទស្សនាវដ្ដីនេះផង បានសុំយកមកចុះផ្សាយ ដើម្បីជាសាធារណប្រយោជន៍ដល់សិក្ខាកាមជនតទៅ ។ ខ្ញុំជាជំណាងគណៈកម្មការវប្បធម៌ បានយល់ព្រមតាមការសុំនេះហើយ ។

ឯសំឡេងគណៈកម្មការវប្បធម៌ ដែលបានផ្សាយតាមវិទ្យុជាតិ

ជាច្រើនកេ.បមកហើយនោះ ដែនអំពីរបៀបកែតម្រង់ពាក្យក្នុងភាសាជាតិ ឲ្យបានត្រឹមត្រូវតាមក្បួនខ្នាត ។ ឥឡូវនេះយើងសូមស្រង់យកពាក្យខ្លះ ដែលជាប់ពាក់ព័ន្ធ ដោយពាក្យបាលីមកអធិប្បាយពន្យល់ជូនក្នុងទំព័រ ទស្សនាវដ្ដីកម្ពុជសុរិយានេះម្ដងទៀត ។

ពាក្យដែលយើងបានស្រង់យកមកអធិប្បាយជូនក្នុងពេលនេះ មាន ៥ ម៉ាត់ដូចខាងក្រោមះ

១- អដ្ឋិសង្ខលិកា ;

២- អជ្ឈោកាស ,

៣- អត្តសន្តោះ ;

៤- អត្តជ័យ ;

៥- អត្តសញ្ញាណលិខិត ។

អដ្ឋិសង្ខលិកា កុំអាន អដ្ឋ-សាំង-លិក ឬ អដ្ឋ-សង-លិក ព្រោះមានជើង ខ នៅខាងក្រោមតួ-ង-ជង ត្រូវអានឲ្យអស់តួអក្សរថា អាត-ថិ-ស័ង-ខៈលិក, ត្រង់ ខៈលិក សុំកុំអានថា ខៈលីក ព្រោះលិ ទីង ក អានថា លិក ពុំមែន លី ទីង ក ដែលត្រូវអានថា លីកទេ ។ អដ្ឋិសង្ខលិក សរសេរ = អ-ដ-ជើង ឋ មុខជៈ ស្រៈ ឥ-ស-ង ជើង ខ-ល-ស្រៈឥ ទីង ក ។ អដ្ឋិសង្ខលិក ជាភាសាបាលី កើត

មកពីសព្ទ ២ គឺ អដ្ឋិ ១ និងសន្ធិលិកៈ ១ , ពាក្យ ១ មាត់កើតមកពីសព្ទច្រើនរួមគ្នាដូច្នេះ លោកឲ្យឈ្មោះថា “ សមាសនាម ” ។ អដ្ឋិ ប្រែថា ឆ្អឹង, សន្ធិលិកៈ ប្រែថា ការប្រមូលផ្សំ , ប្រជុំ , គ្រោង ។ អដ្ឋិសន្ធិលិក ប្រែតាមអក្ខរានុរូបថា ការប្រមូលផ្សំឆ្អឹង; តាមអត្ថប្បដិរូបថា គ្រោងឆ្អឹង ឬ មនុស្សស្គមកំព្រឹង , សំដៅគ្រោងឆ្អឹងទាំងមូលរបស់មនុស្ស , សត្វ ដែលគេយកសាច់នឹងសរសៃចេញ ទៅសល់តែគ្រោងឆ្អឹងទាំងអស់ ។ សូម្បីតែគ្រោងឆ្អឹងផុះ ឬទាក់ ក៏ហៅថា អដ្ឋិសន្ធិលិកបានដែរ ។ ពាក្យនេះមានទំហំន័យប៉ុនគ្នានឹងពាក្យបារាំងថា (Squelette)។

សុំជូនឧទាហរណ៍ ជាប្រយោគឲ្យយល់អំពីរបៀបប្រើ ដូចខាងក្រោម ៖

នៅវិទ្យាល័យ ព្រះស៊ីសុវត្ថិ មានអដ្ឋិសន្ធិលិកនៃមនុស្ស និងសត្វជាច្រើនគ្រោង សម្រាប់បង្រៀនសិស្សឲ្យយល់ច្បាស់ អំពីវិទ្យា. សាស្ត្រធម្មជាតិ ។

នៅមាត់កំពង់ផ្សារស្ទួនចាស់ មានអដ្ឋិសន្ធិលិក នាវា ជាច្រើនគ្រៀបគ្រា ដែលជាងកំពុងតែជួសជុល ។

អដ្ឋិសន្ធិលិក នៃដំរី ធំជាគ្រោង ជាងអដ្ឋិសន្ធិលិកនៃមនុស្ស, សត្វទាំងអស់ ។

ឧទាហរណ៍ ទាំងបីប្រយោគខាងលើនេះ បញ្ជាក់ជូនអស់លោក

អ្នកឲ្យយល់អំពីរបៀបប្រើពាក្យអដ្ឋសន្ធិលិក:ហើយ ។

តពីនេះ សូមអញ្ជើញអានពាក្យមួយម៉ាត់ទៀត សុំអញ្ជើញអាន !

អជ្ឈោកាស សូមកុំអាន អៈ-ឈោ-កាស ព្រោះមានអក្សរ -ជ- តម្រួតលើជើង -ឈ- ផង, ត្រូវអានឲ្យគ្រប់តួអក្សរថា អាជ-ឈោ-កាស ។ អជ្ឈោកាស សរសេរ= អ- ជ- ជើង ឈ ស្រៈឱ-ក-ស្រៈអា ទីងស ។ អជ្ឈោកាស ជាភាសាបាលី កើតមកពីស័ព្ទ២គឺអធិ ដែលផ្សំជា អជ្ឈៈ១ និងឱកាសៈ ១ ។ ពាក្យមួយម៉ាត់ដែលរួមមកពីស័ព្ទច្រើនរូបដូច្នេះ លោកហៅថា "សមាសនាម" ។ អធិ ឬ អជ្ឈៈ ប្រែថា ក្រៃពេក ក្រៃលែង; ឱកាសៈ ប្រែថា ទីវាល, ចំហរ ។ អជ្ឈោកាសប្រែតាមអត្ថា-ធរូបថា ទីវាល, ទីចំហរក្រៃពេក តាមអត្ថប្បដិរូបថា ទីវាលស្រឡះ, ទីវាលកណ្ដាលថ្ងៃ សំដៅទីវាលស្រឡះល្ហល្ហៃដែលគ្មានតែអ្វីបិទបាំងខ្ទប់ ។

សូមជូនឧទាហរណ៍ ជាប្រយោគដូចខាងក្រោមនេះ ។

កុមារ កុមារីទាំងឡាយ, ចូរអ្នក-ទាំងនាំគ្នាទៅលំហែកាយក្នុងអជ្ឈោកាសឲ្យបានញឹកញយ ទើបអ្នក ទាំងនឹងមានសុខភាពល្អ ។

នៅកំពង់ផែ នាក្រុងព្រះសីហនុ មានអជ្ឈោកាសល្អណាស់ ។

ឧទាហរណ៍ប៉ុណ្ណេះ ល្មមអស់លោកអ្នកអាន យល់អំពីពាក្យអជ្ឈោកាសបានហើយ ។

តទៅនេះ សុំអញ្ជើញអានពាក្យ ១ ម៉ាត់ទៀត អញ្ជើញអាន!

អត្ថសង្គហៈ សូមកុំអាន អាត់-ស័ង-ហ. ព្រោះមានជើង ថ ទន្តជៈនៅពីក្រោមអក្សរ ត, មានជើង គ នៅខាងក្រោមតួ ង ផង ត្រូវអានឲ្យអស់តួអក្សរថា អាត់-ថៈ-ស័ង-គៈ-ហៈ ។ អត្ថសង្គហៈ សរសេរ=អ-ត-ជើង ថ ទន្តជៈ ស-ង-ជើង គ ទីងហ ។ ពាក្យនេះជាពាក្យបាលី កើតមកពីសព្ទ២ គឺ អត្ថ + សង្គហៈ;អត្ថៈប្រែថា ផលប្រយោជន៍, សេចក្ដីពន្យល់, ពាក្យប្រែស្រាយ, សេចក្ដីចំរើន, គតិ, រឿង, ហេតុការណ៍, ផល, បំណង, សេចក្ដីប្រាថ្នា, ទ្រព្យ, សម្បត្តិ, របស់ វត្ថុ;អំពើ;កិច្ច; កិច្ចការធុរៈ, រវល់ ។ សង្គហៈប្រែថា ការសង្គ្រោះ, ការកាន់យកឬការស្រង់ៗ រួមសព្ទទាំង២ចូលគ្នាបានជាអត្ថសង្គហៈ ហៅថា «សមាសនាម» បើប្រែតាមអត្ថានុរូបថា ការសង្គ្រោះឬការស្រង់សេចក្ដី ។ តាមអត្ថប្បដិរូប ជាឈ្មោះសៀវភៅដែលគេស្រង់អត្ថបទផ្សេងៗ យកមកបង្គ្រង់ទុក ត្រូវនឹងពាក្យបារាំងថា (Recueil) ។

សុំជូនប្រយោគជាឧទាហរណ៍ ដូចខាងក្រោមះ

ទីស្ដីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានបោះពុម្ពសៀវភៅអត្ថសង្គហៈ នៃច្បាប់តុលាការរៀងរាល់ខែ បារាំងហៅថា (Recueil judiciaire) ។

ឧទាហរណ៍ប៉ុណ្ណេះ ល្មមអស់លោកអ្នកអាន យល់បានអំពីពាក្យ អត្ថសង្គហៈ នេះហើយ ។

តទៅសុំអញ្ជើញអានពាក្យ១ម៉ាត់ទៀត អញ្ជើញអាន !

អត្ថន័យ សរសេរ=អ-ត-ជើងថទន្តជៈន-យ-ទីងសំយោគសញ្ញា ។ សុំកុំអានថា អត្ថៈ-ណៃ ត្រូវអានថា អាត់-ថៈ នៃ,ពាក្យនេះជាភាសាបាលី កើតមកពីស័ព្ទពីរ គឺអត្ថៈ ប្រែថា ផល, ផលប្រយោជន៍, សេចក្ដី, សេចក្ដីពន្យល់, ពាក្យប្រែស្រាយ, សេចក្ដីចំរើន, គតិ, រឿង, ហេតុ, ការណ៍ , បំណង,សេចក្ដីប្រាថ្នា, ទ្រព្យ, សម្បត្តិ, របស់, វត្ថុ, អីវ៉ាន់, កិច្ច, កិច្ចការធុរៈ, រវល់ ទីងនយៈឬន័យប្រែថា ការណែនាំអធិប្បាយ, សេចក្ដីពន្យល់, ហេតុ, ទំនង, លំនាំ; រួមបានជា អត្ថន័យ(ជាសមាសនាម) ។ អត្ថន័យប្រែថា សេចក្ដីអធិប្បាយពន្យល់អំពីគតិ, ហេតុ, ការណ៍, ត្រូវនឹងពាក្យបារាំងថា (Définition) ។

សុំជូនប្រយោគជាឧទាហរណ៍ដូចេះះ

ពាក្យបៀនប្រដៅ របស់បណ្ឌិតមានអត្ថន័យជ្រាលជ្រៅណាស់ ទោះបីជាពាក្យខ្លីសោះ ក៏គង់មានអត្ថន័យវែងឆ្ងាយដែរ ។

ឧទាហរណ៍ប៉ុណ្ណេះ ល្មមអស់លោកអ្នកអានយល់បានអំពីពាក្យថា អត្ថន័យ នេះហើយ ។

បន្ទាប់ពីនេះ សុំអញ្ជើញអានពាក្យ១ម៉ាត់ទៀត អញ្ជើញអាន !

អត្តសញ្ញាណលិខិត សរសេរ=អ-ត-ជើងត-ស-ញ ស្រះអា-ជើងញ-ណ-ល-ស្រះឥ-ខ-ស្រះឥទីងត ។ កុំអានថា អៈ-តៈព្រោះត្ត ត មានសំយោគ ទីងកុំអានថា: សៈ-ញាណព្រោះត្ជ ញ ក៏មានសំយោគដែរ,

ត្រូវអានថា អាត់-តៈ-សាញ់-ញ៉ា-ណៈ-លិខិត ។ កុំអានថា អ័ត-តៈ-សាញ់-ញាន ត្រូវអានថា សាញ់-ញ៉ាន ៈព្រោះមានអក្សរ ស នៅពីខាងដើមត្រូវអានថា ញ៉ា ដូចពាក្យថាសញ្ញា , បរិញ្ញាដែរ គឺត្រូវអានថា សាញ់-ញ៉ា, ប៉ុរិញ-ញ៉ា កុំអានថា ញា ។

ពាក្យនេះជាពាក្យបាលី រួមមកពីសព្ទ៣គឺៈ អត្តៈ ប្រែថា ខ្លួនឬចិត្ត១ សញ្ញាណៈ ការសំគាល់១ និងលិខិតៈ ប្រែថា សរសេរ,គូរ;សំបុត្រ, បុតហ្វាយ១ រួមគ្នាទាំង៣សព្ទជា អត្តសញ្ញាណលិខិត ប្រែថា សំបុត្រសម្រាប់សំគាល់ខ្លួន; ត្រូវនឹងពាក្យបារាំងថា(Pièce d'identité) ។ សព្ទច្រើនរួបរួមគ្នាបានជាពាក្យមួយម៉ាត់ដូច្នេះ ហៅថា "សមាសនាម,, ។

សុំជូនឧទាហរណ៍ ជាប្រយោគឲ្យងាយយល់ ដូចខាងក្រោមនេះៈ

ពលរដ្ឋគ្រប់សញ្ជាតិក្នុងលោក ដែលនឹងអាចឆ្លងកាត់ប្រទេសនីមួយៗបាន ដោយឥតទាស់ខុសនឹងបញ្ញត្តិច្បាប់ លុះត្រាតែមានអត្តសញ្ញាណ-លិខិតគ្រប់គ្រាន់ ។

ឧទាហរណ៍ ជាប្រយោគប៉ុណ្ណោះ ជាការបញ្ជាក់ជូនអស់លោកអ្នកអាន ឲ្យយល់អំពីពាក្យ អត្តសញ្ញាណលិខិតហើយ ។

# ផ្នែកកំណត់ដឹងប្រវត្តិការណ៍

## អនុសំវច្ឆរៈមហាសន្និបាតនៃមន្ត្រីសង្ឃលើកទី ១៦

លោក ជិង - វង រៀបរៀង

---

កាលពីថ្ងៃទី ២១ មករា ១៩៦០ នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត មានធ្វើពិធីអនុសំវច្ឆរៈមហាសន្និបាតនៃមន្ត្រីសង្ឃជាលើកទី ១៦ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ នៃព្រះមហាក្សត្រទាំងពីរព្រះអង្គ ។

នៅមុនពេលបើកពិធីនេះ យើងបានសង្កេតឃើញព្រះសង្ឃទាំងឡាយ ដែលមានសមណសក្តិជាគណៈបាឋានុក្រម ព្រមទាំងព្រះសង្ឃជាមេគណ អនុគណ ចៅអធិការ ដែលគង់នៅក្នុងព្រះរាជធានីភ្នំពេញ និងខេត្រក្រៅជាច្រើនពាន់អង្គ ទាំងពីរគណៈ បាននិមន្តមកកាន់ទីប្រជុំ នៅឯពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ដែលនៅក្នុងឱកាសនោះ សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក គណៈមហានិកាយ សម្តេចព្រះសុគន្ធាធិបតី សង្ឃនាយកគណៈធម្មយុត្តិកនិកាយ ព្រមទាំងព្រះពោធិវង្ស ហួត-តាត ចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត និងព្រះមហាព្រហ្មមុនី ទេព-អ៊ូ ចាងហ្វាងរងនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត

បាននិមន្តមកជាប្រធានផង ។

ចំណែកឥស្សរជន ដែលបានអញ្ជើញទៅរង់ចាំគោរពព្រះមហាក្សត្រគឺ ព្រះអង្គម្ចាស់ក្សត្រី ប៉េងប៉ោះយុគន្ធរ លោក ជួប-ហែល លោក ឯក-យីអ៊ុន ជាប្រធាននៃសភាទាំងពីរ ព្រមដោយសមាជិកសភាខ្លះ លោក ស៊ីន-សាន ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការបរទេស លោក ញឹក-ជូឡុង ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងផែនការអប់រំជាតិ ព្រមទាំងសមាជិករដ្ឋាភិបាលខ្លះ លោក សូ-ណោម រដ្ឋលេខាធិការក្រសួងធម្មការ ព្រមទាំងបុគ្គលិកនៃក្រសួងនេះ លោក យួន ណៃ ចាងហ្វាងមន្ទីរសង្ឃពេទ្យព្រះកុសុមៈ លោក ជា-អ៊ុន នាយកក្រុមពិធីការក្នុងព្រះបរមរាជវាំង ព្រមទាំងមន្ត្រីអ្នករាជការជាច្រើនទៀត បានយាង បានអញ្ជើញមកកាន់កន្លែងប្រកបពិធី ។

នៅវេលាម៉ោង ៨ និង ៣០ នាទីព្រឹក ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះមហាក្សត្រិយានី ដោយមានសម្តេចចៅហ្វាវាំង វរៈវៀងជ័យអធិបតីស្រីគ្គារ ប៉ែន-នុត ឯកឧត្តម សាន-យុន អគ្គនាយកនៃក្រសួងនានាក្នុងព្រះបរមរាជវាំង ឯកឧត្តម ជូ-ព្រឿង ទ្រឿង-កាង ទេព-ផន មៀច-គន្ធ ជាសមាជិកឧត្តមក្រុមប្រឹក្សាព្រះមហាក្សត្រ លោក អ៊ុង-ហុងសាត លេខាធិការរងទី ១ នៃឧត្តមក្រុមប្រឹក្សាព្រះមហាក្សត្រ លោក ម៉ៅ-ចយ ទីប្រឹក្សាបច្ចេកទេស នៅការិយាល័យការងារប្រជា-

ភស្តុទីងលោកវរសេនីយត្រី ស-ហោ ព្រះរាជង្គរក្ស ហែអមព្រះអង្គផង បានស្តេចយាងមកដល់កន្លែងប្រកបពិធី ដែលពេលនោះក្រុមទាហានរក្សាព្រះអង្គ និងក្រុមភ្លេងព្រះរាជទ្រព្យបានលើកអាវុធវន្ទា ទាំងបន្លឺបទបវរ-យាត្រាថ្វាយជាព្រះរាជកិត្តិយស ។

ក្រោយដែលព្រះមហាក្សត្របានទទួលបដិសណ្ឋារកិច្ចអំពីឥស្សរជនទីងយានចូលថ្វាយបង្គំព្រះសង្ឃរួចហើយ តមក ក្រុមតន្ត្រីព្រះរាជទ្រព្យក៏បានបន្លឺឡើង នូវបទនគររាជថ្វាយព្រះមហាក្សត្រជាទីគោរព ។

ឥស្សរជនទាំងឡាយដែលនៅរង់ចាំថ្វាយបង្គំទទួលទីងសំដែងសេចក្តីស្វាមីភក្តិចំពោះព្រះមហាក្សត្រទាំងពីរព្រះអង្គ ក៏បានដង្ហែព្រះអង្គចូលគង់ប្រថាប់លើព្រះសុវណ្ណកោច្ឆៈ នៅយ៉ុតុត្តិកវិទ្យាល័យព្រះសុរាម្រឹត ។

ក្រោយដែលព្រះមហាក្សត្រទាំងពីរព្រះអង្គទ្រង់សំដែងគារវកិច្ច ចំ-ពោះព្រះសង្ឃ ដែលមានសម្តេចព្រះសង្ឃនាយកទាំងពីរគណៈជាប្រធានរួចហើយ តមក លោក ស៊ូ-ណៃម រដ្ឋលេខាធិការក្រសួងធម្មការ បានថ្លែងសុន្ទរកថាមួយ មានសេចក្តីដូចតទៅនេះ : -

សូមព្រះតេជះតំកល់លើត្បូង

សូមព្រះរាជទានក្រាបបង្គំទូល ព្រះករុណាជាអម្ចាស់ជីវិតទាំង ២ ព្រះអង្គ,

សូមព្រះរាជទានក្រាបបង្គំទូល សម្តេចព្រះឧបយុវរាជ ព្រះបិតាឯករាជ្យជាតិ

សូមទ្រង់ជ្រាបក្រោមលម្អងធូលីព្រះបាទ ។

ក្នុងនាមនៃក្រសួងធម្មការ និងសាសនសិក្សាធិការ និងក្នុងនាមផ្ទាល់នៃទូលព្រះបង្គំជាខ្ញុំ ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានថ្លែងនូវអំណរព្រះករុណាធិគុណជាទីបំផុត ព្រមទាំងកតញ្ញូធម៌ដ៏ជ្រាលជ្រៅ និងដោយគោរពចំពោះព្រះករុណាថ្លៃវិសេសទាំង២ព្រះអង្គ និងសម្តេចដែលទ្រង់សព្វព្រះរាជហឫទ័យ ស្តេចយាងមកជាព្រះរាជាធិបតីក្នុងឱកាសពិធីបើកអនុសំវច្ឆរៈមហាសន្និបាត មន្ត្រីសង្ឃ ទី ១៦ សម្រាប់ឆ្នាំកុរនេះ ដោយសោមនស្សចេតនាដ៏ឧត្តម ។

សូមទ្រង់ព្រះមេត្តាប្រោស,

ក្នុងវារៈតទៅ ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានព្រះរាជឱកាស លម្អងធូលីព្រះបាទ ដើម្បីប្រគេនពត៌មានខ្លះ ចំពោះព្រះថេរានុត្ថេរៈ មានសម្តេចទាំង ២ ព្រះអង្គជាប្រធាន ដែលបាននិមន្តមកប្រមូលប្រជុំក្នុងទីនេះ ។

សូមថ្វាយបង្គំសម្តេចទាំង ២ ព្រះអង្គ ព្រមទាំងព្រះថេរានុត្ថេរៈជាព្រះរាជាគណៈ មេគណ អនុគណ ចៅអធិការទាំងអស់ដោយគោរព ។

ខ្ញុំព្រះករុណា សូមថ្លែងនូវសោមនស្សរីករាយយ៉ាងក្រៃលែងចំពោះសម្តេចនិងព្រះករុណាគ្រប់ព្រះអង្គ ព្រោះការជួបជុំនេះ ជាឱកាសមួយ

ប្រពៃ ដែលអាចបង្កើតមកនូវសេចក្តីរុងរឿង សេចក្តីចំរើនជាអនេកប្បការ ដល់ជាតិ សាសនា ព្រះមហាក្សត្រ ។

សម្តេច,

ព្រះករុណាគ្រប់ព្រះអង្គ,

ដូចសម្តេច ព្រះករុណាគ្រប់ព្រះអង្គ បានជ្រាបច្បាស់ស្រាប់ តាំងពីដើមរៀងដរាបមក ព្រះពុទ្ធសាសនាតែងបានទទួលនូវការវិវត្តន៍ត ៗ ជាលំដាប់ហូតមកដល់សព្វថ្ងៃ ដែលបានទទួលនូវឯកភាពដ៏បរិបូណ៌នេះ ។ ខ្មែរទូទៅសុទ្ធសឹងជាពុទ្ធសាសនិក មានសទ្ធាដ៏បរិសុទ្ធចំពោះត្រៃសរណគមន៍ ៗ លទ្ធផលដ៏ប្រសើរ គឺការរីកសាយទូលំទូលាយនៃព្រះពុទ្ធសាសនាក្នុងកម្ពុជាណាចក្រនេះ ក៏អាស្រ័យដោយបុព្វហេតុជាច្រើន តែជាពិសេសគឺដោយព្រះរាជូបត្ថម្ភដ៏ជ្រះថ្លាយ៉ាំងមុះមុត នៃព្រះមហាក្សត្រយើងគ្រប់ៗ អង្គ ព្រមទាំងព្រះរាជវង្សានុវង្ស ។

សព្វថ្ងៃនេះ ក៏ដូចកាលជំនាន់ព្រះបាទអសោករាជ ព្រះរាជបល្ល័ង្កទាំង ព្រះរាជវង្សានុវង្ស ព្រមដោយព្រះរាជរដ្ឋាភិបាល ដែលមានសម្តេចព្រះឧបយុវរាជ ជាព្រះអគ្គនាយកមគ្គុទ្ទេសក៍ បានយកព្រះទ័យទុកដាក់ ខំខ្នះខ្នែងលើកស្ទួយពុទ្ធនិយមឲ្យមានរបៀបរៀបរយ សេចក្តីថ្លៃថ្នូរខ្ពង់ខ្ពស់សមជាទីពឹងផ្អែកនៃសព្វសត្វ ទីជាទីគោរពនៃជនានុជនគ្រប់ប្រភេទគ្រប់ជាន់ថ្នាក់ បានធ្វើឲ្យកិត្តិសព្ទ កិត្តិនាម នៃព្រះពុទ្ធសាសនាឲ្យលេចឮខ្ទរខ្ទឹពេញ

ពិភពលោក ។ ប្រទេសទាំងឡាយដែលជាពុទ្ធសាសនិកក្តី ដែលពុំមែនជាពុទ្ធសាសនិកក្តី សឹងបានសំដែងនូវសេចក្តីកោតសរសើរ បានទទួលស្គាល់ថា ប្រទេសកម្ពុជាមានភ័ព្វសំណាងល្អណាស់ ព្រោះជារដ្ឋកាន់ព្រះពុទ្ធសាសនា មានសេចក្តីប្រតិបត្តិហ្មត់ចត់ពុំមានល្អៀងពីព្រះពុទ្ធោវាទឡើយ ព្រោះព្រះសង្ឃខ្មែរទាំងឡាយ ទោះភិក្ខុក្តី សាមណេរក្តី ក្រោមការដឹកនាំនៃសម្តេច ទ្រង់ព្រះតេជព្រះគុណ មេគណ អនុគណ ចៅអធិការទូទាំងប្រទេស មិនបានធ្វេសប្រហែស ពុំបានភ្លេចនូវបណ្តាំព្រះពុទ្ធបរមគ្រូដែលទ្រង់បានពោលថា: «ព្រះពុទ្ធសាសនាទីនបានចុះទ្រើងក្តី ទីនសាបសូន្យទៅវិញក្តី គឺអាស្រ័យដោយភូនចៅគថាគត» ។

ដើម្បីជាទស្សនានុត្តរិយៈ ខ្ញុំព្រះករុណាសូមបញ្ជាក់ថា ទោះជាមានមធ្យោបាយដ៏ខ្សត់ខ្សោយយ៉ាងណាក៏ដោយ គង់គ្រប់ខណ្ឌនៃពលនាសង្គមកស្រ្តនិយមប្រទេសយើងបានទទួលគម្ពីរដ៏ពេញទំហឹងដល់ព្រះពុទ្ធសាសនា ថែមទាំងបានរៀបចំពិធីបុណ្យធំៗ យ៉ាងដូចជាបុណ្យអរហន្តធាតុ បុណ្យពុទ្ធសករាជ២៥០០ដ៏ឧត្តុង្គឧត្តមទីនបានចាត់គណៈប្រតិភូជាច្រើនឲ្យទៅរួបរួមក្នុងពិធីបុណ្យពុទ្ធសករាជ២៥០០ ច្រើនគរ ឲ្យទៅរួមប្រជុំក្នុងសន្និបាតនានា មានមហាសន្និបាតនៃពុទ្ធិកសមាគមពិភពលោកជាដើម ។

សូមទ្រង់ព្រះមេត្តាប្រោស,

ក្នុងនាមនៃពុទ្ធមាមកជនទាំងឡាយ ទូលព្រះបង្គំជាខ្ញុំ សូមព្រះបរម-

រាជានុញ្ញាតព្រះករុណាថ្ងៃវិសេស ក្នុងឱកាសដ៏ប្រពៃនេះ ដើម្បីថ្លែងជាជូនកតញ្ញូធម៌យ៉ាងជ្រាលជ្រៅ ជាពិសេស ចំពោះសម្តេចព្រះបិតាឯករាជ្យជាតិ ដែលក្នុងពេលថ្មីនេះ ទ្រង់បានគាំទ្រព្រះហឫទ័យថាទីងបាក់ឲ្យរៀបចំធ្វើមហាសន្និបាតទី ៦ នៃពុទ្ធសមាគមពិភពលោក សម្រាប់ឆ្នាំ ១៩៦០ នៅក្នុងរាជធានីភ្នំពេញយើង ។ មហាសន្និបាតនេះ ដែលនឹងត្រូវមូលប្រជុំប្រហែល ៣០ ជាយ គណៈប្រតិភូនៃប្រទេសកាន់ព្រះពុទ្ធ-សាសនា មុខជានឹងនាំឲ្យគុណធម៌ដ៏ប្រសើរ ដែលជាមូលដ្ឋាននៃព្រះពុទ្ធសាសនា បានដល់ អហិំសា គឺការមិនបៀតបៀនដល់អ្នកដទៃ មេត្តាធម៌ គឺការផ្សាយសេចក្តីអាណិតអាសូរទៅកសត្វសត្វ ករុណាធម៌ គឺការផ្សាយសេចក្តីរាប់អានសង្គ្រោះទៅកសត្វសត្វ សប្បុរិសធម៌ គឺការមិនធ្វើអំពើអាក្រក់ដល់មនុស្សដោយកាយវាចាចិត្តជាដើម ដើម្បីសន្តិភាព ពោលគឺសេចក្តីសុខ សេចក្តីចំរើននៃសាកលលោក ព្រមទាំងធ្វើឲ្យសាកលលោក ស្គាល់នូវគុណភាពនៃប្រទេសខ្មែរកាន់តែជាក់ច្បាស់ឡើងទៀត ។

មួយផ្នែកវិញទៀត ក្នុងឋានៈជាពលរដ្ឋខ្មែរមួយរូប ដែលចង់ឲ្យជាតិ សាសនា ព្រះមហាក្សត្រ ពោលគឺប្រជាជាតិបានស្គាល់នូវវិឡូន-ភាពគ្រប់គ្រាន់ ឲ្យបានទទួលនូវសេចក្តីចំរើនរុងរឿង សមនឹងឋានៈជាអារ្យប្រទេស ទាំងក្នុងឋានៈជាសមាជិកនៃព្រះរាជរដ្ឋាភិបាល ទទួលភារៈ

ខាងផ្នែកសាសនា ទូលព្រះបង្គំជាខ្ញុំ មានសេចក្តីរីករាយជាពន់ពេក ដោយបានបង្កើតឃើញថា ព្រះថេរានុត្ថេរទាំងឡាយ ដែលឋិតនៅក្នុងព្រះរាជាណាចក្រ នៅក្រៅព្រះរាជាណាចក្រ ឬដែលបានចេញទៅបន្តវិជ្ជានៅបរទេសក្តី សឹងបានជ្រាបនឹងយល់ច្បាស់នូវគោលហេតុទាំងឡាយ ដែលទូលព្រះបង្គំជាខ្ញុំក្រោមល្អងធូលីព្រះបាទ បានពណ៌នាមកត្រួស ៗ ពីខាងដើមនេះ ។ ព្រះសង្ឃដែលធ្លាប់តែជួយទ្រទ្រង់នូវជាតិនិយមខ្មែរ គោលគឺជាតិ សាសនា ព្រះមហាក្សត្រ ដែលបានទ្រទ្រង់រៀងរាបមកនូវអារ្យធម៌ នូវវប្បធម៌ខ្មែរ ក៏បានជួយទ្រទ្រង់ពេញទំហឹងទាំងដោយកាយ ទាំងដោយវាចា ទាំងដោយចិត្ត នូវព្រះរាជបេសកកម្ម នឹងព្រះរាជនយោបាយដ៏ឆ្នើមនៃសម្តេចព្រះឧបយុវរាជ គឺនយោបាយអព្យាក្រឹត ។ អព្យាក្រឹតជាមាគ៌ាស្របនឹងផ្លូវដែលព្រះពុទ្ធបរមគ្រូបានត្រាយទុកមក នឹងនយោបាយលើកតំកើងជីវភាពពលរដ្ឋ ព្រោះកាលបើពលរដ្ឋដែលជាពុទ្ធសាសនិកជននេះ មិនបានសម្បូណ៌សប្បាយខ្ពស់ថ្កើងទេ ព្រះពុទ្ធសាសនាដែលមានព្រះសង្ឃជាតំណាង ក៏ពុំអាចលូតលាស់ឲ្យសមតាមសេចក្តីប្រាថ្នា នៃយើងទាំងអស់គ្នាឡើយ ។ ដូច្នោះហើយ បានជាពុទ្ធចក្រ នឹងអាណាចក្រក្នុងប្រទេស មានការប្រាស្រ័យគ្នាកាន់តែជិតស្និទ្ធឡើង នឹងអាចជួយបំពេញមុខការ នឹងប្រយោជន៍ផ្សេង ៗ ដល់គ្នានឹងគ្នាទៅវិញទៅមក ។

មុននឹងបញ្ចប់ ទូលព្រះបង្គំជាខ្ញុំ ក្រោមល្អងធូលីព្រះបាទ ខ្ញុំព្រះករុណា ជឿជាក់ចំពោះគាថានៃព្រះពុទ្ធបរមគ្រូ ដែលមានសម្ដីថា

សច្ចំ វេ អមតា វាចា ពាក្យសច្ចៈមិនចេះស្លាប់,

សតញ្ច ធម្មោ ន ជរំ ឧបេតិ ធម៌របស់សប្បុរសមិនចេះចាស់ ។

គឺអាស្រ័យអានិសង្សនៃសេចក្ដីបរិសុទ្ធទាំងនេះ ដោយអានិសង្សនៃកុសលផលដែលខ្ញុំបានសាងទុកមកជាយូរអង្វែង នូវអំពើល្អ អំពើត្រូវ ដែលកំពង់តែកសាងសព្វថ្ងៃនេះ ដោយព្រះតេជបារមីនៃព្រះករុណាថ្លៃវិសេសទាំង ៣ ព្រះអង្គ ប្រទេសកម្ពុជានឹងពុំជួបប្រទះនូវឧបទ្ទវន្តរាយអ្វីមួយឡើយ ។ បច្ចាមិត្រ សត្រូវទាំងឡាយ មានពួកក្បត់ឧត្តមប្រយោជន៍នៃជាតិ សាសនា ព្រះមហាក្សត្រ ជាដើម មុខជានឹងវិនាសសាបសូន្យ ។

ជាទីបំផុត ទូលព្រះបង្គំជាខ្ញុំក្រោមល្អងធូលីព្រះបាទ សូមប្រសិទ្ធិពរបួងសួងដល់គុណព្រះរតនត្រ័យ ព្រមទាំងទេវតាទាំងមួយម៉ឺនលោកធាតុ សូមជួយអភិបាលព្រះពុទ្ធសាសនា ព្រមទាំងព្រះករុណាថ្លៃវិសេសទាំង ២ ព្រះអង្គ និងសម្ដេចសហជីវិន សូមព្រះអង្គគង់នៅជាបរមសុខក្នុង បរិកជ·សម្បត្តិ ដើម្បីជាម្លប់ដ៏ត្រជាក់នៃប្រជាពលរដ្ឋគ្រប់ប្រភេទ ផង ។

មួយវិញទៀត សូមព្រះករុណាគ្រប់ព្រះអង្គ មានសម្ដេចទាំង ២ ជាប្រធាន បានប្រកបដោយសេចក្ដីសុខ·ចំរើនគ្រប់ប្រការ រក្សាព្រះពុទ្ធសា·

សនាឲ្យបានចំរើនរុងរឿងរហូតដល់ ៥០០០ ព្រះវស្សា កុំបីឃ្លាតឡើយ ។

លុះចប់សុន្ទរកថានេះហើយ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់សព្វព្រះរាជហឫទ័យ ថ្លែងព្រះរាជសុន្ទរកថាមួយដូចតទៅនេះ -

សូមពិតពុទ្ធដីកា សម្តេច ព្រះតេជព្រះគុណគ្រប់ព្រះអង្គ,

ខ្ញុំករុណាមានសេចក្តីសោមនស្សយ៉ាងក្រៃលែង ដោយបានឃើញ សម្តេច ព្រះតេជព្រះគុណទាំងអស់ និមន្តមកកាន់មហាសន្និបាតនេះ ដើម្បីជ្រាបនូវកិច្ចការទាំងឡាយខាងពុទ្ធចក្រនឹងអាណាចក្រ ដែលបានប្រព្រឹត្តតាំងពីក្នុងមហាសន្និបាតទី ១៤ មកទល់នឹងសព្វថ្ងៃនេះ ព្រមទាំងកិច្ចការដែលនឹងប្រព្រឹត្តទៅអនាគតទៀតផង ។

ខ្ញុំករុណាមានសេចក្តីជឿជាក់ថា សម្តេច ព្រះតេជព្រះគុណគ្រប់អង្គ ដែលបានមកជួបជុំក្នុងទីនេះក្តី ដែលពុំបាននិមន្តមកក្តី នឹងជួយជ្រោមជ្រែងព្រះពុទ្ធសាសនានៅក្នុងប្រទេសយើងនេះ ឲ្យរុងរឿងតែចំរើនលើសដើម ដោយការមិនបង្កើតនូវវត្តអារាមយើកយោក ដោយការទំនុកបំរុងរៀបចំវត្តអារាមដែលមានហើយ ឲ្យមានសុភាពកាន់តែថ្លៃថ្នូរឡើង ព្រមដោយការគោរពធម្មវិន័យ ឲ្យបានសម្រេចនូវមគ្គផលដ៏បរិបូណ៌តាមមាគ៌ាដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាយទុកមក ។

ម្យ៉ាងទៀត ខ្ញុំករុណាមានសេចក្តីរីករាយជាពន់ពេក ដោយបានឃើញថា ក្នុងពេលដែលព្រះពុទ្ធសាសនាបានស្គាល់នូវសេចក្តីរុងរឿង

យ៉ាងប្រសើរក្នុងបច្ចុប្បន្នកាលនេះ សម្តេច ព្រះតេជព្រះគុណគ្រប់ព្រះអង្គ បានជួយឧបត្ថម្ភដោយមុឺនម៉ាត់ដល់រាជរដ្ឋាភិបាល ក្នុងការបំរើមាតុប្រទេស ឲ្យបានដំណើរយ៉ាងឆាប់រហ័សទៅកាន់វឌ្ឍនភាព និងសុភមង្គលដ៏ឧត្តមតរៀងទៅ ។

ទៅទីបំផុត ខ្ញុំករុណា សូមប្រគេនសព្ទសាធុការពរចំពោះសម្តេចព្រះតេជព្រះគុណគ្រប់ព្រះអង្គ សូមឲ្យបានប្រកបដោយនូវសេចក្តីសុខចំរើន រហូតដល់ព្រះនិព្វាន ហើយខ្ញុំករុណាសូមប្រកាសបើកមហាសន្និបាតលើកទី ១៦ ។

លុះចប់ព្រះរាជសុន្ទរកថានេះហើយ ព្រះតេជព្រះគុណព្រះសាសនសំវរ កាន់-កែល អនុគណស្រុកមុខកំពូល (កណ្តាល) បានថ្លែងសុន្ទរកថាតមកទៀត មានសេចក្តីដូចតទៅនេះ ៖

សូមថ្វាយព្រះពរព្រះករុណាជាអម្ចាស់ជីវិតទាំងពីរព្រះអង្គ ,

សូមថ្វាយព្រះពរសម្តេចព្រះឧបយុវរាជ ព្រះបិតាឯករាជ្យជាតិ

សូមទ្រង់ជ្រាប ។

ក្នុងនាមនៃមន្ត្រីសង្ឃនិងព្រះថេរានុត្ថេរៈទាំងអស់ សូមថ្វាយព្រះពរថ្វាយនូវអំណរព្រះគុណដ៏ខ្ពង់ខ្ពស់បំផុត ចំពោះព្រះករុណាថ្លៃវិសេសទាំងពីរព្រះអង្គ និងសម្តេចព្រះបិតាឯករាជ្យជាតិ ដែលទ្រង់ព្រះមេត្តាប្រោសស្តេចយាងមកជាព្រះរាជាធិបតី ក្នុងពិធីអនុសំវច្ឆរៈមហាសន្និបាតទី ១៦នៃ

មន្ត្រីបរិស័ទនេះដោយព្រះរាជហឫទ័យសោមនស្សចំពោះសង្ឃមហាសន្និបាត។

សូមទ្រង់ព្រះមេត្តាប្រោស,

ក្នុងបំផាប់តទៅ អាត្មាភាពសូមព្រះរាជទានព្រះរាជឱកាសដើម្បីថ្វាយពត៌មានខ្លះ ព្រមទាំងធ្វើយតបសុន្ទរកថានៃលោករដ្ឋលេខាធិការក្រសួងធម្មការ ដូចសេចក្តីរៀបរាប់ថ្វាយដោយសង្ខេបតទៅនេះ ៖

ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា ដែលទទួលនូវវឌ្ឍនភាពច្រើនរុងរឿង ជាប់តមកដល់សព្វថ្ងៃនេះ ដោយអំណាចព្រះមហាក្សត្រដែលមានព្រះរាជហឫទ័យជ្រះថ្លាទំនុកបំរុងព្រះពុទ្ធសាសនា ព្រមទាំងពុទ្ធបរិស័ទ ទាំងបព្វជិតទាំងគ្រហស្ថ តាំងពីអតីតកាលរៀងកបដកបមករហូតដល់សព្វថ្ងៃនេះ ព្រះករុណាជាម្ចាស់ជីវិតទាំងពីរព្រះអង្គ ទីងសម្តេចព្រះបិតាឯករាជ្យជាតិ សុទ្ធតែជាអគ្គពុទ្ធសាសនូបត្ថម្ភក៍ ព្រមទាំងព្រះរាជរដ្ឋាភិបាល ដែលមានសម្តេចព្រះឧបយុវរាជជាព្រះអគ្គនាយកនៃគណរដ្ឋាភិបាល បានបំពេញព្រះរាជបេសកកម្ម ទាំងផ្លូវពុទ្ធចក្រនិងអាណាចក្រ ឲ្យមានតុល្យភាព ឲ្យមានរបៀបរៀបរយល្អ ។ កិត្តិស័ព្ទដ៏ពិរោះរបស់ព្រះពុទ្ធសាសនានៃប្រទេសកម្ពុជាយើង សឹងល្បីលេចឮប្រាកដក្នុងសកលលោក ។ ក្នុងបណ្តាប្រទេសអ្នកកាន់ព្រះពុទ្ធសាសនាឬប្រទេសក្រៅពីនេះ តែងលាន់ឮពាក្យសរសើរថា ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា ជាពុទ្ធសាសនាដ៏បរិសុទ្ធ ដែលប្រជាពលរដ្ឋតែងសិក្សា

រៀនសូត្រប្រតិបត្តិដោយម៉ត់ចត់ប្រកាសខ្លួនថាជាពុទ្ធសាសនិកគ្រប់ៗ គ្នា តាំងការគ្រប់គ្រងគណៈសង្ឃនៃកម្ពុជរដ្ឋ ក៏កាន់តែមានរបៀបរៀបរយ មានល្បឿនឈមទៅរកវឌ្ឍនភាពរៀងរាល់ឆ្នាំ ក្រោមការដឹកនាំនៃសម្តេចសង្ឃនាយកទាំងពីរគណៈ ព្រមទាំងមន្ត្រីសង្ឃគ្រប់ស្រុក គ្រប់ខេត្ត ។

ព្រះពុទ្ធសាសនានៃប្រទេសកម្ពុជាយើង ជាសាសនាឋិតនៅក្នុងការឧបត្ថម្ភនៃព្រះរាជរដ្ឋាភិបាល ។ រដ្ឋធម្មនុញ្ញក៏មានចែងថា "ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ" ។ ពាក្យថាសាសនារបស់រដ្ឋនេះ គឺសាសនារបស់ប្រទេសខ្មែរទាំងមូល ។ គោលបំណងរបស់មន្ត្រីសង្ឃ ដែលមានសម្តេចព្រះសង្ឃនាយកទាំងពីរព្រះអង្គជាប្រធាន ដើម្បីឲ្យព្រះពុទ្ធសាសនារីកធ្លាយឈានទៅរកសេចក្តីចំរើនរុងរឿង ។ គោលបំណងនោះក៏ចេះតែមានល្បឿនចំរើនឡើងម្តងបន្តិចៗ ដោយកម្លាំងនៃសេចក្តីប្រឹងប្រែងរបស់គណៈសង្ឃ ដែលប្រាស្រ័យទាក់ទងរួមកម្លាំងគ្នា ជាមួយនឹងព្រះរាជរដ្ឋាភិបាលមានក្រសួងធម្មការជាដើម ។ គោលបំណងក្នុងការពង្រីកព្រះពុទ្ធសាសនានៃគណៈសង្ឃនោះ ទោះបីពុំទាន់សម្រេចដោយបរិបូណ៌ ក៏ឈ្មោះថា មានសេចក្តីចំរើនឈានទៅមុខ ជាលំដាប់រៀងរាល់ឆ្នាំដែរ ។

ការផ្តើមធ្វើអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃតាមថ្ងៃការ ដោយមានព្រះករុណាជាអម្ចាស់ជីវិតនឹងសម្តេចជាព្រះមគ្គុទ្ទេសក៍នេះ ជាការប្រសើរខ្ពង់ខ្ពស់ក្រៃលែង ដើម្បីពិនិត្យស្ទាបស្ទង់ការរីកសេចក្តីចំរើនលូតលាស់នៃ

ជាតិ សាសនា ព្រះមហាក្សត្រ ។ ការប្រជុំមន្ត្រីសង្ឃនេះ រាប់ថាជាករណីយកិច្ចមួយរបស់ព្រះរាជរដ្ឋាភិបាល ដែលត្រូវមានការប្រាស្រ័យទាក់ទងគ្នារវាងរាជរដ្ឋាភិបាលនិងគណៈសង្ឃ ដែលជាចំណុចមួយយ៉ាងធំ ដើម្បីមិត្តភាពនៃពុទ្ធសាសនិកជនដូចគ្នា ។ ព្រះបរមពុទ្ធោវាទក្នុងបរិហា-នីយធម្មសូត្រថា "ការប្រជុំគ្នារឿយ ៗ ដើម្បីពិគ្រោះពិភាក្សាគ្នានេះ ទុកជាវឌ្ឍនការៈមួយ អាចនាំមកនូវសេចក្ដីសុខចំរើនដោយពិត ព្រោះជាហេតុនាំឱ្យបាននូវទូលដំណើររបស់ការប្រជុំទាំងអស់គ្នា ចម្លងការដឹងឮនោះអំពីទីប្រជុំជាមួយគ្នា អាចនឹងបាននូវយោបល់គ្នាទៅវិញទៅមក ទទួលស្គាល់ ទទួលគោរពនូវដំណើររបស់ទីប្រជុំជាមួយគ្នា ។

ពិធីអនុបព្វៈមហាបន្ទុបាត ក្រោមព្រះរាជាធិបតីភាពនេះ ជាអង្គការមួយដ៏ប្រសើរ ទុកជាចំណងនៃសាមគ្គីភាពរវាងបព្វជិតនិងបព្វជិតរវាងពុទ្ធចក្រនិងអាណាចក្រ ដើម្បីទុកជាទិដ្ឋានុគតិនៃប្រជាពលរដ្ឋពុទ្ធបរិស័ទជាស្ពានតរៀងទៅ ។ គ្រានការនៃគណសង្ឃក្នុងវត្តទូកសិក្សាក្តី ក្នុងការគ្រប់គ្រងសង្ឃមណ្ឌលក្តី ទោះបីនៅមានបញ្ហាសាំញ៉ាំខ្លះ ពុំទាន់បានដោះស្រាយនៅឡើយ ក៏ទុកសង្ឃឹមថា អំណើះតទៅនឹងចេះតែរកមធ្យោ-បាយរៀបចំដោះស្រាយបញ្ហា ដែលនៅសេសសល់ឱ្យរួចជុះស្រឡះពុំខាន ដោយរួមជាមួយនឹងព្រះរាជរដ្ឋាភិបាល ។

ច្បាប់របស់ព្រះរាជាណាចក្រ ឬច្បាប់ព្រះពុទ្ធសាសនាដែលកើតមាន

ឡើង ពុំអាចនឹងអនុវត្តន៍ឲ្យគ្រប់គ្រាន់បានក្លាយ ៗ ទេ នេះជាទំនៀមរបស់ច្បាប់ក្នុងសាកលលោក ៗ

ដើម្បីកាវគេវែកញែករកសេចក្ដីពិត រកសេចក្ដីសុខសេចក្ដីចំរើនដល់ជាតិ សាសនា មហាក្សត្រនេះ ត្រូវអាស្រ័យការប្រជុំរឿយ ៗ ដែលទុកថាជាគោលការមួយដ៏ប្រសើរ ក្នុងបណ្ដាគោលការឯទៀត ៗ ។

ព្រះពុទ្ធសាសនាមានទ្រឹស្ដី មានអត្ថបទល្អច្រើនណាស់ ដែលអាចនាំអ្នកប្រតិបត្តិឲ្យបានទទួលសេចក្ដីសុខសប្បាយ តាំងអំពីជាតិនេះ រហូតដល់មគ្គផលនិព្វាន ។

ព្រះពុទ្ធសាសនាប្រៀបដូចជានាវាមួយរបស់រដ្ឋ ដែលមានសម្ដេចព្រះសង្ឃនាយក មន្ត្រីសង្ឃ នឹងព្រះថេរានុត្ថេរៈ ជាអ្នកកាន់ចង្កូត ៗ ពុទ្ធបរិស័ទខាងគ្រហស្ថគ្រប់ជាន់ថ្នាក់ ជាអ្នកសុំជាអ្នកចែវ ទើបពុទ្ធនាវាអាចលឿនទៅកាន់កាះត្រើយ គឺសេចក្ដីចំរើនបាន ៗ ព្រះពុទ្ធសាសនាប្រាប់ប្រយោជន៍បច្ចុប្បន្នទាំងបរលោក ស្រោចស្រង់សត្វលោកឲ្យរួចចាកទុក្ខភ័យ រួចចាកពាលភាព ទលិទ្ទភាព គឺភាពទាលក្រ ឲ្យឈមទៅរកបណ្ឌិតភាព មហទ្ធភាព គឺភាពជាអ្នកប្រាជ្ញ នឹងភាពមានបានទ្រព្យសម្បត្តិគ្រប់យ៉ាង ។

នៅអវសាននេះ អាត្មាភាព ក្នុងនាមព្រះសង្ឃទាំងឡាយ សូមថ្វាយព្រះពរបវរសួស្ដី ជោគជ័យមហាមង្គលវិបុលសុខគ្រប់ប្រការ ចំពោះ

ព្រះករុណាជាម្ចាស់ជីវិតទាំងពីរព្រះអង្គ ចំពោះសម្ដេចព្រះឧបយុវរាជ ជាអគ្គមគ្គុទ្ទេសក៍ខ្ពស់បំផុតរបស់ប្រទេសកម្ពុជា ។ សូមព្រះមហាក្សត្រ ទាំងពីរព្រះអង្គប្រកបដោយព្រះជន្មវស្សាយឺនយូរ ទីឃាយុកាល មានព្រះសុខភាពបរិបូណ៌ឈ្នះមារសត្រូវគ្រប់ទិសទី កុំបីឃ្លៀងឃ្លាតឡើយ ។

បន្ទាប់មក លោករដ្ឋលេខាធិការក្រសួងធម្មការ ក៏បានលើកយកសៀវភៅពុទ្ធិកសិក្សា លេខពិសេសថ្វាយព្រះនរបតីទាំងពីរព្រះអង្គ រួចហើយព្រះនរបតីទាំងពីរព្រះអង្គ មានព្រះរាជឧត្ដមក្រាប្រាស្រ័យជាមួយព្រះសង្ឃដែលនិមន្តមកកាន់មហាសន្និបាត ប្រកបដោយសេចក្ដីរីករាយជាទីបំផុត ។

នៅវេលាម៉ោង ៩, ៣០នាទី ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងសម្ដេចព្រះមហាក្សត្រិយានី ស្ដេចយាងត្រឡប់ទៅកាន់ព្រះបរមរាជវាំងវិញ ដោយមានឥស្សរជនជាពលបរិពារដដែលហែហមព្រះអង្គ និងមានធ្វើការកិច្ចថ្វាយ ជាព្រះរាជកិត្តិយសដូចកាលស្ដេចយាងមក ។

នៅវេលាម៉ោង១០,៤០នាទីព្រឹកនោះ មន្ត្រីអ្នករាជការនៅក្រសួងធម្មការបានចាត់ចែងប្រគេនភត្តាហារចំពោះព្រះសង្ឃ ក្នុងព្រះបរមនាមនៃព្រះមហាក្សត្រទាំងពីរព្រះអង្គ នៅទីចំពោះមុខលោករដ្ឋលេខាធិការក្រសួងធម្មការ ក្នុងគ្រឹះស្ថានព្រះសីហនុ ជាការបញ្ចប់ពិធីនៅពេលព្រឹក

នោះ ។

លុះដល់ពេលវេលាថ្ងៃដែល សម្តេចព្រះបិតាឯករាជ្យជាតិ ព្រះអង្គទ្រង់ចៀតយកឱកាសដ៏ប្រសើរយាងមកធ្វើកិច្ចប្រាស្រ័យ ជាមួយនឹងព្រះសង្ឃទាំងឡាយ ដែលគង់នៅក្នុងរាជធានីនិងនិមន្តមកពីខេត្តក្រៅដើម្បីមករួបរួមក្នុងពិធីអនុសាវរីយ៍មហាសន្និបាតមន្ត្រីសង្ឃទី១៦ ដែលធ្វើឡើងនៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ។

នៅមុនពេលដែលសម្តេចទ្រង់យាងមកដល់ យើងបានសង្កេតឃើញព្រះសង្ឃ ដែលមានសមណសក្តិទាក់ជាគណៈ ឋានានុក្រម និងលោកគ្រូចៅអធិការ ព្រមទាំងព្រះសង្ឃទាំងពីរគណៈដែលគង់នៅរាជធានីនិងនិមន្តមកពីខេត្តក្រៅជាច្រើនរយអង្គ ដែលមានសម្តេចព្រះសង្ឃនាយកទាំងពីរគណៈជាប្រធាន និងពុទ្ធបរិស័ទជាច្រើនរយនាក់ បាននិមន្តបានអញ្ជើញមកដល់ក្នុងប្រារព្ធពិធី ។

ឥស្សរជនជាន់ខ្ពស់ទាំងឡាយដែលយើងបានសង្កេតឃើញជាអាទិ៍គឺ លោកជួប-ហែល, លោកឯក-យីអ៊ុន ជាប្រធាននៃសភាទាំងពីរ ព្រមទាំងសមាជិកខ្លះ, លោះសឺន-សាន ឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងការបរទេស លោកញឹក-ជូឡុង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងផែនការអប់រំជាតិ, ព្រមទាំងសមាជិករាជរដ្ឋាភិបាលខ្លះ និងអ្នករាជការក្រសួងធម្មការជាច្រើនទៀត អញ្ជើញមកកាន់ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត

ដើម្បីរង់ចាំទទួល និងក្រាបថ្វាយបង្គំគោរពសម្តេចព្រះបិតាឯករាជ្យជាតិ ។

នៅម៉ោង៤,៥នាទីរសៀល សម្តេចប្រមុខរាជរដ្ឋាភិបាល ដោយមានសម្តេច ប៉ែន-នុត ព្រឹទ្ធសមាជិកឧត្តមក្រុមប្រឹក្សាព្រះរាជា, ឯកឧត្តម ជូ-ព្រឿន, ទេព-ផន, ទ្រឿង-កាង ជាសមាជិកឧត្តមក្រុមប្រឹក្សាព្រះរាជា, លោក អ៊ុង-ហុងសាធ អគ្គលេខាធិការរងទី១ នៃឧត្តមក្រុមប្រឹក្សាព្រះរាជា, លោក ម៉ៅ-ចយ ទីប្រឹក្សាបច្ចេកទេស ការិយាល័យការងារប្រជារាស្ត្រ, លោកវរសេនីយទោ មាស-ហ៊ុល រាជអង្គរក្ស ហែហមព្រះអង្គផង ទ្រង់ស្តេចយាងមកដល់ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ដែលជាកន្លែងប្រារព្ធពិធី ។

ក្រោយដែលព្រះអង្គទ្រង់បានទទួលបដិសណ្ឋារកិច្ចអំពីលោក សូ-ណែម រដ្ឋលេខាធិការក្រសួងធម្មការសាសនសិក្សាធិការ ព្រមទាំងអំពីឥស្សរជនជាន់ខ្ពស់ទាំងឡាយរួចហើយ សម្តេចសហជីវិន ទ្រង់ស្តេចយាងចូលទៅក្នុងពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ថ្វាយបង្គំព្រះសង្ឃ ដែលមានសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក គណៈមហានិកាយ និងសម្តេចព្រះសុគន្ធាធិបតីសង្ឃនាយកគណៈធម្មយុត្តិកនិកាយជាប្រធានៗ បន្ទាប់មកទៀត សម្តេចសហជីវិននាយករដ្ឋមន្ត្រីព្រះអគ្គមគ្គុទ្ទេសក៍ ទ្រង់សព្វព្រះរាជហឫទ័យថ្វេនព្រះសង្ឃជាមួយ ដោយបញ្ជាក់អំពីបញ្ហាជាច្រើន ដែលមានជាអាទិ៍ បញ្ហាការទាក់ទងនឹងប្រទេសជាមិត្តទាំងឡាយ បញ្ហា

សិក្សាធិការជាតិ បញ្ហាសេដ្ឋកិច្ចជាតិ បញ្ហាធ្វើការហត្ថកម្ម មានធ្វើផ្ទះជូនកស្រ្តក្រីក្រ លើកទំនប់សន្ទះទឹកទុកឲ្យប្រជាកស្រ្តជាដើម ។

ជាពិសេស ព្រះអង្គទ្រង់ផ្ដាច់ញ្ញាក់អំពីជនក្បត់ជាតិ ដែលជ្រកនៅក្នុងប្រទេសជិតខាង បេះតែពោលមួលបង្កាច់ឥតសមហេតុផល ប្រឆាំងចំពោះប្រទេសជាតិជាដើម ។ ល ។

លុះចប់ព្រះសន្ទរកថានេះហើយ ព្រះសង្ឃទាំងឡាយដែលមានសម្ដេចព្រះសង្ឃនាយកទាំងពីរគណៈជាប្រធាន បានសូត្រជ្រាយន៍ធម៌ជយន្តោថ្វាយពរសព្ទសាធុការ ជោគជ័យចំពោះសម្ដេចសហជីវិន សូមព្រះអង្គទ្រង់គង់នៅ ប្រកបដោយព្រះបរមសុខក្នុងព្រះដំណែងដ៏កនាំព្រះពុទ្ធសាសនានិងប្រជាជាតិខ្មែរ ឆ្ពោះទៅកាន់អភិវឌ្ឍនភាពអស់កាលជាអង្វែង ។

បន្ទាប់មកទៀត សម្ដេចសហជីវិន ទ្រង់សព្វព្រះរាជហឫទ័យបាត់ឲ្យឯកឧត្តម ទ្រៀវ-កាង បានហ្វាងនៃការធ្វាយសារពតិមាន អ្នកជាតិនិយម ប្រគេនកាសែតអ្នកជាតិនិយមចំពោះព្រះសង្ឃទាំងឡាយ តាមនាមគណៈកម្មាធិការកណ្ដាលប្រតិបត្តការនៃសង្គមរាស្រ្តនិយម ។

នៅវេលាម៉ោង៩,៣៥នាទី សម្ដេចសហជីវិន ដោយមានព្រះរាជបរិពារដដែល ហហាមព្រះអង្គផង បានសេ្ដចយានត្រឡប់ទៅកាន់ព្រះរាជដំណាក់វិញ ។

សូមបញ្ជាក់ថា អនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃទី ១៦ នេះ មាន៥ថ្ងៃគត់ គឺផ្ដើមពីពេលរសៀលថ្ងៃពុធ ៧ កើត ដល់ថ្ងៃចន្ទ ១២ កើត ខែបុស្ស ឆ្នាំកុរឯកស័ក ព.ស. ២៥០២ (២០-២៥ មករា ១៩៦០)។

មហាសន្និបាតក្នុងឆ្នាំនេះ បានជាច្រើនថ្ងៃជាងឆ្នាំមុនៗ ព្រោះសម្ដេចព្រះសង្ឃនាយកទាំងពីរគណៈ ព្រមទាំងក្រសួងធម្មការ ប្រាថ្នាជាសំខាន់ក្រើនរំលឹកមន្ត្រីសង្ឃក្នុងក្រុងនិងខេត្តក្រៅ ដោយរបៀបការៈ និងសេចក្ដីរំលឹកផ្សេងៗ ឲ្យខំយកព្រះទ័យទុកដាក់ណែនាំលោកគ្រូចៅអធិការ និងភិក្ខុ-សាមណេរ ដែលនៅក្នុងវត្តរបស់ខ្លួន ឲ្យខំសិក្សារៀនសូត្រ និងប្រតិបត្តិតាមធម៌វិន័យ ឲ្យរឹងរឹតតែចំរើនឡើង ព្រមទាំងឲ្យមានសេចក្ដីសាមគ្គីព្រមព្រៀងគ្នាជាកិយោភាព ដើម្បីរុងរឿងចំរើនដល់ជាតិ សាសនា និងព្រះមហាក្សត្រផង ។

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(តមក)

## ព្រះមហា ប៉ាង-ខាត់ រៀបរៀង

---

អតិក្ឫច្ឆ្រ គុ ដែលលំបាកក្រៃលែង ។ ពុំ. ឈ្មោះឋាននរក ។ អតិក្ឫច្ឆ្រម៑ ក្រិ. វិ ដោយលំបាកក្រៃលែង ។

អតិក្ឫត គុ. ដែលធ្វើដោយក្រៃលែង ។

អតិក្ឫតាបិ គុ. ដែលមានប្រយោជន៍ធ្វើហើយដោយក្រៃលែង, ដែលស្ទាត់ជំនាញណាស់ ។

អតិក្ឫតិ ស្ត្រី. កិរិយាធ្វើដោយក្រៃលែង ។

អតិក្ឫឝ គុ. ស្គមក្រៃពេក ។

អតិក្ឫឞ្ណ គុ. ខ្មៅក្រៃលែង, ខ្មៅព្រឹក ។

អតិកោប ពុំ. សេចក្ដីក្រោធក្រៃលែង ។ គុ ដែលមានក្រោធក្រៃពេក ។

អតិក្រម៑ ធាតុ. កន្លងទៅ, ប្រព្រឹត្តកន្លង, កន្លង (ទោស, វេលា) អតិក្រាន្ត គុ ដែលប្រព្រឹត្តកន្លង ។ នបុំ. អតីតកាល ។

(នៅមានត)